01648279

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ឯកសារលេខ 11

*តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី
ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម
ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/៣១-១០-២០០៩-អ.វ.ត.ក/អជតក (០៣)

ចំពោះមុខ: **ចៅក្រម ក្រាក់ គឹមសាន ជាប្រធាន**
**ចៅក្រម** Olivier BEAUVALLET
**ចៅក្រម ន័យ ថុល**
**ចៅក្រម** Kang Jin BAIK
**ចៅក្រម ហួត វុទ្ធី**
**ចៅក្រម ស៊ិន រិទ្ធ**
**ចៅក្រម** Steven BWANA

កាលបរិច្ឆេទ: **ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 14 / 07 / 2020
ម៉ោង (Time/Heure): 11:20
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**សាធារណៈ:**

**សេចក្តីសម្រេចលើសំណើរបស់ខៀវ សំផន ប្តឹងជំទាស់ចៅក្រមប្រាំមួយរូបនៃអង្គជំនុំជម្រះ
តុលាការកំពូលដែលបានសម្រេចសេចក្តីនៅក្នុងសំណុំរឿង ០០២/១**

**<u>សហព្រះរាជអាជ្ញា:</u>**

ជា លាង
Brenda HOLLIS

**<u>សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ្រ អង្គ
Megan HIRST

**<u>សហមេធាវីការពារក្តី ខៀវ សំផន</u>**

គង់ សំអុន
Anta GUISSÉ
Göran SLUITER

# មាតិកា


I. ប្រវត្តិនីតិវិធី ..... 1

II. សារណា ..... 7

III. ភាពអាចទទួលយកបាន ..... 9

ក. សារណា ..... 9

ខ. ការពិភាក្សា ..... 12

១. មូលដ្ឋានទី១ និងទី២ អាចទទួលយកបាន ..... 14

២. មូលដ្ឋានទី៣ អាចទទួលយកបាន ..... 20

IV. អង្គសេចក្តី ..... 22

ក. មូលដ្ឋានទី១៖ អត្ថិភាពនៃភាពលម្អៀងនៃការសម្រេចសេចក្តីជាមុនទៅលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/២ ..... 22

១. សារណា ..... 22

២. ការពិភាក្សា ..... 33

ខ. មូលដ្ឋានទី២៖ អត្ថិភាពនៃភាពលម្អៀងនៃការសំអាងហេតុដោយមានកំហុសក្នុងសាលដីកានៃសំណុំរឿង ០០២/១ ..... 55

១. សារណា ..... 56

២. ការពិភាក្សា ..... 63

គ. មូលដ្ឋានទី៣៖ ការបញ្ជាក់ពីភាពលម្អៀងចាប់តាំងពីពេលប្រកាសសាលក្រមនៃសំណុំរឿង ០០២/២ ..... 74

១. សារណា ..... 74

២. ការពិភាក្សា ..... 76

V. សម្រេចសេចក្តី ..... 79

01648281



**អង្គបុរេជំនុំជម្រះពិសេសនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** ("អ.វ.ត.ក") ដែលរៀបចំឡើងដោយគណកម្មាធិការរដ្ឋបាលតុលាការ តាមវិធាន៣៤(៦) នៃវិធានផ្ទៃក្នុង[1] បានទទួលសំណើរបស់ខៀវ សំផន សុំប្តឹងជំទាស់ចិត្តចៅក្រមប្រាំមួយរូបដែលបានសម្រេចសេចក្តីលើសំណុំរឿង ០០២/០១ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ ("សំណើជំទាស់ចិត្ត")[2]។

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ ក្នុងសំណុំរឿង០០២ សម្រេចចោទប្រកាន់ និងជូនទៅជម្រះលើ នួន ជា, អៀង សារី, អៀង ធីរិទ្ធ, និង ខៀវ សំផន ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ប្រល័យពូជសាសន៍ និងការរំលោភបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងការបំពានក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦[3]។ ក្រោយមកអៀង ធីរិទ្ធ ត្រូវបានរកឃើញថាពុំមានកាយសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ និងអៀង សារី បានស្លាប់នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣[4] បន្សល់ទុកតែនួន ជា និងខៀវ សំផន។

២. នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង បានចេញដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង០០២[5] ដែលដីកាសម្រេចនេះត្រូវបានអង្គជំនុំជម្រះតុលាការកំពូលធ្វើមោឃភាព នៅ

---

[1] សំណុំរឿង ០០២/៣១-១០-២០១៩-អវតក/អជតក(០៣) ការតែងតាំងចៅក្រមជំនួស ដើម្បីសម្រេចសេចក្តីពាក្យសុំប្តឹងជំទាស់ចិត្ត ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៩, ៧, សំណុំរឿង ០០២/៣១-១០-២០១៩-អវតក/អជតក(០៣) (កែតម្រូវលើកទី១) ការតែងតាំងចៅក្រមជំនួស ដើម្បីសម្រេចសេចក្តីពាក្យសុំប្តឹងជំទាស់ចិត្ត ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩, ៩។

[2] សំណុំរឿង ០០២/៣១-១០-២០១៩-អវតក/អជតក(០៣) សំណើរបស់ខៀវ សំផន សុំប្តឹងជំទាស់ចិត្តចៅក្រមប្រាំមួយរូប ដែលបានសម្រេចសេចក្តីលើសំណុំរឿង ០០២/១ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ ("សំណើរបស់ខៀវ សំផន សុំប្តឹងជំទាស់ចិត្ត(១)")។

[3] សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស (សំណុំរឿង០០២) ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D247 កថាខណ្ឌ១៦១៣។

[4] សំណុំរឿង ០០២ សេចក្តីសម្រេចលើសម្បទារបស់អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E138 កថាខណ្ឌ៨២, សំណុំរឿង ០០២ សេចក្តីសម្រេចលើការបញ្ចប់កិច្ចនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង សារី ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ ឯកសារ E270/1 ទំព័រ៣។

[5] សំណុំរឿង ០០២ ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ E124។

01648282

ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣[6]។ នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូង បានបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង០០២ ដោយបង្កើតជាសំណុំរឿង០០២/១ និង០០២/២ ដែលពាក់ព័ន្ធបណ្តឹងផ្សេងគ្នា នៃសកម្មភាពឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ ប្រឆាំង នួន ជា និង ខៀវ សំផន[7]។ សំណុំរឿង ០០២/១ កម្រិតត្រឹមការចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងនឹងដំណាក់កាលពីរ នៃការផ្លាស់ទីលំនៅដោយបង្ខំ និងការសម្លាប់អតីតអ្នករដ្ឋការសម័យសាធារណរដ្ឋខ្មែរ ដែលបានប្រព្រឹត្តឡើងនៅទួលពោធិ៍ជ្រៃ ភ្លាមៗបន្ទាប់ពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ[8]។ នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ អង្គជំនុំជម្រះតុលាការកំពូល បានតម្កល់សេចក្តីសម្រេច បំបែកកិច្ចដំណើរការនីតិវិធីនេះ[9]។ នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេចបន្ថែម កំណត់វិសាលភាពនៃសំណុំរឿង០០២/២[10] ដែលបន្ទាប់មកត្រូវបានតម្កល់ដោយអង្គជំនុំជម្រះតុលាការកំពូល នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤[11]។ សំណុំរឿង០០២/២ កម្រិតត្រឹមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប្រឆាំងជនជាតិវៀតណាម និងជនជាតិចាម, ឧក្រិដ្ឋកម្មដែលបានកើតឡើងនៅមន្ទីរសន្តិសុខស-២១ ក្រាំងតាចាន់ អូរកន្សែង និងភ្នំ

---

[6] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/១ ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E163/5/1/13 កថាខណ្ឌ ៥២។

[7] សំណុំរឿង ០០២ សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣, ថ្ងៃទី២៦ ខែមេសា ឆ្នាំ ២០១៣ ឯកសារ E284 ("សំណុំរឿង ០០២ សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី (ឯកសារ E284)")

[8] សំណុំរឿង ០០២ សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី (ឯកសារ E284) ផ្នែកសម្រេចសេចក្តី ទំព័រ ៧០។

[9] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ របស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង០០២ (សេចក្តីសង្ខេបនៃសំអាងហេតុ) ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ ២០១៣ ឯកសារ E284/4/7 កថាខណ្ឌ ៦-៧, ១៣, សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ របស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង០០២ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ E284/4/8 កថាខណ្ឌ ៧៦។

[10] សំណុំរឿង ០០២ សេចក្តីសម្រេចលើការបំបែក កិច្ចដំណើរការនីតិវិធីបន្ថែម លើសំណុំរឿង០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ថ្ងៃទី៤ ខែមេសា ឆ្នាំ ២០១៤ ឯកសារ E301/9/1 (សំណុំរឿង ០០២ សេចក្តីសម្រេចលើការបំបែក កិច្ចដំណើរការនីតិវិធីបន្ថែម (ឯកសារ E301/9/1)")។

[11] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម លើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ ២០១៤ ឯកសារ E301/9/1/1/3 កថាខណ្ឌ ៨១។

ក្រោល, ឧក្រិដ្ឋកម្មដែលបានកើតឡើងនៅការដ្ឋាន ទំនប់១មករា និងត្រពាំងថ្ម សហករណ៍ត្រាំកក់ ព្រលាន យន្តហោះកំពង់ឆ្នាំង, ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទ នៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការបោសសម្អាតផ្ទៃក្នុង[12]។

៣. នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ នៅក្នុងសំណុំរឿង០០២/១ អង្គជំនុំជម្រះសាលាដំបូង បានរកឃើញពិរុទ្ធភាព នួន ជា និង ខៀវ សំផន ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ដទៃទៀត រួមមានការជម្លៀសដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរបស់មនុស្សជាតិ[13] ។ ពួកគេត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារមួយអស់ជីវិត[14]។ បន្ទាប់ពីចេញសាលក្រមសំណុំរឿង០០២/១រួចហើយ នួន ជា និង ខៀវ សំផន បានដាក់សំណើសុំប្តឹងជំទាស់ ចៅក្រមអង្គជំនុំជម្រះសាលាដំបូង ដែលត្រូវជំនុំជម្រះសំណុំរឿង០០២/២[15]។ សំណើសុំប្តឹងជំទាស់ បានចោទប្រកាន់ដូចជា ការសម្រេចនៅក្នុងសាលក្រមសំណុំរឿង០០២/២ បានបង្ហាញពីភាពលម្អៀងពិតប្រាកដ របស់ចៅក្រមដែលរងការចោទប្រកាន់ និង/ឬបង្កើតឱ្យមានការយល់ឃើញដោយសមហេតុផល ពីភាពលម្អៀងទាក់ទងកិច្ចដំណើរការនីតិវិធី នាពេលអនាគតក្នុងសំណុំរឿង០០២/២ [16] ។ ចៅក្រមភាគច្រើននៃ ក្រុមប្រឹក្សាជំនុំជម្រះពិសេស បានបង្កើតឡើងដើម្បីពិចារណាទៅលើ សំណើសុំប្តឹងជំទាស់ ហើយបានច្រានចោលការចោទប្រកាន់របស់ នួន ជា និង ខៀវ សំផន ដោយមានមតិជំទាស់ដោយផ្នែក

---

[12] សំណុំរឿង ០០២ សេចក្តីសម្រេចលើការបំបែក កិច្ចដំណើរការនីតិវិធីបន្ថែម (ឯកសារ E301/9/1) កថាខណ្ឌ ២១។

[13] សំណុំរឿង ០០២/១ សំណុំរឿង ០០២/០១ សាលក្រម ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313។

[14] សំណុំរឿង ០០២/១ សំណុំរឿង ០០២/០១ សាលក្រម ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313។

[15] សំណុំរឿង ០០២ សំណើរបស់លោក ខៀវ សំផន សុំឱ្យពិនិត្យឡើងវិញ ពីភាពចាំបាច់ក្នុងការរង់ចាំ សាលក្រមក្នុងសំណុំរឿង ០០២/១ ចូលជាស្ថាពរ មុននឹងចាប់ផ្តើមការជំនុំជម្រះសំណុំរឿង ០០២/០២ និងសុំឱ្យពិនិត្យឡើងវិញ ពីការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះថ្មី ថ្ងៃទី២៥ ខែសីហា ឆ្នាំ ២០១៤ ឯកសារ E314/1 ("សំណុំរឿង ០០២ សំណើរបស់របស់ ខៀវ សំផន (ឯកសារ E314/1)"), សំណុំរឿង ០០២ បណ្តឹងជំទាស់របស់ នួន ជា ប្រឆាំងនឹងចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម យូរ ឧត្តរា ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ E314/6 ("សំណុំរឿង ០០២ បណ្តឹងជំទាស់របស់ នួន ជា (ឯកសារ E314/6)"), សំណុំរឿង ០០២ បណ្តឹងជំទាស់សាជាថ្មី ប្រឆាំងនឹងសមាសភាពចៅក្រមបច្ចុប្បន្ន នៃអង្គជំនុំជម្រះសាលាដំបូង ដែលត្រូវសម្រេចលើសំណុំរឿង០០២/០២ ថ្ងៃទី១០ ខែតុលា ឆ្នាំ ២០១៤ ឯកសារ E314/8

[16] សំណុំរឿង ០០២ សំណើរបស់របស់ ខៀវ សំផន (ឯកសារ E314/1) កថាខណ្ឌ ៤២, ៤៨ សំណុំរឿង ០០២ បណ្តឹងជំទាស់របស់ នួន ជា (ឯកសារ E314/6) កថាខណ្ឌ ៦១-១១៤, ១២២-១៣៣។

របស់ចៅក្រម DOWNING[17]។ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ អង្គជំនុំជម្រះតុលាការកំពូល បានគាំទ្រការផ្តន្ទាទោសមួយផ្នែក និងបានតម្កល់ទោសដាក់ពន្ធនាគារ នួន ជា និង ខៀវ សំផន អស់មួយជីវិត[18]។

៤. នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅក្នុងសំណុំរឿង០០២/២ អង្គជំនុំជម្រះសាលាដំបូង ដោយបានផ្តល់នូវសេចក្តីសង្ខេបផ្ទាល់មាត់ នៃការយល់ឃើញនិងផ្នែកសម្រេចសេចក្តី បានផ្តន្ទាទោស នួន ជា និង ខៀវ សំផន ដាក់ពន្ធនាគារអស់មួយជីវិត[19]។

៥. នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ ខៀវ សំផន បានប្តឹងសាទុក្ខប្រឆាំងសាលក្រម ដែលបានប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ដោយផ្អែកលើមូលដ្ឋាននៃវិការៈនីតិវិធីនិងការមិនមានសំអាងហេតុគ្រប់គ្រាន់[20]។ នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ អង្គជំនុំជម្រះតុលាការកំពូល បានច្រានចោលបណ្តឹងសាទុក្ខដោយសារមិនអាចទទួលយកបាន[21]។ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ ខៀវ សំផន បានដាក់សំណើសុំមោឃភាព ដីកាសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ដោយផ្អែកលើមូលដ្ឋានដែលថា ចៅក្រមបម្រុង RAPOZA មិនត្រូវបានតែងតាំងត្រឹមត្រូវ ឲ្យធ្វើជាចៅក្រមពេញសិទ្ធិ នៅពេលចេញដីកាសម្រេច[22]។ នៅថ្ងៃ

---

[17] សំណុំរឿង ០០២ Reasons for Decision on Applications for Disqualification, 30 January 2015, E314/12/1

[18] សំណុំរឿង ០០២/១ សាលដីកា ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36។ អង្គជំនុំជម្រះតុលាការកំពូល បានច្រានចោលពិរុទ្ធភាពរបស់ នួន ជា និង ខៀវ សំផន ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការសម្លាប់រង្គាល ប៉ុន្តែតម្កល់ពិរុទ្ធភាពនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ដទៃទៀត ដែលកើតឡើងក្នុងដំណាក់កាលទីមួយ នៃការផ្លាស់ទីលំនៅប្រជាជន។ ចំពោះអង្គហេតុដែលបានអនុវត្ត នៅក្នុងដំណាក់កាលទីពីរ នៃការផ្លាស់ទីលំនៅប្រជាជន អង្គជំនុំជម្រះតុលាការកំពូលច្រានចោលពិរុទ្ធភាព នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្ស នៃការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ប៉ុន្តែតម្កល់ពិរុទ្ធភាពនៃ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើអមនុស្សធម៌ដទៃទៀត ហើយសម្រេចថាមានពិរុទ្ធភាព ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើមនុស្សឃាត ដោយការកំណត់ប្រភេទឡើងវិញនៃអង្គហេតុ។ ចំពោះអង្គហេតុនៅទួលពោធិ៍ជ្រៃ អង្គជំនុំជម្រះតុលាការកំពូល បដិសេធចោលពិរុទ្ធភាពរបស់ នួន ជា និង ខៀវ សំផន ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើសម្លាប់រង្គាល មនុស្សឃាត និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។

[19] សំណុំរឿង ០០២/២ ប្រតិចារឹកសវនាការ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ (ការប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២) ទំព័រ ៥៣:២១ ដល់៥៦:១៧។

[20] សំណុំរឿង ០០២/២ បណ្តឹងសាទុក្ខភ្លាមៗរបស់លោក ខៀវ សំផន ប្រឆាំងនិងសាលក្រមប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០១៨ ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ ២០១៨ ឯកសារ E463/1។

[21] សំណុំរឿង ០០២/២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងការប្រកាសសេចក្តីសម្រេចសង្ខេបនៃសាលក្រមដែលបានធ្វើឡើងនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ ២០១៩ ឯកសារ E463/1/3។

[22] សំណុំរឿង ០០២/២ សំណើរបស់លោក ខៀវ សំផន សុំធ្វើមោឃភាពសេចក្តីសម្រេច E463/1/3 លើបណ្តឹងសាទុក្ខភ្លាមៗ

ទី១៦ ខែសីហា ឆ្នាំ២០១៩ អង្គជំនុំជម្រះតុលាការកំពូលបានច្រានចោល សំណើសុំមោឃភាព ដោយលើកបង្ហាញនូវព័ត៌មានលម្អិត នៃការតែងតាំងចៅក្រមបម្រុង RAPOZA[23]។

៦. នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ អង្គជំនុំជម្រះសាលាដំបូង បានជូនដំណឹងទៅភាគីនានា អំពីសាលក្រមមានសំអាងហេតុពេញលេញ ក្នុងសំណុំរឿង០០២/២[24] ។ នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ របស់ខ្លួន[25] ហើយ ខៀវ សំផន បានឆ្លើយតបចំពោះសេចក្តីជូនដំណឹងនេះ[26] ។ នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ខៀវ សំផន បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់គាត់ ក្នុងសំណុំរឿង០០២/២ នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ដោយចោទប្រកាន់អំពីកំហុសឆ្គងជាច្រើន[27] ។ នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៩ នួន ជា បានស្លាប់។

៧. នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ ខៀវ សំផន បានដាក់សំណើសុំប្តឹងជំទាស់ជិតចិត្ត[28]។ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់ចម្លើយតបរៀងៗខ្លួន ទៅនឹងសំណើសុំប្តឹងជំទាស់ជិតចិត្ត[29]។

---

ប្រឆាំងនឹងសាលក្រមប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ថ្ងៃទី២០ ខែមីនា ឆ្នាំ ២០១៩ ឯកសារ E463/1/4។

[23] សំណុំរឿង ០០២/២ សេចក្តីសម្រេចលើសំណើរបស់លោក ខៀវ សំផន សុំធ្វើមោឃភាពសេចក្តីសម្រេចលេខ E463/1/3 លើបណ្តឹងសាទុក្ខភ្លាមៗរបស់ខ្លួន ប្រឆាំងនឹងសាលក្រមប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០១៩ ឯកសារ E463/1/5។

[24] សំណុំរឿង ០០២/២ សេចក្តីសម្រេច សំណុំរឿង ០០២/២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ (ដាក់ចូលសំណុំរឿង ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩) ឯកសារ E465 ("សេចក្តីសម្រេចសំណុំរឿង ០០២/២ (E465)")។

[25] សំណុំរឿង ០០២/២ សេចក្តីជូនដំណឹងពីបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ E465/2/1 (សំណុំរឿង០០២/២ សេចក្តីជូនដំណឹងពីបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា (E465/2/1)")។

[26] សំណុំរឿង ០០២/២ ការឆ្លើយតបរបស់មេធាវីការពារក្តីឱ្យខៀវ សំផន តបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ក្នុងសំណុំរឿង០០២/២ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ F50/1។

[27] សំណុំរឿង ០០២/២ សេចក្តីជូនដំណឹងពីបណ្តឹងឧទ្ធរណ៍របស់ខៀវ សំផន (០០២/២) ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២២០១៩ ឯកសារ E465/4/1។

[28] សំណុំរឿង ០០២/៣១-១០-២០១៩-អវតក/អជតក (០៣) សំណើរបស់ ខៀវ សំផន សុំប្តឹងជំទាស់ជិតចិត្តចៅក្រមប្រាំមួយរូប ដែលបានសម្រេចសេចក្តីលើសំណុំរឿង ០០២/០១ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩, ១។

[29] សំណុំរឿង ០០២/៣១-១០-២០១៩-អវតក/អជតក (០៣) ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះសំណើរបស់ ខៀវ សំ

៨. នៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩ គណៈកម្មាធិការរដ្ឋបាលតុលាការ បានជូនដំណឹងអំពីការបង្កើត ក្រុមប្រឹក្សាជំនុំជម្រះពិសេស តាមវិធាន ៣៤(៦) នៃវិធានផ្ទៃក្នុង ដើម្បីជំនុំជម្រះលើសំណើសុំប្ដឹងជំទាស់រួមរបស់ ខៀវ សំផន[30]។ គណៈកម្មាធិការរដ្ឋបាលតុលាការ បានសម្រេចជាឯកច្ឆន្ទជ្រើសរើសចៅក្រម ប្រាក់ គឹមសាន (ជាប្រធាន) ចៅក្រម ហួត វុទ្ធី ចៅក្រម ន័យ ថុល ចៅក្រម ស៊ិន រិទ្ធិ ចៅក្រម Olivier BEAUVALLET ចៅក្រម Maureen CLARK និងចៅក្រម Kang Jin BAIK។

៩. នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩ ចៅក្រម CLARK បានជូនដំណឹងទៅគណៈកម្មាធិការរដ្ឋបាលតុលាការ អំពីការសុំដកខ្លួនរបស់គាត់ ដោយសារតែគាត់គឺជាផ្នែកមួយនៃអង្គជំនុំជម្រះតុលាការកំពូល នៅពេលដែលអង្គជំនុំជម្រះនេះ ចេញដីកាសម្រេចដែលរងការជំទាស់ លើ ខៀវ សំផន។ នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ គណៈកម្មាធិការរដ្ឋបាលតុលាការ បានសម្រេចជាឯកច្ឆន្ទជ្រើសរើសចៅក្រម Steven BWANA ជំនួសចៅក្រម Maureen CLARK នៅក្នុងក្រុមប្រឹក្សាជំនុំជម្រះពិសេស[31]។

១០. នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ សំណុំរឿងដាច់ដោយឡែកមួយ សម្រាប់ឯកសារទាក់ទងនឹងសំណើសុំប្ដឹងជំទាស់រួម ត្រូវបានបង្កើតឡើង និងបានជូនដំណឹងទៅភាគី និងក្រុមប្រឹក្សាជំនុំជម្រះពិសេស។

---

ផន សុំប្ដឹងជំទាស់រួមចៅក្រមប្រាំមួយរូប ដែលបានសម្រេចសេចក្ដីលើសំណុំរឿង ០០២/០១ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ២០១៩, ៥, សំណុំរឿង ០០២/៣១-១០-២០១៩-អវតក/អជតក (០៣) ចម្លើយតបរបស់សហមេធាវីនាំមុខ តំណាងដើមបណ្ដឹងរដ្ឋប្បវេណី ចំពោះសំណើរបស់ ខៀវ សំផន សុំប្ដឹងជំទាស់រួមចៅក្រមប្រាំមួយរូប ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩, ៦។ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាង ដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវការពេលវេលាបន្ថែមដើម្បីឆ្លើយតប។ សូមមើល សំណុំរឿង ០០២/៣១-១០-២០១៩-អវតក/អជតក (០៣) សំណើបន្ទាន់របស់ សហព្រះរាជអាជ្ញា សុំបន្ថែមពេលវេលាក្នុងការឆ្លើយតប ចំពោះសំណើប្ដឹងជំទាស់រួមរបស់ ខៀវ សំផន ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៩, ២, សំណុំរឿង ០០២/៣១-១០-២០១៩-អវតក/អជតក (០៣) សំណើបន្ទាន់របស់សហមេធាវីនាំមុខ តំណាងដើមបណ្ដឹងរដ្ឋប្បវេណី សុំបន្ថែមពេលវេលាឆ្លើយតបចំពោះឯកសារ F53 ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៩, ៣។ នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ អង្គជំនុំជម្រះតុលាការកំពូល បានពន្យាពេលវេលានៃកាលបរិច្ឆេទកំណត់ ដល់ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩។ សំណុំរឿង ០០២/៣១-១០-២០១៩-អវតក/អជតក (០៣) ដីកាសម្រេចលើសំណើបន្ទាន់របស់ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ តំណាងដើមបណ្ដឹងរដ្ឋប្បវេណី សុំបន្ថែមពេលវេលាឆ្លើយតប ចំពោះសំណើសុំប្ដឹងជំទាស់រួមរបស់ ខៀវ សំផន ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នា២០១៩, ៤។

[30] សំណុំរឿង ០០២/៣១-១០-២០១៩-អវតក/អជតក (០៣) ការតែងតាំងចៅក្រមជំនួស ដើម្បីសម្រេចសេចក្ដីលើសំណើរបស់ ខៀវ សំផន សុំប្ដឹងជំទាស់រួម ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៩, ៧។

[31] សំណុំរឿង ០០២/៣១-១០-២០១៩-អវតក/អជតក (០៣) (កំណែតម្រូវទី១) ការតែងតាំងចៅក្រមជំនួស ដើម្បីសម្រេចសេចក្ដីលើសំណើរបស់ ខៀវ សំផន សុំប្ដឹងជំទាស់រួម ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩, ៩។

១១. នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ ក្រុមប្រឹក្សាជំនុំជម្រះពិសេស បានចេញលិខិតអញ្ជើញ[32] ចៅក្រមដែលរងបណ្តឹង អនុលោមតាមវិធាន ៣៤(៧) នៃវិធានផ្ទៃក្នុង ហើយចៅក្រម JAYASINGHE[33] និងចៅក្រម MUMBA[34] បានឆ្លើយតបនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០។

## II. សារណា

១២. សហមេធាវីការពារក្តី ខៀវ សំផន ("សហមេធាវី") ដាក់សំណើទៅអង្គជំនុំជម្រះតុលាការកំពូលសុំប្តឹងជំទាស់ ចិត្តចៅក្រម ៦ រូបនៃអង្គជំនុំជម្រះតុលាការកំពូលដែលបានសម្រេចក្តីក្នុងសំណុំរឿង ០០២/០១ អនុលោមតាមវិធាន៣៤នៃវិធានផ្ទៃក្នុង [35] ។ សហមេធាវីលើកឡើងថាដើម្បីធានាបានសិទ្ធិទទួលបានការកាត់ក្តីពីតុលាការអនាគតិ[36] ចៅក្រមដែលរងបណ្តឹងគួរតែត្រូវប្តឹងជំទាស់ចិត្តលើមូលដ្ឋាន៖ (i) ភាពលម្អៀងនៅក្នុងសាលដីកាលើសំណុំរឿង០០២/០១ ដែលសម្រេចជាមុនលើបណ្តឹងសាទុក្ខលើសំណុំរឿងរឿង០០២/០២ (ii) ភាពលម្អៀងផ្អែកលើសេចក្តីសន្និដ្ឋានខុសក្នុងសាលដីកា ក្នុងសំណុំរឿង០០២/០១ (iii) ភាពមិនត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីចាប់តាំងពីពេលប្រកាសសាលក្រមក្នុងសំណុំរឿង០០២/០២ [37] ។ ដោយផ្អែកលើវិធាន៣៤(២)នៃវិធានផ្ទៃក្នុង សហមេធាវីផ្អែកទឡ្ហីករណ៍របស់ខ្លួនលើលក្ខណៈវិនិច្ឆ័យគតិយុត្តិសម្រាប់ជំទាស់ចិត្តចៅក្រោម ដោយមូលហេតុនៃភាពលម្អៀងជាក់ស្តែងនិង/ឬអាការៈនៃភាពលម្អៀងដែលមិនអាចទទួល

[32] សំណុំរឿង ០០២/៣១-១០-២០១៩-អវតក/អជតក (០៣) លិខិតអញ្ជើញចៅក្រមទាំងប្រាំមួយរូប នៃអង្គជំនុំជម្រះតុលាការកំពូល ដែលសម្រេចសេចក្តីលើសំណុំរឿង ០០២/១ ថ្ងៃទី២២ ខែមករា ឆ្នាំ២០២០, ១០។

[33] សំណុំរឿង ០០២/៣១-១០-២០១៩-អវតក/អជតក (០៣) ការឆ្លើយតបចំពោះលិខិតអញ្ជើញ ចៅក្រមទាំងប្រាំមួយរូប នៃអង្គជំនុំជម្រះតុលាការកំពូល ដែលសម្រេចសេចក្តីលើស័ណុំរឿង ០០២/១ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០, ១០/១។

[34] ស័ណុំរឿង ០០២/៣១-១០-២០១៩-អវតក/អជតក (០៣) ការឆ្លើយតបចំពោះលិខិតអញ្ជើញ ចៅក្រមទាំងប្រាំមួយរូប នៃអង្គជំនុំជម្រះតុលាការកំពូល ដែលសម្រេចសេចក្តីលើសំណុំរឿង ០០២/១ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០, ១០/២។

[35] សំណុំរឿង ០០២/៣១-១០-២០១៩-អ.វ.ត.ក/អ.ជ.ត.ក (០៣) សំណើរបស់លោក ខៀវ ស័ផន សុំប្តឹងជំទាស់ចិត្តចៅក្រម ៦ រូបនៃអង្គជំនុំជម្រះតុលាការកំពូលដែលបានសម្រេច នៅក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩, ១ ("សំណើសុំប្តឹងជំទាស់ចិត្តរបស់ ខៀវ ស័ផន" (១)") កថាខណ្ឌ ៨, ១១៦។

[36] សំណើសុំប្តឹងជំទាស់ចិត្តរបស់ ខៀវ ស័ផន (១) កថាខណ្ឌ ១២-១៨។

[37] សំណើសុំប្តឹងជំទាស់ចិត្តរបស់ ខៀវ សំផន (១) កថាខណ្ឌ ១៩។

យកបាន ដែលត្រូវបានទទួលយក និងអនុវត្តដោយ អ.វ.ត.ក[38] ។ សហមេធាវីស្នើសុំឱ្យមានសវនាការពិភាក្សាដេញដោលចំពោះមុខ ជាសាធារណៈ[39]។

១៣. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលបដិសេធសំណើសុំប្ដឹងជំទាស់ ដោយហេតុថាសំណើនោះមិនបានបំពេញតាមលក្ខខណ្ឌតម្រូវចាំបាច់កម្រិតខ្ពស់ក្នុងការជម្នះសច្ចធានៃអនាគតតុលាការដែលមានលទ្ធភាពវិនិច្ឆ័យលើរឿងក្ដីនៅ អ.វ.ត.ក[40]។

១៤. សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីមិនបានឆ្លើយតបលើអង្គសេចក្ដីនៃសំណើសុំប្ដឹងជំទាស់ចៅក្រមឡើយ។

១៥. នៅក្នុងការឆ្លើយតប ចៅក្រម Judge JAYASINGHE[41] លើកឡើងថាអនុលោមតាមវិធាន៣៤ (២) ចៅក្រមអាចត្រូវបានប្ដឹងជំទាស់ ប្រសិនបើមានការបង្ហាញថា "ចៅក្រមមានប្រយោជន៍ផ្ទាល់ខ្លួនឬហិរញ្ញវត្ថុ ឬមានការពាក់ព័ន្ធដែលអាចធ្វើឱ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតរបស់ចៅក្រមរូបនេះ ឬបង្កើតឱ្យមានភាពលម្អៀងនៃអនាគតតុលាការដែលមានលទ្ធភាពវិនិច្ឆ័យលើរឿងក្ដីនៅ អ.វ.ត.ក" [42] ។ ចៅក្រម JAYASINGHE លើកឡើងថាគាត់មិនមាន ហើយក៏មិនធ្លាប់មានផលប្រយោជន៍ឬភាពលម្អៀងបែបនោះឡើយ។ ចៅក្រម JAYASINGHE ថ្លែងបន្ថែមទៀតថា គាត់ដឹងនិងយល់អំពីកាតព្វកិច្ចរបស់ខ្លួនក្នុងការបំពេញមុខនាទីជាចៅក្រមដោយស្របតាមនីតិរដ្ឋ ដោយធានាថាសិទ្ធិទទួលបានការជំនុំជម្រះ ដោយ

---

[38] សំណើសុំប្ដឹងជំទាស់របស់ ខៀវ សំផន (១) កថាខណ្ឌ ១៩-២៣ និង ជើងទំព័រ ៣៦ *យោងទៅ* សាលដីកានៃសំណុំរឿង ០០២/០១ (ឯកសារ F36) កថាខណ្ឌ ១១២។ សេចក្ដីសម្រេចជាសាធារណៈស្ដីពីបណ្ដឹងជំទាស់ជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល រង់ចាំសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងសំណុំរឿងរបស់ នួន ជា ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៨ (ឯកសារ C11/29) កថាខណ្ឌ ២០ *យោងទៅ* តុលាការ ICTY *រឿងក្ដី រដ្ឋអាជ្ញា ទល់នឹង Furundžija* សំណុំរឿងលេខ IT-95-17/1-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០។

[39] សំណើសុំប្ដឹងជំទាស់របស់ ខៀវ សំផន (១) កថាខណ្ឌ ១១៦។

[40] សំណុំរឿង ០០២/៣១-១០-២០១៩-អ.វ.ត.ក/អ.ជ.ត.ក (០៣) ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន ប្ដឹងជំទាស់ចៅក្រមប្រាំមួយរូបនៃអង្គជំនុំជម្រះតុលាការកំពូលដែលបានសម្រេចសេចក្ដីនៅក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩, ៥ ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា (៥)") កថាខណ្ឌ ១, ៧៣។

[41] ការឆ្លើយតបទៅនឹងការអញ្ជើញចៅក្រមប្រាំមួយរូប (១០/១)។

[42] ការឆ្លើយតបទៅនឹងការអញ្ជើញរបស់ចៅក្រមប្រាំមួយរូប (១០/១)") *យោងទៅ* វិធាន ៣៤(២) នៃវិធានផ្ទៃក្នុង។

01648289

ត្រឹមត្រូវរបស់ជនជាប់ចោទត្រូវបានការពារដោយឯករាជ្យ ឥតលម្អៀង និងម៉ឺងម៉ាត់ក្នុងការកាត់សេចក្តី[43]។ ចៅក្រម JAYASINGHE សន្និដ្ឋានថាក្នុងការធានាបាននូវសុចរិតភាពជាចៅក្រម សេចក្តីសម្រេច ដែលយើងបានធ្វើឡើងគឺផ្អែកលើការវាយតម្លៃយ៉ាងពិតប្រាកដនិងជាសត្យានុម័តលើអង្គច្បាប់និងអង្គហេតុ [44] ។ ចៅក្រម MWACHANDE-MUMBA យល់ស្របនឹងសារណារបស់ចៅក្រម JAYASINGHE[45]។

## III. ភាពអាចទទួលយកបាន

### ក. សារណា

១៦. សហមេធាវីការពារក្តី ខៀវ សំផន ("សហមេធាវី") លើកឡើងថា សំណើសុំប្តឹងជំទាស់ អាចទទួលយកបាន អនុលោមតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុង ដោយសារ សំណើនេះ (១) ត្រូវបានដាក់ខណៈដែលបណ្តឹងសាទុក្ខកំពុងរង់ចាំការសម្រេច ចាប់តាំងពីការដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ មកម្ល៉េះ (២) ផ្អែកលើវិសាលភាពនៃបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើសំណុំរឿង ០០២/០២ និងដែលត្រូវកម្រិតត្រឹមតែកំហុសដែលភាគីបានលើកឡើង និង (៣) ផ្អែកលើភាពមិនប្រក្រតីនៃកិច្ចដំណើរការនីតិវិធីនាពេលថ្មីៗកន្លងទៅ[46]។ សហមេធាវីអះអាងថា សំណើសុំប្តឹងជំទាស់ ផ្តល់ជា "លាយលក្ខណ៍អក្សរនូវសំអាងហេតុ និងភស្តុតាងដើម្បីគាំទ្រដល់ការចោទប្រកាន់អំពីភាពលម្អៀង" ដោយកត់សម្គាល់អំពីទំនាក់ទំនងរវាងសំអាងហេតុនៃសាលក្រមលើសំណុំរឿង ០០២/០២ សំអាងហេតុនៃសាលដីកាលើសំណុំរឿង ០០២/០១ និងផលប៉ះពាល់លើបណ្តឹងសាទុក្ខប្រឆាំងសាលក្រមលើសំណុំរឿង ០០២/០២[47] ។ សហមេធាវីអះអាងបន្ថែមថា ឧបសម្ព័ន្ធ ១ ដល់ ១៦ ដែលរៀបរាប់អំពីការចោទប្រកាន់នូវកំហុសនៅក្នុង

---

[43] ការឆ្លើយតបទៅនឹងការអញ្ជើញរបស់ចៅក្រមប្រាំមួយរូប (១០/១)។

[44] ការឆ្លើយតបទៅនឹងការអញ្ជើញរបស់ចៅក្រមប្រាំមួយរូប (១០/១)។

[45] ការឆ្លើយតបទៅនឹងការអញ្ជើញរបស់ចៅក្រមប្រាំមួយរូប (១០/២)។

[46] សំណុំរឿង ០០២/៣១-១០-២០១៩-អ.វ.ត.ក/អ.ជ.ត.ក (០៣) សំណើរបស់លោក ខៀវ សំផន សុំប្តឹងជំទាស់ចៅក្រម ៦ រូប នៃអង្គជំនុំជម្រះតុលាការកំពូលដែលបានសម្រេច នៅក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩, ១ ("សំណើសុំប្តឹងជំទាស់របស់ ខៀវ សំផន" (១)") កថាខណ្ឌ ១១។

[47] សំណើសុំប្តឹងជំទាស់របស់ ខៀវ សំផន (១) កថាខណ្ឌ ១១។

01648290

សាលក្រមលើសំណុំរឿង ០០២/០២ បង្ហាញពីទំហំនៃបញ្ហាដែលចៅក្រមរងបណ្តឹងជំទាស់បានសម្រេចរួចហើយ[48]។

១៧. សហព្រះរាជអាជ្ញាមិនបានជំទាស់ទៅនឹងភាពអាចទទួលយកបាននៃសំណើសុំប្តឹងជំទាស់ទេ[49]។

១៨. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា សំណើសុំប្តឹងជំទាស់មិនអាចទទួលយកបានទេ ដោយសារ (១) សំណើនេះត្រូវបានដាក់យឺតយ៉ាវខ្លាំង និង (២) ផលប្រយោជន៍នៃយុត្តិធម៌គាំទ្រដល់ការច្រានចោលសំណើនេះ[50]។

១៩. ពាក់ព័ន្ធនឹងការចោទប្រកាន់ពីការពន្យារពេលដាក់សំណើសុំប្តឹងជំទាស់ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា (១) សហមេធាវីបានដឹងអំពីមូលដ្ឋាននៃការប្តឹងជំទាស់អស់រយៈពេលបីឆ្នាំមកហើយ[51] (២) សហមេធាវីបានដឹងអំពីបំណងរបស់ខ្លួនក្នុងការប្តឹងសាទុក្ខតាំងពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨[52] និង (៣) កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខចាប់ផ្តើមពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨[53]។

២០. ទីមួយ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកជាទឡ្ហីករណ៍ថា សហមេធាវីបានដឹងថា ចៅក្រមដែលបានសម្រេចសេចក្តីនៅក្នុងសំណុំរឿង ០០២/០១ មានភាពលម្អៀង ដោយសារតួនាទីរបស់ពួកគាត់ក្នុងការផ្តន្ទាទោស ខៀវ សំផន នៅក្នុងសំណុំរឿង ០០២/០១ យ៉ាងហោចណាស់នៅខែវិច្ឆិកាឆ្នាំ២០១៦ នៅពេលចេញសាលដីកាលើសំណុំរឿង ០០២/០១[54]។ ទីពីរ សហមេធាវីនាំមុខតំណាងដើម

[48] សំណើសុំប្តឹងជំទាស់របស់ ខៀវ សំផន (១) កថាខណ្ឌ ១១។

[49] សំណុំរឿង ០០២/៣១-១០-២០១៩-អ.វ.ត.ក/អ.ជ.ត.ក (០៣) ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ចៅក្រមប្រាំមួយរូបនៃអង្គជំនុំជម្រះតុលាការកំពូលដែលបានសម្រេចសេចក្តីនៅក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩, ៥។

[50] សំណុំរឿង ០០២/៣១-១០-២០១៩-អ.វ.ត.ក/អ.ជ.ត.ក (០៣) ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះសំណើរបស់ ខៀវ សំផន សុំប្តឹងជំទាស់ចៅក្រម ៦ រូបនៃអង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩, ៦ ("ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (៦)") កថាខណ្ឌ ៥-៥៧។

[51] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (៦) កថាខណ្ឌ ១៧-២៧។

[52] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (៦) កថាខណ្ឌ ២៨-៣០។

[53] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (៦) កថាខណ្ឌ ៣១-៣៥។

[54] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (៦) កថាខណ្ឌ ១៧, ២២ *យោងទៅ* សំណុំរឿង ០០២/០២ សំអាងហេតុចំពោះសេចក្តីសម្រេចលើបណ្តឹងជំទាស់ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ ឯកសារ E314/12/1 ("សេចក្តីសម្រេច

បណ្ដឹងរដ្ឋប្បវេណីលើកជាទឡ្ហីករណ៍ថា សហមេធាវីបានដឹងពីបំណងរបស់ខ្លួនក្នុងការប្ដឹងសាទុក្ខ ចាប់ពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៦ មកម្ល៉េះ នៅពេលអង្គជំនុំជម្រះសាលាដំបូងចេញសាលក្រមសង្ខេបដែលផ្តល់នូវសេចក្តីសន្និដ្ឋាននានាជាគន្លឹះ រួមទាំងការសន្និដ្ឋានជាអវិជ្ជមានពាក់ព័ន្ធនឹងការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលរបស់ ខៀវ សំផន និងសេចក្តីថ្លែងការណ៍នានាទៅកាន់សារព័ត៌មានដែលបញ្ជាក់ពីបំណងរបស់ខ្លួនក្នុងការប្តឹងសាទុក្ខ[55]។ ចាប់តាំងពីពេលនោះមក បញ្ហាអំពីភាពលម្អៀងរបស់ចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូលលែងជាសម្មតិកម្មទៀតហើយ[56]។ ទីបី សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអះអាងថាកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខចាប់ផ្តើមនៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ ដោយការដាក់ "បណ្តឹងសាទុក្ខភ្លាមៗរបស់លោក ខៀវ សំផន ប្រឆាំងនឹងសាលក្រមប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨" ហើយថា សហមេធាវីគួរតែដាក់សំណើសុំប្តឹងជំទាស់ ... 

២១. ទាក់ទិននឹងផលប្រយោជន៍យុត្តិធម៌ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថាប្រយោជន៍យុត្តិធម៌គាំទ្រដល់ការច្រានចោលសំណើសុំប្តឹងជំទាស់

យុត្តិធម៌គាំទ្រឱ្យពង្រឹងការអនុវត្តវិធាននីតិវិធីជាធរមាន[61]។ ការបដិសេធសំណើរបស់មេធាវីការពារក្ដីដែលយឺតយ៉ាវដោយចាត់ទុកថាមិនអាចទទួលយកបាន ធានានូវការអនុវត្តកិច្ចដំណើរការនីតិវិធីដោយឆាប់រហ័ស និងយុត្តធម៌[62]។

## ខ. ការពិភាក្សា

២២. ជាដំបូង ក្រុមប្រឹក្សាជំនុំជម្រះពិសេសសូមលើកឡើងនូវមូលដ្ឋានផ្លូវច្បាប់ដែលបញ្ញត្តិអំពីភាពអាចទទួលយកបាននៃសំណើសុំប្ដឹងជំទាស់ចៅក្រម។ បន្ទាប់មក ក្រុមប្រឹក្សាជំនុំជម្រះពិសេសនឹងលើកឡើងនូវភាពអាចទទួលយកបាននៃមូលដ្ឋាននីមួយៗនៅក្នុងសំណើសុំប្ដឹងជំទាស់។

២៣. វិធាន ៣៤ នៃវិធានផ្ទៃក្នុងរៀបរាប់អំពីនីតិវិធី និងមូលដ្ឋានសម្រាប់ប្ដឹងជំទាស់ចៅក្រមនៅ អ.វ.ត.ក[63]។ ពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃសំណើសុំប្ដឹងជំទាស់ចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូល មានវិធាន ៣៤(៣) និង (៤)(ឃ) នៃវិធានផ្ទៃក្នុងដែលចែងថា ពាក្យសុំ (១) "ត្រូវបង្ហាញឱ្យច្បាស់លាស់អំពីមូលហេតុនៃបណ្ដឹង និងត្រូវមានភស្តុតាងបញ្ជាក់ផងដែរ" (២) "ត្រូវធ្វើឡើងឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន នៅពេលណាដែលភាគីបានដឹងអំពីមូលហេតុនោះ" និង (៣) "ត្រូវតែធ្វើឡើង... ពាក់ព័ន្ធទៅនឹងបញ្ហាដែលកើតឡើងមុនពេលធ្វើបណ្ដឹងសាទុក្ខ នៅពេលចាប់ផ្ដើមនីតិវិធីបណ្ដឹងសាទុក្ខ ឬ ពាក់ព័ន្ធទៅនឹងបញ្ហា ... ដែលភាគីមិនបានដឹងនៅមុនពេលចាប់ផ្ដើមនីតិវិធីបណ្ដឹងសាទុក្ខ មុនពេលធ្វើសេចក្ដីសម្រេចចុងក្រោយលើបណ្ដឹងសាទុក្ខនោះ"[64]។ ដូចដែលអង្គជំនុំជម្រះជាច្រើននៅ អ.វ.ត.ក បានសម្រេចរួចហើយគឺថា លក្ខខណ្ឌទាំងនេះជាលក្ខខណ្ឌត្រួត និងត្រូវតែបំពេញឱ្យបាន[65]។

---

[61] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី (៦) កថាខណ្ឌ ៥៤-៥៦។

[62] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី (៦) កថាខណ្ឌ ៥៤-៥៦។

[63] វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (វិ.លើកទី៩) វិសោធនកម្មនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ វិធាន ៣៤។

[64] វិធាន ៣៤(៣), (៤) នៃវិធានផ្ទៃក្នុង។

[65] សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក (១) សេចក្ដីសម្រេចលើសំណើរបស់ អៀង ធីរិទ្ធ សុំប្ដឹងជំទាស់ចៅក្រម សោម សិរីវឌ្ឍ ដោយសារកង្វះឯករាជភាព ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១ ឯកសារលេខ ១/៤ ("សេចក្ដីសម្រេចលើស័ណើរបស់ អៀង ធីរិទ្ធ (ឯកសារលេខ ១/៤)") កថាខណ្ឌ ៤។ សំណុំរឿង ០០២/១៧-០៦-២០១០-អ.វ.ត.ក/អ.ប.ជ (០៩) សាលដីកាលើបណ្ដឹងជំទាស់ ចៅក្រម យូ ប៊ុនឡេង ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០ ឯកសារលេខ ៨ ("សាលដីកាលើបណ្ដឹងជំទាស់ ចៅក្រម យូ ប៊ុនឡេង (ឯកសារលេខ ៨)") កថាខណ្ឌ ១២។

២៤. នៅក្នុងការសម្រេចពីភាពអាចទទួលយកបាននៃសំណើសុំប្តឹងជំទាស់ អង្គបុរេជំនុំជម្រះបានសម្រេចថា "ដើម្បីបំពេញលក្ខខណ្ឌនៃភាពច្បាស់លាស់សម្រាប់គោលបំណងនៃការទទួលយកពាក្យបណ្តឹង ម្ចាស់បណ្តឹងត្រូវតែបង្ហាញមូលហេតុនៃបណ្តឹងជំទាស់ឲ្យបានច្បាស់លាស់គ្រប់គ្រាន់ ដើម្បីឲ្យអង្គជំនុំជម្រះ អាចធ្វើការត្រួតពិនិត្យលើអង្គសេចក្តីបានត្រឹមត្រូវ"[66]។

២៥. ពាក់ព័ន្ធនឹងភាពទាន់ពេលវេលានៃសំណើសុំ ក្រុមប្រឹក្សាជំនុំជម្រះពិសេសកត់សម្គាល់ពីលក្ខណៈត្រួតនៃលក្ខខណ្ឌនានាដែលមានចែងក្នុងវិធាន ៣៤(៣) និង (៤)(ឃ) នៃវិធានផ្ទៃក្នុង[67] និងពិចារណាឃើញថា បទប្បញ្ញត្តិទាំងពីរមានមុខងារជា ពេលកំណត់សម្រាប់ដាក់សំណើសុំប្តឹងជំទាស់ប្រឆាំងនឹងចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូល។ អង្គបុរេជំនុំជម្រះបានសម្រេចថា ដើម្បីបំពេញទៅតាមលក្ខខណ្ឌដែលមានចែងក្នុងវិធាន ៣៤(៣) នៃវិធានផ្ទៃក្នុង ភាគីគួរដាក់សំណើសុំ "ឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាននៅពេលដែលភាគីបានដឹងអំពីមូលហេតុនោះ"[68]។ ក្នុងការកំណត់ឲ្យបានកាន់តែច្បាស់ថែមទៀតពីលក្ខខណ្ឌនៃភាពទាន់ពេលវេលា អង្គជំនុំជម្រះតុលាការបានសម្រេចថា "ម្ចាស់បណ្តឹងត្រូវតែមានបណ្តឹងសាទុក្ខ ដែលកំពុងរង់ចាំសេចក្តីសម្រេចពីអង្គជំនុំជម្រះ នៅពេលដែលម្ចាស់បណ្តឹងដាក់បណ្តឹងជំទាស់របស់គាត់"[69]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសសង្កេតឃើញថា អនុលោមតាមវិធាន ១០៥(២) និង (៣) នៃវិធានផ្ទៃក្នុង កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខចាប់ផ្តើមនៅពេលមានការដាក់បណ្តឹងសាទុក្ខភ្លាម ឬការជូនដំណឹងអំពីបណ្តឹងសាទុក្ខ[70]។

[66] សាលដីកាលើបណ្តឹងជំទាស់ ចៅក្រម យូ ប៊ុនឡេង (ឯកសារលេខ ៨) កថាខណ្ឌ ២៦។

[67] សេចក្តីសម្រេចលើសំណើរបស់ អៀង ធីរិទ្ធ (ឯកសារលេខ ១/៤) កថាខណ្ឌ ៩។

[68] សំណុំរឿង ០០២/១៣-១០-២០០៩-អ.វ.ត.ក/អ.ប.ជ (០២) សាលដីកាលើពាក្យបណ្តឹងជំទាស់របស់ជនត្រូវចោទ ខៀវ សំផន ចំពោះសហចៅក្រមស៊ើបអង្កេត ចៅក្រម Marcel Lemonde ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ឯកសារលេខ ៧ ("សាលដីកាលើពាក្យបណ្តឹងជំទាស់របស់ ខៀវ សំផន") កថាខណ្ឌ ២០។ *សូមមើលផងដែរ* សាលដីកាលើបណ្តឹងជំទាស់ ចៅក្រម យូ ប៊ុនឡេង (ឯកសារលេខ ៨) កថាខណ្ឌ ១៩។ សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ ០១) សេចក្តីសម្រេចជាសាធារណៈស្តីពីបណ្តឹងជំទាស់ជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល រង់ចាំសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ននៅក្នុងសំណុំរឿងរបស់ នួន ជា ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៨ ឯកសារ C11/29 កថាខណ្ឌ ៩។

[69] សេចក្តីសម្រេចលើសំណើរបស់ អៀង ធីរិទ្ធ (ឯកសារលេខ ១/៤) កថាខណ្ឌ ៩។

[70] វិធាន ១០៥(២) និង (៣) នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* សេចក្តីសម្រេចលើសំណើរបស់ អៀង ធីរិទ្ធ (ឯកសារលេខ ១/៤) កថាខណ្ឌ ១ ("ជនជាប់ចោទបានចាប់ផ្តើមដំណើរការនីតិវិធីប្តឹងសាទុក្ខ នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ដោយដាក់

២៦. នៅក្នុងករណីនេះ ក្រុមប្រឹក្សាជំនុំជម្រះពិសេសនឹងពិចារណាថាតើ មូលដ្ឋានទីបីនៃសំណើសុំប្តឹងជំទាស់ ស្របទៅនឹងលក្ខខណ្ឌនានាដែលមានចែងក្នុងវិធាន ៣៤(៣) និង (៤)(ឃ) នៃវិធានផ្ទៃក្នុង ឬយ៉ាងណា។

### ១. មូលដ្ឋានទី១ និងទី២ អាចទទួលយកបាន

២៧. ក្រុមប្រឹក្សាជំនុំជម្រះពិសេសកត់សម្គាល់ជាបឋមថា មូលដ្ឋានទី១ លើកឡើងអំពីអត្ថិភាពនៃភាពលម្អៀងនៃការសម្រេចសេចក្តីជាមុនទៅលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២។ មូលដ្ឋានទី២ លើកឡើងនូវ "សេចក្តីសន្និដ្ឋានខុសខ្លះនៃសាលដីកាលើសំណុំរឿង ០០២/០១" ដែលនាំឱ្យមានភាពលម្អៀង[71]។ ដោយរម្លឹកថា ដើម្បីបំពេញទៅតាមលក្ខខណ្ឌនៃភាពច្បាស់លាស់ដែលមានចែងក្នុងវិធាន ៣៤(៣) នៃវិធានផ្ទៃក្នុង ភាគីត្រូវបង្ហាញនូវមូលហេតុណាមួយ ដើម្បីឱ្យអង្គជំនុំជម្រះអាចត្រួតពិនិត្យទៅលើអង្គសេចក្តីបាន[72] នោះ ក្រុមប្រឹក្សាជំនុំជម្រះពិសេសពិចារណាឃើញថា មូលដ្ឋានទី១ និងទី២ បានបំពេញទៅតាមលក្ខខណ្ឌតម្រូវនេះហើយ។

២៨. ដោយពិចារណាដល់លក្ខខណ្ឌនៃភាពទាន់ពេលវេលា ក្រុមប្រឹក្សាជំនុំជម្រះពិសេសសន្និដ្ឋានថា សំណើសុំប្តឹងជំទាស់ត្រូវបានដាក់រយៈពេលជាងបួនខែក្រោយកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខបានចាប់ផ្តើម ហើយថា សហមេធាវីការពារក្តីបានដឹងអំពីបញ្ហានានានៅក្នុងមូលដ្ឋានទី១ និងទី២ រួចហើយ មុនពេលមានបណ្តឹងសាទុក្ខ។

២៩. ទីមួយ ពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវ "ឆាប់បំផុតតាមដែលអាចធ្វើទៅបាន" អនុលោមតាមវិធាន ៣៤(៣) នៃវិធានផ្ទៃក្នុង ក្រុមប្រឹក្សាជំនុំជម្រះពិសេសយល់ឃើញថាជាការចាំបាច់ដែលត្រូវរម្លឹកពីពេលដែល

---

បណ្តឹងសាទុក្ខភ្លាមៗ ជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង")។ យន្តការកិច្ចការបន្ទាប់បន្សំជាអន្តរជាតិសម្រាប់តុលាការព្រហ្មទណ្ឌ ("MICT") *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង* *Mladić* សំណុំរឿងលេខ MICT-13-56-A សេចក្តីសម្រេចលើពាក្យសុំពន្យារពេលបន្ថែមទៀត ដើម្បីដាក់សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៨ ទំព័រ ២ ("ការដាក់សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខកំណត់ជាការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខនៅក្នុងរឿងក្តីណាមួយ")។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា ("ICTR") *រឿងក្តី Nyiramasuhuko និងអ្នកផ្សេងទៀត ទល់នឹង រដ្ឋអាជ្ញា* សំណុំរឿងលេខ ICTR-98-42-A សេចក្តីសម្រេចលើសំណើសុំពន្យារពេលដើម្បីដាក់សារណាបណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១១ កថាខណ្ឌ ៥។

[71] សំណើសុំប្តឹងជំទាស់របស់ ខៀវ សំផន (១) កថាខណ្ឌ ១៩។

[72] សាលដីកាលើបណ្តឹងជំទាស់ ចៅក្រម យូ ប៊ុនឡេង (ឯកសារលេខ ៨) កថាខណ្ឌ ២៦។

សហមេធាវី "បានដឹង" អំពីសំអាងហេតុដែលពាក់ព័ន្ធនៅក្នុងសាលដីកាលើសំណុំរឿង ០០២/០១ និងនៅក្នុងសាលក្រមលើសំណុំរឿង ០០២/០២ ជាទឡ្ហីករណ៍ដែលយកមកសំអាងនៅក្នុងមូលដ្ឋានទី១ និងទី២។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសសង្កេតឃើញថា សាលដីកាលើសំណុំរឿង ០០២/០១ ត្រូវបានចេញនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦[73] ចំណែកឯសំអាងហេតុពេញលេញសម្រាប់សាលក្រមលើសំណុំរឿង ០០២/០២ ត្រូវបានជូនដំណឹងដល់ភាគីនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩[74]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសកត់សម្គាល់ថា នៅក្នុងសំណើសុំពន្យារពេល និងបន្ថែមចំនួនទំព័រនៃសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ខ្លួន នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ សហមេធាវីបានលើកឡើងអំពី "ការរៀបចំបណ្តឹងដិតចិត្ត" ក្នុងការគាំទ្រដល់សំណើនោះ[75]។

៣០. ក្រុមប្រឹក្សាជំនុំជម្រះពិសេសមិនយល់ស្របតាមទឡ្ហីករណ៍របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី[76] ដែលថា នៅក្នុងបរិបទនៃវិធាន ៣៤(៣) នៃវិធានផ្ទៃក្នុង សហមេធាវីបានដឹងពីមូលដ្ឋានទី១ និងទី២ អស់រយៈពេលបីឆ្នាំមកហើយ ចាប់ពីខែវិច្ឆិកា ឆ្នាំ២០១៦ នៅពេលចេញសាលដីកាលើសំណុំរឿង ០០២/០១ ឬចាប់ពីខែវិច្ឆិកា ឆ្នាំ២០១៦ នៅពេលអង្គជំនុំជម្រះសាលាដំបូងចេញសាលក្រមសង្ខេបលើសំណុំរឿង ០០២/០២ នោះឡើយ។ ទោះបី "ភាគីអាចដឹងអំពី "ភស្តុតាងបញ្ជាក់" មួយចំនួន មុនពេលដែលខ្លួនបានដឹងអំពី "មូលហេតុនៃបណ្តឹងដិតចិត្ត"[77] ក៏ដោយ តែសហមេធាវីអាចដឹងច្បាស់អំពីការចោទប្រកាន់ពីការធ្វើសេចក្តីសម្រេចជាមុន ឬសេចក្តីសន្និដ្ឋានដែលមានកំហុសឆ្គង ត្រឹមតែក្រោយពេលដែលមានការផ្សព្វផ្សាយសាលក្រមលើសំណុំរឿង ០០២/០២ ដែលមានសំអាងហេតុពេញលេញ និង រកឃើញនូវបញ្ហាត្រួតគ្នាជាមួយបញ្ហានានានៅសាលដីកាលើសំណុំរឿង ០០២/០១ តែប៉ុណ្ណោះ[78]។ ហេតុនេះ

---

[73] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36។

[74] សំណុំរឿង ០០២/០២ សាលក្រមលើសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ (ដាក់នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩) ឯកសារ E465។

[75] សំណុំរឿង ០០២/០២ សំណើរបស់លោក ខៀវ សំផន សុំពន្យារពេល និងបន្ថែមចំនួនទំព័រនៃសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ ឯកសារ F39/1.1 កថាខណ្ឌ ៣៦។

[76] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (៦) កថាខណ្ឌ ១៧, ២៨។

[77] សាលដីកាលើបណ្តឹងដិតចិត្ត ចៅក្រម យូ ប៊ុនឡេង (ឯកសារលេខ ៨) កថាខណ្ឌ ១៩។

[78] *សូមមើលផងដែរ* សេចក្តីសម្រេចលើបណ្តឹងដិតចិត្តក្នុងសំណុំរឿង ០០២/០២ (E314/12/1) កថាខណ្ឌ ៣២ (ដែលក្រុមប្រឹក្សាជំនុំជម្រះពិសេសបានកត់សម្គាល់ថា ទោះបីភាគីបានដឹងពី "អង្គហេតុដែលអះអាងថាបង្ហាញឲ្យឃើញពីការលេចចេញនូវភាពលម្អៀង" និងការពន្យារពេលដាក់សំណើសុំប្តឹងដិតចិត្តក្នុងចំណុចនោះក៏ដោយ ក៏ "មូលហេតុជាច្រើន [...] ផ្អែកទៅលើសំអាង

ក្រុមប្រឹក្សាជំនុំជម្រះពិសេសសន្និដ្ឋានថា សម្រាប់គោលបំណងនានានៃវិធាន ៣៤(៣) នៃវិធានផ្ទៃក្នុង សហមេធាវីបានដឹងអំពីមូលដ្ឋានចំពោះភាពលម្អៀងដែលបានចោទប្រកាន់នៅក្នុងមូលដ្ឋានទី១ និងទី២ នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ ឬយ៉ាងយូរបំផុតគឺនៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩។

៣១. ចំណុចទី២ ពាក់ព័ន្ធនឹងលក្ខខណ្ឌ "នៅពេលចាប់ផ្តើមនីតិវិធីបណ្តឹងសាទុក្ខ" អនុលោមតាមវិធាន ៣៤(៤)(ឃ) ក្រុមប្រឹក្សាជំនុំជម្រះពិសេសសូមរំលឹកឡើងវិញថា កិច្ចដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍ចាប់ផ្តើមរាប់ពីពេលដាក់បណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំ ឬ សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍[79]។ ផ្ទុយពីការអះអាងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី [80] ក្រុមប្រឹក្សាជំនុំជម្រះពិសេសពិចារណាឃើញថា កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខនៅក្នុងរឿងក្តីបច្ចុប្បន្នពុំបានចាប់ផ្តើមនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ នៅពេលដាក់ "បណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងការប្រកាសសេចក្តីសម្រេចសង្ខេបនៃសាលក្រមដែលបានធ្វើឡើងនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨" ("បណ្តឹងឧទ្ធរណ៍ភ្លាមៗ") [81]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសសង្កេតឃើញថា បណ្តឹងសាទុក្ខភ្លាមៗពុំមែនជាបណ្តឹងសាទុក្ខបន្ទាន់បន្ទំនៅក្នុងស្មារតីនៃវិធាន ១០៤(៤)(ខ) [82] ប៉ុន្តែ វាជាបណ្តឹងប្រឆាំងនឹងសេចក្តីសង្ខេបសំអាងហេតុ និងសេចក្តីសម្រេចចំពោះអនីយ័តភាពផ្លូវការ រួមទាំង "ពុំមានសំអាងហេតុ"[83] ដែលសម្រេចថា មិនអាចទទួលយកបាន[84] និងមិនអាចផ្តួចផ្តើមជាកិច្ចដំណើរការនីតិវិធីនោះឡើយ។ ដូច្នេះ ក្រុមប្រឹក្សាជំនុំជម្រះពិសេសយល់ឃើញថា ការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខនៅក្នុងរឿងក្តីបច្ចុប្បន្ន គឺបន្ទាប់ពីពេលសហព្រះរាជអាជ្ញាបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខកាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩[85]។

---

ហេតុជាក់លាក់នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ និងសេចក្តីសម្រេចស្តាពរស្តីពីសាក្សី ដែលជាក់ស្តែងគេអាចដឹងបានតែនៅពេលមានការផ្សព្វផ្សាយជាសាធារណៈនៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤" ប៉ុណ្ណោះ)។

[79] *សូមមើល* កថាខណ្ឌ ២៥ *ខាងលើ*។

[80] ចម្លើយតបរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (៦) កថាខណ្ឌ ៣១។

[81] សំណុំរឿង ០០២/២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងការប្រកាសសេចក្តីសម្រេចសង្ខេបនៃសាលក្រមដែលបានធ្វើឡើងនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ឯកសារ E463/1/3។

[82] វិធាន ១០៤(៤)។

[83] សំណុំរឿង០០២/២ បណ្តឹងសាទុក្ខភ្លាមៗរបស់ខៀវ សំផន ឯកសារ E463/1/3។

[84] *សូមមើល* សំណុំរឿង ០០២/២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ឯកសារ E463/1/3។

[85] សំណុំរឿង ០០២/២ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអំពីបណ្តឹងសាទុក្ខប្រឆាំងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ E465/2/1។

៣២. ក្រុមប្រឹក្សាជំនុំជម្រះពិសេសសង្កេតឃើញថា យោងតាមអត្ថន័យនៃវិធាន ៣៤ និង ៣៩(១) ថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០១៩ គឺជាកាលបរិច្ឆេទមុនដំបូងបំផុតនៅពេលសហមេធាវីការពារក្តីអាចដាក់បណ្តឹងជំទាស់ ចិត្ត ដែលទើបតែបានដាក់នាពេលក្រោយមក ពោលគឺ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩[86] ជាងរយៈពេល ០៤ ខែ ក្រោយកិច្ចដំណើរការនីតិវិធីបានចាប់ផ្តើម និងរយៈពេល ០៦ខែ ក្រោយសហមេធាវីបានដឹងអំពីមូលដ្ឋាន ទី១ និងទី២។

៣៣. ទោះបីជាយ៉ាងនេះក៏ដោយ ក្រុមប្រឹក្សាជំនុំជម្រះពិសេសកត់សម្គាល់ឃើញថា ខ្លួនមានឆន្ទានុសិទ្ធិ ទទួលយកបណ្តឹងជំទាស់ចិត្តតាមទម្រង់ច្បាប់ ដើម្បីសម្រេចលើអង្គសេចក្តី បើទោះជាពុំបានដាក់ប្តឹងក្នុងរយៈ ពេលកំណត់ក៏ដោយ[87]។ ជាពិសេស នៅពេលបណ្តឹងជំទាស់ចិត្តលើកចំណុចសារធាតុសំខាន់អំពីភាពយុត្តិធម៌នៃ កិច្ចដំណើរការនីតិវិធី ក្រុមប្រឹក្សាជំនុំជម្រះពិសេសអាចសម្រេចទទួលយកមកជំនុំជម្រះទៅតាមករណី នីមួយៗ[88]។ ពាក់ព័ន្ធនឹងភាពយុត្តិធម៌ អង្គបុរេជំនុំជម្រះបានសម្រេចថា "មាត្រា ៣៣(ថ្មី) នៃច្បាប់ អ.វ.ត.ក

[86] បណ្តឹងជំទាស់ចិត្តរបស់ ខៀវ សំផន (១)។

[87] វិធាន ៣៩(៤) ("តាមគំនិតផ្តួចផ្តើមរបស់ខ្លួន [...] អង្គជំនុំជម្រះអាច [...] ទទួលស្គាល់ថាមានសុពលភាពចំពោះកិច្ចទាំងឡាយ ណាដែលធ្វើក្រោយពីពេលកំណត់ដែលមានចែងនៅក្នុងវិធានផ្ទៃក្នុងនេះត្រូវផុតរលត់ ប្រសិនបើខ្លួនយល់ឃើញថាត្រឹមត្រូវសម ហេតុផល")។

[88] *សូមមើល* សំណុំរឿង ០០២/២ សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្ត (ឯកសារ E314/12/1) កថាខណ្ឌ ៣២ ("ទោះបីជាមាន មន្ទិល [...] ជារួម ការទទួលយកបណ្តឹងជំទាស់ចិត្តទាំងអស់ និងឆ្លើយតបចំពោះសំណើនានាដែលបានលើកឡើងនោះ គឺជាផល ប្រយោជន៍នៃយុត្តិធម៌")។ សំណុំរឿង ០២/០៨-០៧-២០០៩-អវតក-អបជ សេចក្តីសម្រេចលើពាក្យសុំរបស់ជនត្រូវចោទ ប្តឹងជំទាស់ ចិត្តលោកStephen Heder និង David Boyle ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារលេខ ៣ កថាខណ្ឌ ១២។ *សូមមើលផង ដែរ* តុលាការព្រហ្មទណ្ឌអន្តរជាតិ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Al Hassan Ag Abdoul Aziz Ag Mohamed Ag Mahmoud* សេច ក្តីសម្រេចរបស់ចៅក្រមពេញអង្គលើបណ្តឹងជំទាស់ចិត្តរបស់មេធាវីការពារក្តីចំពោះចៅក្រមនៃអង្គបុរេជំនុំជម្រះទី I សំណុំរឿង ICC-01/12-01/18-458-AnxI-Red ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ កថាខណ្ឌ ៣០ (ដែលចៅក្រមភាគច្រើនអនុញ្ញាត "ការវាយតម្លៃ ពិសេសមួយ" លើអង្គសេចក្តីនៃសំណើសុំ ទោះបីជាសំណើសុំត្រូវបានរកឃើញថាពុំបានដាក់ទាន់ពេលវេលាក៏ដោយ)។ សាលាក្តី ពិសេសសម្រាប់ប្រទេសលីបង់ *ក្នុងរឿងក្តី El Sayed* សំណុំរឿងលេខ CH/PRES/2010108 សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្ត របស់លោក El Sayed ចំពោះចៅក្រម Riachy នៃអង្គជំនុំជម្រះតុលាការកំពូល អនុលោមតាមវិធាន ២៥ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ ២០១០ កថាខណ្ឌ ៣៦ ("ផលប្រយោជន៍នៃយុត្តិធម៌តម្រូវថា នៅក្នុងកិច្ចដំណើរការនីតិវិធី បុគ្គលគ្រប់រូបពាក់ព័ន្ធត្រូវមានសិទ្ធិតវ៉ា លើអនាគតិ ឬ ឯករាជ្យរបស់ចៅក្រម ហើយតុលាការត្រូវបង្ហាញការជឿជាក់លើការតវ៉ាបែបនោះ")។ សំណុំរឿង ០០២ សេចក្តី សម្រេចលើសំណើរបស់ អៀង សារី សុំឱ្យមានការស៊ើបអង្កេត អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ទៅលើសកម្មភាពនានា ពាក់ព័ន្ធនឹងការប្រាស្រ័យទាក់ទងជាមួយភាគីតែម្ខាងរបស់បណ្ឌិត Craig Etcheson នៃការិយាល័យសហព្រះរាជអាជ្ញា ជាមួយ សមាសភាពអន្តរជាតិនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០ ឯកសារលេខ ៣ កថាខណ្ឌ ១២

ដែលចែងថា 'ការជំនុំជម្រះក្តីត្រូវប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ" និង 'ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនជាប់ចោទ" និងស្របជាមួយនឹងមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR") ដែល 'អាចអនុវត្តបាននៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ... ការពិចារណាសំខាន់ជាងគេនៅក្នុងគ្រប់កិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញគឺជាភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីដូចមានចែងនៅក្នុងវិធាន ២១ (១)(ក) នៃវិធានផ្ទៃក្នុង'"[89]។

៣៤. ផ្ទុយពីទឡ្ហីករណ៍របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី [90] បណ្តឹងជំទាស់ដែលលើកឡើងបញ្ហាធ្ងន់ធ្ងរនៃភាពយុត្តិធម៌ ពោលគឺ ការចោទប្រកាន់អំពីភាពលម្អៀងរបស់ចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូល ដែលនឹងត្រូវបើកសវនាការលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/២ នាពេលខាងមុខ[91]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសសង្កេតឃើញថា សាលដីកាសំណុំរឿង ០០២/២ នឹងជាការកំណត់ការបញ្ចប់កិច្ចដំណើរការនីតិវិធីរយៈពេល ១០ឆ្នាំ ប្រឆាំងនឹង ខៀវ សំផន ហើយអង្គជំនុំជម្រះតុលាការកំពូលគឺជាដំណាក់កាលចុងក្រោយ ដែលភាគីបានប្តឹងលើការផ្តន្ទាទោស និងការកំណត់ទោស[92]។

("អង្គបុរេជំនុំជម្រះយល់ឃើញថា ដើម្បីដោះស្រាយករណីពិសេសបែបនេះដូចបានលើកឡើងនៅក្នុងសំណើសុំ វាជាផលប្រយោជន៍នៃយុត្តិធម៌ដែលត្រូវសម្រេចទៅលើសំណើសុំនោះ ដែលបានដាក់យ៉ាងត្រឹមត្រូវនៅចំពោះមុខអង្គបុរេជំនុំជម្រះ។ ក្នុងការធ្វើសេចក្តីសម្រេចបែបនេះ គេពុំអាចយល់ឃើញថាជាទំនាស់ លទ្ធភាពនៃភាពលម្អៀង ឬសេចក្តីអាម៉ាស់ ឡើយ")។

[89] សំណុំរឿង ០០២ (អ.ប.ជ ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/1/30 ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ កថាខណ្ឌ ៤៩ *ដកស្រង់* សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលបដិសេធសំណើសុំផ្អាកកិច្ចដំណើរការនីតិវិធីដោយមូលហេតុរំលោភនីតិវិធី (ឯកសារ D264/1) ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ ឯកសារ D264/2/6 កថាខណ្ឌ ១៣-១៤។

[90] ចម្លើយតបរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (៦) កថាខណ្ឌ ៥១-៥៣។

[91] បណ្តឹងជំទាស់របស់ ខៀវ សំផន (១) កថាខណ្ឌ ៤១-១០៩។

[92] *កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ* ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ *បានចូលជាធរមាន* នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ("កិច្ចព្រមព្រៀង អ.វ.ត.ក") មាត្រា ៣(២)(ខ)។ *ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់កាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ* ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ នស/រកម/១០០៤/០០៦ ដែលបានវិសោធនកម្មនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ("ច្បាប់ អ.វ.ត.ក") មាត្រា ៣៦។ វិធាន ១០៤។

៣៥. ក្រុមប្រឹក្សាជំនុំជម្រះពិសេសកត់សម្គាល់ឃើញថា មានការព្រួយបារម្ភផ្នែកអង្គច្បាប់ថាតើបណ្តឹងដិតចិត្តបានបំពេញលក្ខខណ្ឌដូចមានចែងនៅក្នុងវិធាន ៣៤(៣) និង (៤)(ឃ) ដែលពុំកំណត់ជាក់លាក់លើរយៈពេលនៃការដាក់បណ្តឹងដិតចិត្ត ហើយតម្រូវឲ្យអនុវត្តវិធីសាស្ត្រតាមករណីនីមួយៗ។

៣៦. ក្នុងន័យនេះ ក្រុមប្រឹក្សាជំនុំជម្រះពិសេសសូមរំលឹកលក្ខណៈពិសេសនៃដីកាបំបែកកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន ដែលក្នុងនោះដីកាបញ្ជូនរឿងទៅជំនុំជម្រះតែមួយត្រូវបានបំបែកចេញជារឿងក្តីចំនួនពីរពាក់ព័ន្ធនឹងជនជាប់ចោទតែមួយ ប៉ុន្តែមានសារតារអង្គហេតុជាន់គ្នា។ អង្គជំនុំជម្រះតុលាការកំពូលធ្លាប់បង្ហាញការព្រួយបារម្ភអំពីភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីក្រោយពេលបំបែកកិច្ចដំណើរការនីតិវិធី រួមទាំង អនាគតិនៃចៅក្រម[93] ប៉ុន្តែ ចុងក្រោយ បានតម្កល់ចំណុចនេះ ដោយមានការបញ្ជាក់បំភ្លឺច្បាស់លាស់[94]។ ផលប្រយោជន៍ចាំបាច់ដែលត្រូវធានាយុត្តិធម៌ប្រកបដោយអត្ថន័យតាមរយៈការទទួលបានការសម្រេចមួយនៅក្នុងអាយុកាលរស់នៅរបស់ជនជាប់ចោទ ត្រូវយកមកពិចារណាឲ្យបានត្រឹមត្រូវ[95]។

៣៧. ការបំបែកកិច្ចដំណើរការនីតិវិធីត្រូវសហមេធាវីបានតវ៉ានៅចំពោះមុខក្រុមប្រឹក្សាជំនុំជម្រះពិសេសរបស់អង្គជំនុំជម្រះសាលាដំបូង[96] ក៏ប៉ុន្តែ ការតវ៉ានៅក្នុងរឿងក្តីបច្ចុប្បន្ន បានសំអាងលើសាលដីកាលើសំណុំរឿង ០០២/១ ដែលត្រូវបានប្រកាសក្រោយក្រុមប្រឹក្សាជំនុំជម្រះពិសេសនៃអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេច [97] ហើយបានតវ៉ានៅក្នុងបរិបទខុសៗគ្នានៃកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ។ ហេតុដូច្នេះ តាមលក្ខណៈជាក់ស្តែង វាមិនដូចគ្នាទាំងស្រុងជាមួយនឹងអ្វីដែលអង្គជំនុំជម្រះពិសេស នៃអង្គជំនុំ

[93] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងការបំបែកកិច្ចដំណើរការនីតិវិធីលើកទី២ (ឯកសារ E284/4/8) កថាខណ្ឌ ៣៩។

[94] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងការបំបែកកិច្ចដំណើរការនីតិវិធីលើកទី៣ (ឯកសារ E301/9/1/1/3) កថាខណ្ឌ ៨៨។

[95] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងការបំបែកកិច្ចដំណើរការនីតិវិធីលើកទី៣ (ឯកសារ E301/9/1/1/3) កថាខណ្ឌ ៥៤។ *សូមមើលផងដែរ* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងការបំបែកកិច្ចដំណើរការនីតិវិធីលើកទី២ (ឯកសារ E284/4/8)។ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងការបំបែកកិច្ចដំណើរការនីតិវិធីលើកទី១ (ឯកសារ E163/5/1/13)។

[96] សំណុំរឿង ០០២ សំណើសុំរបស់ ខៀវ សំផន (ឯកសារ E314/1)។ សំណុំរឿង ០០២ បណ្តឹងដិតចិត្តរបស់ នួន ជា (ឯកសារ E314/6)។ សំណុំរឿង ០០២ បណ្តឹងដិតចិត្តសាជាថ្មីប្រឆាំងនឹងសមាសភាពចៅក្រមបច្ចុប្បន្ននៃអង្គជំនុំជម្រះសាលាដំបូង ដែល ត្រូវសម្រេចលើសំណុំរឿង ០០២/២ ចុះថ្ងៃទី១០ ខែតុលាឆ្នាំ២០១៤ ឯកសារ E314/8។

[97] សំណុំរឿង ០០២ សំអាងហេតុនៃបណ្តឹងដិតចិត្ត ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ ឯកសារ E314/12/1។

ជម្រះសាលាដំបូងបានសម្រេចរួចហើយ ដូចសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានចោទប្រកាន់នោះឡើយ[98]។

៣៨. ក្រុមប្រឹក្សាជំនុំជម្រះពិសេសពិចារណាឃើញថា ការថ្លឹងថ្លែងប្រកបដោយយុត្តិធម៌ត្រូវធ្វើឡើងរវាងផលប្រយោជន៍ផ្លូវច្បាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី និងការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃសិទ្ធិរបស់ជនជាប់ចោទក្នុងការប្តឹងឧទ្ធរណ៍ ជាពិសេស ដោយពិចារណាលើអ្វីដែលកំពុងប៉ះពាល់ដល់ជនជាប់ចោទក្នុងកិច្ចដំណើរការនីតិវិធីនេះ។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសសង្កេតឃើញថា ប្រសិនបើបណ្តឹងជំទាស់បញ្ញត្តិត្រូវបានសម្រេចទទួលយកលើទម្រង់ច្បាប់ ហើយបញ្ហាចោទពាក់ព័ន្ធនឹងការចោទប្រកាន់អំពីភាពលម្អៀងរបស់ចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូល ដែលត្រូវបើកសវនាការលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/២[99] មិនត្រូវបានយកមកដោះស្រាយ នៅពេលនោះភាពយុត្តិធម៌ទាំងមូលនៃកិច្ចដំណើរការនីតិវិធីប្រឆាំងនឹង ខៀវ សំផន អាចរងនូវផលប៉ះពាល់។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសជឿជាក់ថា នៅពេលពិចារណាលើផលប្រយោជន៍ស្របច្បាប់ជារួម វាមានសារសំខាន់ស្មើគ្នាសម្រាប់គ្រប់ភាគីទាំងអស់ និងសម្រាប់កេរ្តិ៍ដំណែលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

៣៩. យោងតាមហេតុផលខាងលើ ក្រុមប្រឹក្សាជំនុំជម្រះពិសេសយល់ឃើញថាមានហេតុផលសមស្របក្នុងការទទួលយកមូលដ្ឋានទី១ និងទី២ ដើម្បីយកមកសម្រេចលើអង្គសេចក្តី។

## ២. មូលដ្ឋានទី៣ អាចទទួលយកបាន

៤០. ក្រុមប្រឹក្សាជំនុំជម្រះពិសេសយល់ឃើញថា មូលដ្ឋានទី៣ ពោលគឺទឡ្ហីករណ៍ចំពោះការសម្រេចតម្កល់លើភាពលម្អៀងចាប់តាំងពីការប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/២[100] អាចទទួលយកបានដោយសារវាបំពេញលក្ខខណ្ឌស្របតាមវិធាន ៣៤(៣) និង ៣៤(៤)(ឃ)។

---

[98] ចម្លើយតបរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (៦) កថាខណ្ឌ ៥១-៥៣។

[99] បណ្តឹងជំទាស់បញ្ញត្តិរបស់ ខៀវ សំផន (១) កថាខណ្ឌ ៤១-១០៩។

[100] ឯកសារ E463/1/3 បណ្តឹងជំទាស់បញ្ញត្តិរបស់ ខៀវ សំផន (១) កថាខណ្ឌ ១១០។

៤១. មូលដ្ឋានទី៣ ចោទប្រកាន់អំពីអនីយ័តភាពផ្នែកនីតិវិធីចាប់តាំងពីការប្រកាសសម្រង់សាលក្រមលើសំណុំរឿង ០០២/២ ជាពិសេស សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលកាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ និងថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩[101]។

៤២. យោងតាមបរិបទ ក្រុមប្រឹក្សាជំនុំជម្រះពិសេសសង្កេតឃើញលក្ខណៈនៃបរិបទប្រទាក់ក្រឡាគ្នានៃសេចក្តីសម្រេចចំនួន ០២ របស់អង្គជំនុំជម្រះតុលាការកំពូល[102] និងពិចារណាឃើញថាសមស្របក្នុងការចាត់ទុកកាលបរិច្ឆេទនៃសេចក្តីសម្រេចលើសំណើសុំមោឃភាពចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ គឺជាកាលបរិច្ឆេទ ដែលសហមេធាវីបានដឹងអំពីមូលដ្ឋាននៃបណ្តឹងជំទាស់ដូចបានចោទប្រកាន់។

៤៣. ក្រុមប្រឹក្សាជំនុំជម្រះពិសេសកត់សម្គាល់ឃើញថា ចាប់តាំងពីពេលដែលកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខបានចាប់ផ្តើមនៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ហើយសហមេធាវីត្រូវបានជូនដំណឹងអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលទៅលើសំណើសុំមោឃភាពចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ មូលដ្ឋានទី៣ គឺជាបញ្ហា "ដែលភាគី *មិនបានដឹងនៅមុនពេល*ចាប់ផ្តើមនីតិវិធីបណ្តឹងសាទុក្ខ"[103]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសពិចារណាឃើញថា រយៈពេល ០២ខែ នៅចន្លោះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ និងការដាក់បណ្តឹងជំទាស់ ពុំមែនជាការពន្យារពេលដោយមិនសមហេតុផលនោះឡើយ ដោយសារសហមេធាវីការពារក្តីត្រូវរៀបចំ និងដាក់មូលដ្ឋានទី៣ នៃបណ្តឹងជំទាស់ ដោយសារវាមានរយៈពេលខ្លី ហើយដោយពិនិត្យលើភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីជារួម។ អាស្រ័យហេតុនេះ មូលដ្ឋានទី៣ អាចទទួលយកបាន។

---

[101] សំណុំរឿង ០០២/២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងការប្រកាសសេចក្តីសម្រេចសង្ខេបនៃសាលក្រមដែលបានធ្វើឡើងនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ឯកសារ E463/1/3។ សំណុំរឿង ០០២/២ សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំធ្វើមោឃភាពសេចក្តីសម្រេចលេខ E463/1/3 បណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ ឯកសារ E463/1/5។

[102] សេចក្តីសម្រេចលើបណ្តឹងជំទាស់របស់ ខៀវ សំផន (ឯកសារលេខ ៧) កថាខណ្ឌ ២០ ("ភាគីអាចបង្ហាញភ័ស្តុតាងខុសគ្នាស្រឡះពីមុន ដែលផ្អែកតាមបរិបទពាក់ព័ន្ធជាលើកដំបូង ដោយសារលទ្ធផលនៃហេតុការណ៍ថ្មីៗ")។

[103] វិធាន ៣៤(៤)(ឃ)។ ការគូសបញ្ជាក់បន្ថែម។

## IV. អង្គសេចក្តី

### ក. មូលដ្ឋានទី១÷ អត្ថិភាពនៃភាពលម្អៀងនៃការសម្រេចសេចក្តីជាមុនទៅលើបណ្តឹងសាទុក្ខក្នុង សំណុំរឿង០០២/២

#### ១. សារណា

៤៤. សហមេធាវីបានលើកឡើងថា សាលដីកាសំណុំរឿង០០២/១ "សម្រេចជាមុនលើបណ្តឹងសាទុក្ខ លើសំណុំរឿង០០២/០១ ដែលជារឿងមិនអាចទទួលយកបាន" ដោយដកស្រង់ "យុត្តិសាស្ត្រពាក់ព័ន្ធ" របស់ អ.វ.ត.ក តុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការសិទ្ធិមនុស្សអឺរ៉ុប [104] ។ សហមេធាវីបានពឹងផ្អែកជា បន្ថែមទៀតលើ "យុត្តិសាស្ត្រពាក់ព័ន្ធ" ដើម្បីកំណត់អំពីភាពលម្អៀង ដោយផ្អែកលើបុរេវិនិច្ឆ័យចំពោះពិរុទ្ធ ភាពរបស់ជនជាប់ចោទ [105] និងយោងទៅរក "សំអាងហេតុដែលគួរឱ្យជឿជាក់" ដែលតាមទស្សនៈរបស់ ពួកគាត់ គឺចាំបាច់ត្រូវតែប្តឹងជំទាស់ពិតប្រាកដ[106]។

#### ក. យុត្តិសាស្ត្រពាក់ព័ន្ធ

៤៥. សហមេធាវីបានជំទាស់ចំពោះ សេចក្តីសម្រេចបដិសេធកន្លងមក របស់ក្រុមប្រឹក្សាជំនុំជម្រះ ពិសេស នៃអង្គជំនុំជម្រះសាលាដំបូង ចំពោះសំណើសុំប្តឹងជំទាស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុង សំណុំរឿង០០២/២ ដោយលើកទឡ្ហីករណ៍ថា លក្ខណៈវិនិច្ឆ័យ ដែលបានអនុម័ត និងអនុវត្តដោយមតិភាគ ច្រើនលើសលប់ "ថាតើការរកឃើញទាំងនេះ អាចមានផលប៉ះពាល់លើការទទួលខុសត្រូវរបស់ជនជាប់ ចោទ ទាក់ទងនឹងបទចោទ ដែលជាកម្មវត្ថុនៃការជំនុំជម្រះក្តីក្រោយៗទៀត ដែរឬទេ" គឺ "មិនត្រឹមត្រូវ" ផ្អែក តាមមតិជំទាស់មួយផ្នែករបស់ចៅក្រម DOWNING និងយុត្តិសាស្ត្រនាពេលថ្មីៗនេះ របស់តុលាការព្រហ្ម ទណ្ឌអន្តរជាតិ[107]។

---

[104] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ (១) កថាខណ្ឌ ២៤។

[105] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ (១) កថាខណ្ឌ ២៥-៤០។

[106] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ (១) កថាខណ្ឌ ៤១-៧៥។

[107] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ (១) កថាខណ្ឌ ២៥-២៨ *យោងទៅរក* សំណុំរឿង ០០២/២ សេចក្តីសម្រេចលើ សំណើ សុំប្តឹងជំទាស់ (ឯកសារ E314/12/1) កថាខណ្ឌ ៦២, ៧០។

៤៦. ជាដំបូង សហមេធាវីបានកត់សម្គាល់ថា ចៅក្រម DOWNING នៅក្នុងមតិជំទាស់មួយផ្នែករបស់គាត់ បានពិចារណាថា អង្គជំនុំជម្រះសាលាដំបូង "ធ្វើការសម្រេចនៅក្នុងសំណុំរឿង ០០២/០១ [...] លើបញ្ហាសំខាន់ៗមួយចំនួន [...] ដែលអាចមានផលប៉ះពាល់ លើការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល" របស់ ខៀវ សំផន ដែលបង្កើតបានជាមូលដ្ឋាន សម្រាប់ការយល់ឃើញ "ថាមានភាពលម្អៀងពីសំណាក់ ចៅក្រមដែលត្រូវបានប្តឹងជិតចិត្តក្នុងសំណុំរឿង ០០២/២"[108]។

៤៧. ទីពីរ សហមេធាវីបានអះអាងថា កាលៈទេសៈពិសេស នៃសំណុំរឿង០០២/០២ ផ្តល់យុត្តិកម្មសម្រាប់ការប្រុងប្រយ័ត្នកាន់តែខ្ពស់ ធៀបនឹងការអនុវត្តនៅចំពោះមុខតុលាការអន្តរជាតិនានា ដែលបានសម្រេចគាំទ្រដល់ការគោរពតាមយ៉ាងម៉ឺងម៉ាត់ចំពោះគោលការណ៍អនាគតិរបស់ចៅក្រម [109] ។ បើតាមសហមេធាវី សេចក្តីសម្រេចលើបណ្តឹងជិតចិត្ត *Mladić* ដែលចៅក្រម ANTONETTI តែមួយរូបដែលត្រូវបានចាត់តាំងឲ្យបំពេញមុខងារ នៅយន្តការអន្តរជាតិសេសសល់របស់តុលាការឧក្រិដ្ឋកម្ម ("IRMCT") បានឯកភាពតាមសំណើសុំប្តឹងជិតចិត្តចៅក្រម ដែលត្រូវបានជំទាស់ដោយជនជាប់ចោទ គឺជាការសម្រេចមួយ "ស្រដៀងគ្នាបំផុត នឹងស្ថានភាពបច្ចុប្បន្ន" [110] ។ សហមេធាវីបានអះអាងបន្ថែមថា ចៅក្រម ANTONETTI បានសម្រេចថា ទោះបីជាការយោងដាក់បន្ទុក ចំពោះជនជាប់ចោទនៅក្នុងសាលដីកាមួយផ្សេងទៀត មិនអាចចាត់ទុកដោយផ្ទាល់ ថាជាការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្តី ក៏ការរួមផ្សំបញ្ចូលគ្នាទាំងនេះ អាចបង្កើតបានជា "ការយល់ឃើញថាមានបុរេវិនិច្ឆ័យ"[111]។ សហមេធាវីអះអាងថា សេចក្តីសម្រេចនេះ "ទទួលស្គាល់ដោយចំហរ នូវគ្រោះថ្នាក់នៃការចូលរួមរបស់ចៅក្រម ក្នុងការជំនុំជម្រះក្តីច្រើនពាក់ព័ន្ធគ្នា និងបង្ហាញអំពីការបញ្ចប់ការអនុវត្ត ប្រថុយប្រថានទាក់ទិននឹងភាពអនាគតិ"[112]។

---

[108] សំណើរបស់ ខៀវ សំផន ប្តឹងជិតចិត្ត (១) កថាខណ្ឌ ២៦ *យោងទៅរក* សំអាងហេតុសម្រាប់សេចក្តីសម្រេចលើ សំណើសុំប្តឹងជិតចិត្ត (ឯកសារ E314/12/1) មតិជំទាស់ដោយផ្នែករបស់ចៅក្រម DOWNING ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ ("មតិជំទាស់ដោយផ្នែករបស់ចៅក្រម DOWNING (ឯកសារ E314/12/1)") កថាខណ្ឌ ១, ២៣។

[109] សំណើរបស់ ខៀវ សំផន ប្តឹងជិតចិត្ត (១) កថាខណ្ឌ ២៩។

[110] សំណើរបស់ ខៀវ សំផន ប្តឹងជិតចិត្ត (១) កថាខណ្ឌ ៣០ *យោងទៅរក*តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង Mladić* សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ប្តឹងជិតចិត្តចៅក្រម Theodor Meron, Carmel Agius និង Liu Daqun MICT-13-56-A ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៨ ("សេចក្តីសម្រេចលើបណ្តឹងជិតចិត្ត Mladić")

[111] សំណើរបស់ ខៀវ សំផន ប្តឹងជិតចិត្ត (១) កថាខណ្ឌ ៣៤ *យោងទៅរក*សេចក្តីសម្រេចលើបណ្តឹងជិតចិត្ត Mladić កថាខណ្ឌ ៤៩។

[112] សំណើរបស់ ខៀវ សំផន ប្តឹងជិតចិត្ត (១) កថាខណ្ឌ ៣៥ *យោងទៅរក*សេចក្តីសម្រេចលើបណ្តឹងជិតចិត្ត Mladić កថាខណ្ឌ

៤៨. ទីបី សហមេធាវីបានអះអាងថា យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប[113] ដែលត្រូវបានបកស្រាយថា "ជាការតម្រូវឱ្យចៅក្រម រងបណ្ដឹងជំទាស់ដោយផ្អែកលើគ្រប់ធាតុផ្សំទាំងអស់ នៃបទល្មើសព្រហ្មទណ្ឌណាមួយ ដើម្បីឈានទៅដល់ការប្ដឹងជំទាស់គាត់" គឺគ្រាន់ "ជាការស្រាយបំភ្លឺ គឺមិនមែនជាលក្ខណៈវិនិច្ឆ័យដាច់ខាត សម្រាប់បង្ហាញអត្ថិភាពនៃការលម្អៀងនោះទេ" ដូចដែលបានបញ្ជាក់យ៉ាងត្រឹមត្រូវដោយចៅក្រម DOWNING និងចៅក្រម ANTONETTI[114]។ ដោយពឹងផ្អែកលើរឿងក្ដីមួយផ្សេងទៀត របស់តុលាការសិទ្ធិមនុស្សអឺរ៉ុប[115] សហមេធាវីបានលើកឡើងថា តុលាការសិទ្ធិមនុស្សអឺរ៉ុប "បានកំណត់លក្ខណៈវិនិច្ឆ័យជាមូលដ្ឋាន សម្រាប់ដោះស្រាយករណីនេះ"[116] ដូចជា "ថាតើបញ្ហាដែលខ្លួនត្រូវដោះស្រាយ ក្នុងបណ្ដឹងសាទុក្ខទីពីរ មានលក្ខណៈស្រដៀងគ្នានឹងបញ្ហាដែលខ្លួនបានដោះស្រាយក្នុងបណ្ដឹងសាទុក្ខទីមួយដែរឬទេ" ដែលដូច្នេះគឺមិនមានមន្ទិលសង្ស័យ អំពីភាពលម្អៀងរបស់ចៅក្រម ដែលរងបណ្ដឹងជំទាស់ ក្នុងករណីបច្ចុប្បន្ននេះឡើយ[117]។

---

៨២-៨៣។

[113] តុលាការសិទ្ធិមនុស្សអឺរ៉ុប ("តុលាការសិទ្ធិមនុស្សអឺរ៉ុប"), *Poppe តទល់នឹង ប្រទេសហូឡង់*, សំណើសុំលេខ 32271/04 សាលក្រម ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ (*"Poppe តទល់នឹង ប្រទេសហូឡង់* (តុលាការសិទ្ធិមនុស្សអឺរ៉ុប)") កថាខណ្ឌ ២៨ ("អង្គហេតុដែលថា សាលក្រមមុនរបស់ចៅក្រម មានសេចក្ដីសម្រេចដែល ពិតជាបុរេវិនិច្ឆ័យ លើបញ្ហានៃពិរុទ្ធភាពរបស់ជនជាប់ចោទ ក្នុងកិច្ចដំណើរការនីតិវិធីបន្តបន្ទាប់ គឺគ្រប់គ្រាន់ក្នុងការនាំឱ្យមានមន្ទិលសង្ស័យ លើអនាគតិរបស់ចៅក្រម")។

[114] សំណើរបស់ ខៀវ សំផន ប្ដឹងជំទាស់ (១) កថាខណ្ឌ ៣៧ *យោងទៅរក* Poppe *តទល់នឹង ប្រទេសហូឡង់* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) កថាខណ្ឌ ២៨, មតិជំទាស់ដោយផ្នែករបស់ចៅក្រម DOWNING (ឯកសារ E314/12/1) កថាខណ្ឌ ១៥-១៦, សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ Mladić កថាខណ្ឌ ២៥។

[115] តុលាការសិទ្ធិមនុស្សអឺរ៉ុប *Mancel និង Branquart* តទល់នឹង *ប្រទេសបារាំង* សំណើសុំលេខ 22349/06 សាលក្រម ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១០ 2010 (*"Mancel និង Branquart* តទល់នឹង *ប្រទេសបារាំង* (តុលាការសិទ្ធិមនុស្សអឺរ៉ុប)") កថាខណ្ឌ ៣៦ ("ការស្ដែងចេញនូវភាពលំអៀង គឺដោយសារតែអង្គហេតុដែលថា ចៅក្រមប្រាំពីររូប ក្នុងចំណោមចៅក្រមជំនុំជម្រះប្រាំបួនរូប នៅក្នុងផ្នែកព្រហ្មទណ្ឌ [នៃតុលាការកំពូល] ដែលនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៥ បានសម្រេចលើបណ្ដឹងសាទុក្ខ ដែលបានដាក់ដោយម្ចាស់បណ្ដឹងសាទុក្ខ ប្រឆាំងសាលក្រមផ្ដន្ទាទោស គឺធ្លាប់ជាចៅក្រមជំនុំជម្រះក្នុងអង្គជំនុំជម្រះ ដែលបានសម្រេចកាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០២ លើបណ្ដឹងសាទុក្ខ ដែលបានដាក់ដោយរដ្ឋអាជ្ញា នៃសាលាឧទ្ធរណ៍ Amiens ប្រឆាំងសេចក្ដីសម្រេចលើកលែងចោទប្រកាន់") (ការបកស្រាយក្រៅផ្លូវការ)។

[116] សំណើរបស់ ខៀវ សំផន ប្ដឹងជំទាស់ (១) កថាខណ្ឌ ៣៨-៣៩ *យោងទៅរក* ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក មាត្រា ៣៦, វិធាន ១០៤ នៃវិធានផ្ទៃក្នុង, សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ Mladić កថាខណ្ឌ ៣១។

[117] សំណើរបស់ ខៀវ សំផន ប្ដឹងជំទាស់ (១) កថាខណ្ឌ ៣៩-៤០ *យោងទៅរក* Mancel *និង* Branquart តទល់នឹង *ប្រទេស*

៤៩. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាបានលើកឡើងថា សហមេធាវីបំផ្លើសហួសហេតុ នូវអានុភាពនៃយុត្តិសាស្ត្រ ដែលពួកគេពឹងផ្អែកលើ ហើយសហមេធាវីមិនបានបង្ហាញថា ការអនុវត្តច្បាប់នេះគឺតម្រូវឱ្យដិតចិត្តចៅក្រម ដែលរងបណ្តឹងនោះឡើយ[118]។ ជាដំបូង សហព្រះរាជអាជ្ញាអះអាងថា សហមេធាវីពឹងផ្អែកដោយខុសទៅលើ មតិជំទាស់មួយផ្នែករបស់ចៅក្រម DOWNING ដែលផ្ទុយពីសេចក្តីសម្រេចដោយសម្លេងភាគច្រើនលើសលប់ របស់ក្រុមប្រឹក្សាជំនុំជម្រះពិសេសកន្លងមករបស់អង្គជំនុំជម្រះសាលាដំបូង ដែលសម្រេចបដិសេធសំណើសុំ ប្តឹងដិតចិត្តចៅក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០២ ហើយថាក្រៅពីបង្ហាញពីភាពផ្ទុយគ្នា រវាងមតិរបស់ចៅក្រម DOWNING និងមតិរបស់ចៅក្រមភាគច្រើនលើសលប់នោះ សហមេធាវីគ្រាន់តែអះអាងថា ក្រុមប្រឹក្សាជំនុំជម្រះពិសេស មានកំហុសឆ្គងក្នុងការបដិសេធ ដោយផ្អែកលើយុត្តិសាស្ត្រនាពេលថ្មីៗនេះ[119]។

៥០. ទីពីរ សហព្រះរាជអាជ្ញាបានលើកទឡ្ហីករណ៍ថា សេចក្តីសម្រេចលើបណ្តឹងដិតចិត្ត *Mladić* ដែលសហមេធាវីបានយោង គឺងាកចេញយ៉ាងខ្លាំងពីបទដ្ឋាន ដែលបានកំណត់យ៉ាងច្បាស់លាស់ ដែលផ្តល់នូវសច្ចាធារណ៍ នៃអនាគតិយ៉ាងរឹងមាំសម្រាប់ចៅក្រម នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលដូច្នេះហើយទាមទារឱ្យមានលក្ខខណ្ឌតម្រូវ នៃភស្តុតាងដ៏ខ្ពស់បំផុត ដើម្បីកំណត់ថាចៅក្រមណាម្នាក់ពិតជាមានការលំអៀង ឬដែលនាំឱ្យគេយល់ឃើញ អំពីភាពលំអៀងដែលកើតឡើង ចេញពីខាងចៅក្រមនោះ[120]។ សហ

---

*បារាំង* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) កថាខណ្ឌ ៣៧។

[118] ចម្លើយតបរបស់ សហព្រះរាជអាជ្ញា (៥) កថាខណ្ឌ ១៣,២១។

[119] ចម្លើយតបរបស់ សហព្រះរាជអាជ្ញា (៥) កថាខណ្ឌ ១៤ *យោងទៅរក*សំណុំរឿង ០០២/២ សេចក្តីសម្រេចលើ សំណើសុំប្តឹងដិតចិត្ត (ឯកសារ E314/12/1) កថាខណ្ឌ ៥។

[120] ចម្លើយតបរបស់ សហព្រះរាជអាជ្ញា (៥) កថាខណ្ឌ ១៥-១៦ *យោងទៅរក* សំណុំរឿង០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ ០១) សេចក្តីសម្រេចជាសាធារណៈ ស្តីពីបណ្តឹងដិតចិត្តជាបន្ទាន់ របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ ឯកសារ C11/29 (“សេចក្តីសម្រេចលើបណ្តឹងដិតចិត្តបន្ទាន់ របស់សហមេធាវី (ឯកសារ C11/29)”) កថាខណ្ឌ ១៩, សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ នួន ជា និង អៀង សារី ដែលប្តឹងដិតចិត្តចំពោះលោកចៅក្រម និល ណុន ចៅក្រម Silvia Cartwright ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc Lavergne និងចៅក្រម ធូ មណី ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១១ ឯកសារ E55/4 (“សេចក្តីសម្រេចលើ សំណើសុំប្តឹងដិតចិត្ត(ឯកសារ E55/4)”) កថាខណ្ឌ ១២, ១៥ តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹងDelalić* និងអ្នកដទៃទៀត IT-96-21-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូលអង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ (“*Delalić និងអ្នកដទៃទៀត* សាលដីកា (តុលាការ ICTY)”) កថាខណ្ឌ ៧០៧ តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹងŠainović* និងអ្នកដទៃទៀត IT-05-87-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ កថាខណ្ឌ ១៨១ តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង Galić* IT-98-29-A, សាលក្រម អង្គជំនុំជម្រះ

ព្រះរាជអាជ្ញាបានអះអាងបន្ថែមថា សេចក្តីសម្រេចលើបណ្តឹងជំទាស់ *Mladić* ត្រូវបានជំទាស់ជាបន្តបន្ទាប់ដោយមតិប្រឆាំងដោយផ្ទាល់ របស់ចៅក្រមដទៃទៀត [121] ដូច្នេះហើយការណ៍នេះមិនមែនជាយុត្តិសាស្ត្រដ៏រឹងមាំនោះទេ[122]។

៥១. ទីបី ការយោងទៅរកយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប គឺសហព្រះរាជអាជ្ញាបានជំទាស់ថា ផ្ទុយពីចេតនារបស់សហមេធាវី ក្នុងការគេចវេសពីពាក្យពេចន៍សាមញ្ញនៃរឿងក្តី *Poppe តទល់នឹងប្រទេសហូឡង់* ដោយអះអាងថាចៅក្រម ANTONETTI និងចៅក្រម DOWNING បានបញ្ជាក់យ៉ាងត្រឹមត្រូវថា លក្ខណៈវិនិច្ឆ័យលើ "គ្រប់ធាតុផ្សំទាំងអស់ នៃបទល្មើសព្រហ្មទណ្ឌណាមួយ" ជាការស្រាយបំភ្លឺ

---

តុលាការកំពូល ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៦ ("សាលដីការឿងក្តី *Galić* (តុលាការ ICTY)") កថាខណ្ឌ ៤១, ៤៤ តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង*Mladić IT-09-92-T សេចក្តីសម្រេចលើសំណើរបស់ មេធាវីការពារក្តី សុំប្តឹងជំទាស់ចៅក្រម Alphons Orie និងចៅក្រម Christoph Flügge ប្រធានអង្គជំនុំជម្រះ ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៦ ("សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម Orie និង Flügge ក្នុងរឿងក្តី Mladić (តុលាការ ICTY)") ទំព័រ ៣ ជើងទំព័រ 14 ដកស្រង់តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹងStanišić and Župljanin* IT-08-91-A សាលក្រម អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ កថាខណ្ឌ ៤៤ តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹងŠešelj* IT-03-67-R77.3 សេចក្តីសម្រេចលើញត្តិរបស់សាស្ត្រាចារ្យ Vojislav Šešelj ប្តឹងជំទាស់ចៅក្រម O-Gon Kwon និង Kevin Parker អង្គជំនុំជម្រះពិសេស ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០ ("សេចក្តីសម្រេចរឿងក្តី *Šešelj* (តុលាការ ICTY)") កថាខណ្ឌ ២៨ ដកស្រង់តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹងBrđanin និង Talić* IT-99-36-T សេចក្តីសម្រេចលើសំណើរបស់ Momir Talić ប្តឹងជំទាស់និងដកចេញនូវចៅក្រមមួយរូប អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០០ ("សេចក្តីសម្រេចលើរឿងក្តី *Brđanin and Talić (*តុលាការ *ICTY)*") កថាខណ្ឌ ១៨ តុលាការ ICTR *រដ្ឋអាជ្ញា តទល់នឹងNtawukulilyayo* ICTR-05-82-A សេចក្តីសម្រេចលើញត្តិប្តឹងជំទាស់ចៅក្រម អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១១ 2011 ("សេចក្តីសម្រេចលើរឿងក្តី Ntawukulilyayo (តុលាការ ICTR)") កថាខណ្ឌ ៧, ១២, ១៣ តុលាការ ICTR, *រដ្ឋអាជ្ញា តទល់នឹង Nahimana* និងអ្នកដទៃទៀត ICTR-99-52-A សាលក្រម អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧ ("សាលដីកា *Nahimana និងអ្នកដទៃទៀត* (តុលាការ ICTR)") កថាខណ្ឌ ៤៨-៥០, ៧៨ តុលាការ ICTR *រដ្ឋអាជ្ញា តទល់នឹង Renzaho*, ICTR-97-31-A សាលក្រម អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី១ ខែមេសា ឆ្នាំ២០១១ ("សាលដីកា *Renzaho* (តុលាការ ICTR)") កថាខណ្ឌ ២២-២៣ តុលាការ ICTR *រដ្ឋអាជ្ញា តទល់នឹងKarera* ICTR-01-74-A សាលក្រម អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០០៩ ("សាលដីកា *Karera* (តុលាការ ICTR)") កថាខណ្ឌ ៣៧៨ តុលាការ ICTR *រដ្ឋអាជ្ញា តទល់នឹង Akayesu* ICTR-96-4-A សាលក្រម អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០១ ("សាលដីកា *Akayesu* (តុលាការ ICTR)") កថាខណ្ឌ ២៦៩។

[121] ចម្លើយតបរបស់ សហព្រះរាជអាជ្ញា (៥) កថាខណ្ឌ ១៧ *យោងទៅរក* តុលាការ MICT *រដ្ឋអាជ្ញា តទល់នឹង Karadzić* MICT-13-55-A សេចក្តីសម្រេច ចៅក្រមប្រធាន Theodor Meron ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨

[122] ចម្លើយតបរបស់ សហព្រះរាជអាជ្ញា (៥) កថាខណ្ឌ ១៧។

ប៉ុន្តែតាមការពិតលក្ខណៈវិនិច្ឆ័យ ត្រូវបានចាត់ទុកជាលក្ខណៈវិនិច្ឆ័យដាច់ខាត ក្នុងករណីជាច្រើន [123] ។ សហព្រះរាជអាជ្ញាបានបន្ថែមថា យុត្តិសាស្ត្ររឹងមាំនៃរឿងក្តី *Mancel និង Branquart* ដែលពាក់ព័ន្ធនឹងបញ្ហាតែមួយ សម្រាប់បទល្មើសតែមួយនៅក្នុងរឿងក្តីតែមួយនោះ គឺអាចញែកចេញពីគ្នាបាន ព្រោះចៅក្រមដែលរងបណ្តឹង នៅក្នុងករណីបច្ចុប្បន្ននេះ ចាំបាច់ត្រូវត្រួតពិនិត្យលើការសម្រេច លើអង្គហេតុនិងអង្គច្បាប់ថ្មី ដែលសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០២/០២ ដែលពាក់ព័ន្ធនឹងបទឧក្រិដ្ឋផ្សេង ទីតាំងឧក្រិដ្ឋកម្មផ្សេង និងបណ្តុំនៃភស្តុតាងថ្មីៗយ៉ាងច្រើន ដែលទាំងអស់នេះមិនត្រូវបានពិចារណា នៅក្នុងសំណុំរឿង ០០២/០១ ទេ[124]។

## ខ. សំអាងហេតុសម្រាប់បណ្តឹងជំទាស់ចិត្ត

៥២. សហមេធាវីបានលើកឡើងថា បណ្តឹងជំទាស់ចិត្តជាការចាំបាច់ ដោយសារតែ៖ (១) ភាពត្រួតគ្នា នៃការជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២/០១ និង ០០២/០២ បានរំលោភដល់សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការអព្យាក្រឹត (២) សវនាការសំណុំរឿង០០២/០២ ដោយចៅក្រមដែលរងបណ្តឹង នឹងប៉ះពាល់ដល់

---

[123] ចម្លើយតបរបស់ សហព្រះរាជអាជ្ញា (៥) កថាខណ្ឌ ១៨ *យោងទៅរក*តុលាការសិទ្ធិមនុស្សអឺរ៉ុប *Schwarzenberger* តទល់នឹង *Germany* សំណើសុំលេខ 75737/01 សាលក្រម ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៦ ("*Schwarzenberger* តទល់នឹង *Germany* (តុលាការសិទ្ធិមនុស្សអឺរ៉ុប)") កថាខណ្ឌ ៤៣ តុលាការសិទ្ធិមនុស្សអឺរ៉ុប *Miminoshvili* តទល់នឹង *Russia* សំណើសុំលេខ 20197/03សាលក្រម ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ ("*Miminoshvili* តទល់នឹង *Russia* (តុលាការសិទ្ធិមនុស្សអឺរ៉ុប)") កថាខណ្ឌ ១១៨ សេចក្តីសម្រេចលើ សំណើសុំប្តឹងជំទាស់ចិត្ត (ឯកសារ E55/4) កថាខណ្ឌ ២១ សំណុំរឿង ០០២/២ សេចក្តីសម្រេចលើ សំណើសុំប្តឹងជំទាស់ចិត្ត (ឯកសារ E314/12/1) កថាខណ្ឌ ៣៨-៤៤, ៩៤ សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តចៅក្រម Orie និង Flügge ក្នុងរឿងក្តី Mladić (តុលាការ ICTY) ឧបសម្ព័ន្ធ ខ៖ អនុស្សរណៈផ្ទៃក្នុង ពីចៅក្រមប្រធាន Alphonse Orie ជូនចំពោះលោកប្រធាន Theodor Meron ដែលមានចំណងជើងថា "របាយការណ៍អនុលោមតាម វិធាន ១៥(ខ)" ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១២ កថាខណ្ឌ ៣០, ៣៦-៣៧ សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តចៅក្រម Orie និង Flügge ក្នុងរឿងក្តី Mladić (តុលាការ ICTY) ឧបសម្ព័ន្ធ ក៖ អនុស្សរណៈផ្ទៃក្នុង ពីចៅក្រម Christoph Flügge ជូនចំពោះចៅក្រមប្រធាន Alphons Orie ដែលមានចំណងជើងថា "ការបញ្ជូនញត្តិប្តឹងជំទាស់ចិត្ត អនុលោ
មតាមវិធាន ១៥(ខ)" ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ កថាខណ្ឌ ១៨-១៩, ៣៦-៣៨ សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តចៅក្រម Orie និង Flügge ក្នុងរឿងក្តី Mladić (តុលាការ ICTY) ឧបសម្ព័ន្ធ ខ៖ អនុស្សរណៈផ្ទៃក្នុង ពីចៅក្រមប្រធាន Alphonse Orie ជូនចំពោះលោកប្រធាន Theodor Meron ដែលមានចំណងជើងថា "របាយការណ៍អនុលោមតាម វិធាន ១៥(ខ)" ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ កថាខណ្ឌ ២៩។

[124] ចម្លើយតបរបស់ សហព្រះរាជអាជ្ញា (៥) កថាខណ្ឌ ២០ *យោងទៅរក* *Mancel and Branquart* តទល់នឹង *ប្រទេសបារាំង* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) កថាខណ្ឌ ២១-២២, ២៧-២៨, ៣៩។

សិទ្ធិក្នុងការប្ដឹងសារទុក្ខ (៣) ការសម្រេចក្នុងសាលដីកាសំណុំរឿង ០០២/០១ ជាបុរេវិនិច្ឆ័យលើទំនួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន សម្រាប់បណ្ដឹងសាទុក្ខក្នុងសំណុំរឿង០០២/០២[125]។

៥៣. ទីមួយ សហមេធាវីបានលើកឡើងថា ទោះបីជាការបំបែកកិច្ចដំណើរការនីតិវិធី ត្រូវបានបង្កាប់ឡើងដើម្បីបំបែកសវនាការជំនុំជម្រះបុគ្គលនីមួយៗ ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមានជនជាប់ចោទច្រើនក្ដី តែការបំបែកកិច្ចដំណើរការនីតិវិធី សំណុំរឿង០០២ ដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះមួយត្រូវបានបំបែកទៅជាសវនាការបន្តបន្ទាប់គ្នា ដែលកើតចេញពីសំណុំរឿងតែមួយ ពាក់ព័ន្ធជាមួយជនជាប់ចោទដដែល ត្រូវបានធ្វើឡើងតាមរបៀបថ្មីមិនធ្លាប់មាន និងចម្រូងចម្រាស ហើយបណ្ដាលឲ្យមានការរំលោភបំពាន ទៅលើសិទ្ធិទទួលបានការជំនុំជម្រះ ដោយតុលាការមិនលំអៀង[126]។ សហមេធាវីអះអាងថា ការបំបែកសំណុំរឿង០០២ "ស្ដែងចេញជាគ្រោះថ្នាក់បន្តបន្ទាប់ ដល់សិទ្ធិទទួលបានការជំនុំជម្រះ ប្រកបដោយយុត្តិធម៌" ហើយវិវាទដ៏ធ្ងន់ធ្ងរ ដែលរួតរឹតសំណុំរឿង ០០២/០១ និង០០២/០២ បង្ហាញពីការរំលោភសច្ចធម៌គតិយុត្តិ[127]។ សហមេធាវីបានអះអាងថា អង្គជំនុំជម្រះតុលាការកំពូលខ្លួនឯងផ្ទាល់ បានទទួលស្គាល់ពីលក្ខណៈពិសេស នៃការបំបែកកិច្ចដំណើរការនីតិវិធី ដោយបានផ្ដល់អនុសាសន៍ច្បាស់លាស់ អំពីការបង្កើតក្រុមប្រឹក្សាជំនុំជម្រះមួយផ្សេងទៀត "ដើម្បីដោះស្រាយបញ្ហាលំអៀងជាក់ស្ដែង ឬច្បាស់ក្រឡែត ដែលអាចត្រូវបានលើកឡើង ប្រឆាំងនឹងចៅក្រម" ហើយបន្ទាប់មកបានលើកអំពីបញ្ហា អនាគតនៅក្នុងសេចក្ដីសម្រេចលើកទីពីរ និងលើកទីបី បំបែកកិច្ចដំណើរការនីតិវិធី ប៉ុន្តែ "អង្គជំនុំជម្រះ [សាលាដំបូង] បដិសេធសេចក្ដីសម្រេចនេះ"[128]។ សហមេធាវីអះអាងបន្ថែមទៀតថា "ភាពត្រួតគ្នាដ៏សម្បើមនៃអង្គហេតុ

[125] សំណើរបស់ ខៀវ សំផន ប្ដឹងដិតចិត្ត (១) កថាខណ្ឌ ៤១។

[126] សំណើរបស់ ខៀវ សំផន ប្ដឹងដិតចិត្ត (១) កថាខណ្ឌ ៤២-៤៤។

[127] សំណើរបស់ ខៀវ សំផន ប្ដឹងដិតចិត្ត (១) កថាខណ្ឌ ៤៦ និងជើងទំព័រ ៦៩។

[128] សំណើរបស់ ខៀវ សំផន ប្ដឹងដិតចិត្ត (១) កថាខណ្ឌ ៤៥, ៤៨-៥០*យោងទៅរក* សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ភ្លាមៗ របស់សហព្រះរាជអាជ្ញា ប្រឆាំងសេចក្ដីសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង ទាក់ទងវិសាលភាពនៃសំណុំរឿង ០០២/០១ ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ E163/5/1/13 ("សំណុំរឿង ០០២ សេចក្ដីសម្រេចលើកទីមួយ បំបែកកិច្ចដំណើរការនីតិវិធី (E163/5/1/13)") កថាខណ្ឌ ៥១ សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីរ របស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធី នៃសំណុំរឿង០០២ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ឯកសារ E284/4/8 ("សំណុំរឿង ០០២ សេចក្ដីសម្រេចលើកទីពីរ បំបែកកិច្ចដំណើរការនីតិវិធី (ឯកសារ E284/4/8)") កថាខណ្ឌ ៣៩, ៤៦, ៥០ សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្ដីសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម លើសំណុំរឿង០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ ឯកសារ E301/9/1/1/3 ("សំណុំរឿង ០០២ សេចក្ដីសម្រេចលើកទីបី បំបែកកិច្ចដំណើរ

01648309

និងអង្គច្បាប់" ផ្តល់យុត្តិកម្មដល់បណ្តឹងជំទាស់ចៅក្រមដែលរងបណ្តឹង ដែលគួរតែដកខ្លួនដោយស្ម័គ្រចិត្ត អនុលោមតាមគោលការណ៍ដែលពួកគាត់ បានអនុម័តដោយខ្លួនឯងផ្ទាល់ និងវិធាន ៣៤(១) នៃវិធានផ្ទៃក្នុង[129]។

៥៤. ទីពីរ សហមេធាវីចោទប្រកាន់ថា ដើម្បីធានាពីអនាគតិរបស់ចៅក្រម ដែលត្រូវជំនុំជម្រះក្នុងសាលដីកាសំណុំរឿង០០២/០២ គឺជាការចាំបាច់ ដោយសារតែអង្គជំនុំជម្រះតុលាការកំពូល ចេញសាលដីកាសម្រេចស្ថាពរ ទៅលើទាំងបញ្ហាអង្គហេតុ និងបញ្ហាអង្គច្បាប់ ហើយសាលដីកា "បញ្ចប់កិច្ចដំណើរការនីតិវិធី ប្រឆាំងនឹង ខៀវ សំផន"[130]។ បើតាមទស្សនៈរបស់សហមេធាវី ចៅក្រមដែលរងបណ្តឹង មិនអាចជំនុំជម្រះបណ្តឹងសាទុក្ខ ដោយមិនរំលោភបំពានទៅលើ សិទ្ធិជាសារវន្តក្នុងការទទួលបានការជំនុំជម្រះដោយតុលាការអព្យាក្រឹត សិទ្ធិក្នុងការប្តឹងសាទុក្ខ និងសច្ចធារណ៍នៃនិរទោសឡើយ ដោយសារតែលក្ខណៈដែលចៅក្រម បានសម្រេចសេចក្តីក្នុងសាលដីកា សំណុំរឿង០០២/០១ មិនអាចធ្វើឲ្យម្ចាស់បណ្តឹងសាទុក្ខ អាចប្រើប្រាស់ដោយមានប្រសិទ្ធិភាព នូវសិទ្ធិរបស់គាត់ក្នុងការប្តឹងសាទុក្ខ ក្នុងសំណុំរឿង០០២/០២ ប្រសិនបើចៅក្រមទាំងនោះ មិនត្រូវបានជំនិតចិត្តទេនោះ[131]។

៥៥. ទីបី ដោយយោងទៅរកឧបសម្ព័ន្ធ ដែលរៀបរាប់លម្អិតអំពីវិសាលភាពនៃការជាន់គ្នា សហមេធាវីបានលើកឡើងថា សាលដីកាសំណុំរឿង០០២/០១ បានបុរេវិនិច្ឆ័យ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន ក្នុងបណ្តឹងសាទុក្ខសំណុំរឿង ០០២/០២ ដែលបណ្តឹងនេះពាក់ព័ន្ធទាំងការសម្រេចលើអង្គហេតុ និងលើអង្គច្បាប់ ដែលជាកត្តាកំណត់អំពី ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន ក្នុងសំណុំរឿង០០២/០២[132]។ សហមេធាវីបញ្ជាក់ថា អង្គជំនុំជម្រះតុលាការកំពូល នៅក្នុងសំណុំរឿង ០០២/០១ បានធ្វើការសម្រេចអង្គហេតុលើ (១) អត្ថិភាពនិងគោលបំណងនៃគោលនយោបាយផ្លាស់ទីលំនៅប្រជាជន ដែលដូច្នេះ

---

ការនីតិវិធី (ឯកសារ E301/9/1/1/3)") កថាខណ្ឌ ៥១។

[129] សំណើរបស់ ខៀវ សំផន ប្តឹងជំនិតចិត្ត (១) កថាខណ្ឌ ៥១-៥៥ *យោងទៅរក*មតិជំទាស់ដោយផ្នែករបស់ចៅក្រម DOWNING (ឯកសារ E314/12/1) កថាខណ្ឌ ៣ សំណុំរឿង ០០២ សេចក្តីសម្រេចលើកទីបី បំបែកកិច្ចដំណើរការនីតិវិធី (ឯកសារ E301/9/1/1/3) កថាខណ្ឌ ៤៥។

[130] សំណើរបស់ ខៀវ សំផន ប្តឹងជំនិតចិត្ត (១) កថាខណ្ឌ ៥៦-៥៨។

[131] សំណើរបស់ ខៀវ សំផន ប្តឹងជំនិតចិត្ត (១) កថាខណ្ឌ ៥៨-៥៩។

[132] សំណើរបស់ ខៀវ សំផន ប្តឹងជំនិតចិត្ត (១) កថាខណ្ឌ ៦០-៦១, ៧១, ៧៥។

គឺបុរេវិនិច្ឆ័យបញ្ហានៃអត្ថិភាពរបស់គោលនយោបាយ បង្កើតការដ្ឋាន [133] (២) ការចោទប្រកាន់ពីគោលនយោបាយ កំណត់គោលដៅលើអតីត អ្នករដ្ឋការនិងយោធាសាធារណរដ្ឋខ្មែរ សម្រាប់រយៈពេលដែលពាក់ព័ន្ធជាមួយ សំណុំរឿង០០២/០២ [134] (៣) អត្ថិភាពនៃគោលនយោបាយសម្លាប់ខ្មាំង [135] (៤) ការចោទប្រកាន់ពីការចូលរួមយ៉ាងសំខាន់របស់ ខៀវ សំផន នៅក្នុងសហឧក្រិដ្ឋកម្មរួម[136] និង (៥) ការចោទប្រកាន់ពីការដឹងពុកន្លងមក អំពីឧក្រិដ្ឋកម្ម និងអំពីចេតនារបស់គាត់[137]។ សហមេធាវីបានបន្ថែមថា ការបង្ហាញអំពីទស្សនៈរបស់ចៅក្រម លើសហករណ៍និងការដ្ឋាន "ដោយមិនមានកំណត់ត្រាជើងទំព័រ ឬឯកសារយោងជាក់លាក់ ដើម្បីគាំទ្រការរកឃើញណាមួយ របស់អង្គជំនុំជម្រះ" បង្ហាញ "ភាពលំអៀងជាក់ស្តែង និង/ឬយ៉ាងហោចណាស់ វាអាចជាមូលដ្ឋានស្របច្បាប់ នៃការព្រួយបារម្ភអំពីភាពលំអៀងរបស់ចៅក្រម"[138]។

៥៦. ចំពោះការសម្រេចលើអង្គច្បាប់ សហមេធាវីចោទប្រកាន់ថា ពួកគាត់ព្រួយបារម្ភណ៍បញ្ហា "ចំណុចស្នូលនៃបណ្តឹងឧទ្ធរណ៍ ក្នុងសំណុំរឿង០០២/០២ និងមានឥទ្ធិពលគន្លឹះ លើលទ្ធផលចុងក្រោយនៃសំណុំរឿងនេះ" [139] ដែលរួមមានទាំងការសម្រេច "លើធាតុផ្សំក្នុងបរិបទនៃ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ យុត្តាធិការពេលវេលា ភាពអាចប្រមើលមើលទុកជាមុនបាន និងគោលការណ៍នីត្យានុកូលភាព ធាតុផ្សំអត្តនោម័តនៃមនុស្សឃាត ក្រោមទម្រង់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងក្រោមទម្រង់សហឧក្រិដ្ឋកម្មរួម"[140]។ សហមេធាវីបានអះអាងថា ចៅក្រមដែលរងបណ្តឹង "មិនត្រឹមតែអនុវត្តច្បាប់យុត្តិសាស្ត្រ ដដែលម្តងទៀតនោះតែ ប៉ុន្តែថែមទាំងបានទាញការសន្និដ្ឋានពិស្តារជាច្រើន ដេលប្រាសចាកពីលទ្ធិច្បាប់" ហើយសិទ្ធិក្នុងការប្តឹងសាទុក្ខរបស់ ខៀវ សំផន នឹង "បាត់បង់ទាំងស្រុង" ប្រសិនបើមិនអនុញ្ញាតតាមការប្តឹងជំទាស់

[133] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ (១) កថាខណ្ឌ ៦២-៦៤។

[134] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ (១) កថាខណ្ឌ ៦៥-៦៦។

[135] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ (១) កថាខណ្ឌ ៦៧។

[136] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ (១) កថាខណ្ឌ ៦៨។

[137] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ (១) កថាខណ្ឌ ៦៩។

[138] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ (១) កថាខណ្ឌ ៦២-៦៣ *យោងទៅរក* សំណុំរឿង ០០២/១ សាលដីកា ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 កថាខណ្ឌ ៨២៨។

[139] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ (១) កថាខណ្ឌ ៧០-៧១។

[140] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ (១) កថាខណ្ឌ ៧២ និងជើងទំព័រ ១១០-១១៥។

ចិត្ត[141]។ សហមេធាវីសន្និដ្ឋានថា សំណើសុំប្ដឹងជំទាស់ ... គឺដើម្បីធានា "សិទ្ធិពិតជាក់ស្ដែងរបស់ ខៀវ សំផន ក្នុងការទទួលបានការជំនុំជម្រះសេចក្ដី ដោយតុលាការពីរថ្នាក់ខុសគ្នា"[142]។

៩៧. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាបានលើកឡើងថា ការជំទាស់របស់សហមេធាវី ទាក់ទងការបំបែកកិច្ចដំណើរការនីតិវិធី សិទ្ធិក្នុងការប្ដឹងសាទុក្ខ និងភាពត្រូតគ្នានៃការសម្រេច មិនអាចយកឈ្នះលើសច្ចធារណ៍ នៃអនាគតិរបស់ចៅក្រមឡើយ[143]។

៩៨. ពាក់ព័ន្ធការបំបែកកិច្ចដំណើរការនីតិវិធី សំណុំរឿង០០២ សហព្រះរាជអាជ្ញាបានលើកឡើងថា ទឡ្ហីករណ៍របស់សហមេធាវី ទាក់ទងការរំលោភបំពានទៅលើ សច្ចភាពតុលាការ និងសិទ្ធិទទួលបានការជំនុំជម្រះ ប្រកបដោយយុត្តិធម៌ ដែលបណ្ដាលមកពីលក្ខណៈថ្មី ដែលមិនធ្លាប់មាន នៃការបំបែកកិច្ចដំណើរការនីតិវិធី សំណុំរឿង០០២ ត្រូវបានលើកឡើងជាច្រើនដង ហើយត្រូវបានឆ្លើយតបយ៉ាងច្បាស់លាស់[144]។ សហព្រះរាជអាជ្ញាបានរំឮកថា អង្គជំនុំជម្រះតុលាការកំពូល បានពិចារណាអំពីផលប្រយោជន៍ស្របច្បាប់ជាច្រើន រួមទាំងព្យសនកម្មដែលអាចកើតមាន ចំពោះសិទ្ធិរបស់ជនជាប់ចោទ នៅមុនពេលសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ហើយបានសម្រេចថា ការធានាបាននូវយុត្តិធម៌មួយ ប្រកបដោយអត្ថន័យ តាមរយៈការទទួលបានសាលក្រម នៅក្នុងពេលជនជាប់ចោទនៅមានជីវិត គឺជាផលប្រយោជន៍ចម្បងបំផុត ជាអាទិភាពលើសពីក្ដីព្រួយបារម្ភណ៍នានា[145]។ ផ្ទុយពីទឡ្ហីករណ៍របស់សហមេធាវី ក្រុមប្រឹក្សាជំនុំជម្រះពិសេស នៃអង្គជំនុំជម្រះសាលាដំបូង បានគាំទ្រថាភាពត្រូតគ្នា រវាងសំណុំរឿងណាមួយ គឺមិនគ្រប់គ្រាន់សម្រាប់កំណត់ថា ចៅក្រមមិនអាចសម្រេចដោយឥតលម្អៀង ចំពោះសំណុំរឿង០០២/០២ ដោយគ្រាន់តែដោយសារការសម្រេចរបស់ពួកគាត់ ទៅលើភស្ដុតាងនានាក្នុងសំណុំរឿង០០២/០១ ឡើយ[146]។

[141] សំណើរបស់ ខៀវ សំផន ប្ដឹងជំទាស់ (១) កថាខណ្ឌ ៧៣។

[142] សំណើរបស់ ខៀវ សំផន ប្ដឹងជំទាស់ (១) កថាខណ្ឌ ៧៤។

[143] ចម្លើយតបរបស់ សហព្រះរាជអាជ្ញា (៥) កថាខណ្ឌ ២២-៣៦។

[144] ចម្លើយតបរបស់ សហព្រះរាជអាជ្ញា (៥) កថាខណ្ឌ ២២ យោងទៅរកផងដែរ សំណុំរឿង ០០២ សេចក្ដីសម្រេចលើកទីបី បំបែកកិច្ចដំណើរការនីតិវិធី (ឯកសារ E301/9/1/1/3) កថាខណ្ឌ ៣៩, ៦៣-៨៦។

[145] ចម្លើយតបរបស់ សហព្រះរាជអាជ្ញា (៥) កថាខណ្ឌ ២២-២៣ *យោងទៅរក*សំណុំរឿង ០០២ សេចក្ដីសម្រេចលើកទីពីរ បំបែកកិច្ចដំណើរការនីតិវិធី (ឯកសារ E284/4/8) កថាខណ្ឌ ៣៧-៣៨, ៤៣, ៥០-៥២ សំណុំរឿង ០០២ សេចក្ដីសម្រេចលើកទីបី បំបែកកិច្ចដំណើរការនីតិវិធី (ឯកសារ E301/9/1/1/3) កថាខណ្ឌ ៥៣-៥៥។

[146] ចម្លើយតបរបស់ សហព្រះរាជអាជ្ញា (៥) កថាខណ្ឌ ២៤-២៥ *យោងទៅរក* សំណុំរឿង ០០២/២ សេចក្ដីសម្រេចលើ សំណើ

៥៩. ចំពោះការចោទប្រកាន់ពីការរំលោភបំពាន ទៅលើសិទ្ធិក្នុងការប្ដឹងសាទុក្ខ សហព្រះរាជអាជ្ញាបានលើកឡើងថា សហមេធាវីបានផ្ដល់ត្រឹមតែការសង្ស័យអំពីភាពលម្អៀង ដែលមិនគ្រប់គ្រាន់ដើម្បីជំទាស់ចំពោះសច្ចធារណ៍នៃអនាគតិឡើយ[147]។

៦០. សម្រាប់ការចោទប្រកាន់អំពីបុរេវិនិច្ឆ័យ ដោយភាពត្រួតគ្នានៃការសម្រេចលើអង្គហេតុ ជាពិសេសទៅលើបញ្ហាដែលបានលើកឡើង ក្នុងសំណើសុំប្ដឹងជិតចិត្តនោះ[148] សហព្រះរាជអាជ្ញាបានលើកទឡ្ហីករណ៍ថា ការសម្រេចរបស់សាលដីកា សំណុំរឿង ០០២/០១ "បង្ហាញយ៉ាងច្បាស់" ពីការអនុវត្តច្បាប់ដោយត្រឹមត្រូវ និងការវាយតម្លៃទៅលើអង្គហេតុ ដោយមិនមានបុរេវិនិច្ឆ័យ ទៅលើបញ្ហាក្នុងបណ្ដឹងសាទុក្ខ សំណុំរឿង ០០២/០២ ទេ[149]។ សហព្រះរាជអាជ្ញាបានអះអាងថា ការយោងរបស់សហមេធាវី ទៅលើការនិយាយដោយចៃដន្យរបស់អង្គជំនុំជម្រះតុលាការកំពូល មិនបានបង្ហាញអំពីបុរេវិនិច្ឆ័យ ដោយសារតែវា មិនបានសម្រេចលើអត្ថិភាព នៃបទល្មើសព្រហ្មទណ្ឌ ឬសម្រេចទៅលើពិរុទ្ធភាពនៃអ្នកដាក់ពាក្យសុំ អំពីបទល្មើសឲ្យហួសពីវិមតិសង្ស័យឡើយ[150]។ សហព្រះរាជអាជ្ញាបានលើកឡើងបន្ថែមទៀតថា ការយោងរបស់សហមេធាវី ទៅរកការសម្រេចលើអង្គហេតុដែលរងការជំទាស់ នៅក្នុងសាលដីកាសំណុំរឿង០០២/០១ ទាក់ទងសហករណ៍និងការដ្ឋាន គោលនយោបាយកំណត់គោលដៅអតីតអ្នករដ្ឋការនិងយោធាសាធារណរដ្ឋខ្មែរ គោលនយោបាយខ្មាំង ការចូលរួមសហឧក្រិដ្ឋកម្មរួម និងការដឹងឮអំពីឧក្រិដ្ឋកម្ម គឺមិនមានអត្ថិភាព មិនពាក់ព័ន្ធ ឬមិនបានពិចារណានៅក្នុងបរិបទត្រឹមត្រូវ និងទាំងស្រុងនោះឡើយ[151]។ ជាចុងក្រោយ សហព្រះរាជអាជ្ញា បានលើកទឡ្ហីករណ៍ថា សូម្បីក្នុងករណីនៃការសម្រេចបុរេវិនិច្ឆ័យដែលអាចកើតឡើង លើបញ្ហារួមដោយសារតែការត្រួតគ្នា នៃការសម្រេចលើអង្គេហតុក្ដី ចៅក្រមដែលរងបណ្ដឹង គួរត្រូវបានចាត់ទុកថាអនា

សុំប្ដឹងជិតចិត្ត (ឯកសារ E314/12/1) កថាខណ្ឌ ១១, ៥០-៧០, ៩១-១០៥, ១០៦។

[147] ចម្លើយតបរបស់ សហព្រះរាជអាជ្ញា (៥) កថាខណ្ឌ ២៦ និងជើងទំព័រ ៧១។

[148] ចម្លើយតបរបស់ សហព្រះរាជអាជ្ញា (៥) កថាខណ្ឌ ២៧។

[149] ចម្លើយតបរបស់ សហព្រះរាជអាជ្ញា (៥) កថាខណ្ឌ ២៨-២៩។

[150] ចម្លើយតបរបស់ សហព្រះរាជអាជ្ញា (៥) កថាខណ្ឌ ៣០ *យោងទៅរកPoppe តទល់នឹង ប្រទេសហូឡង់* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) កថាខណ្ឌ ២៨។

[151] ចម្លើយតបរបស់ សហព្រះរាជអាជ្ញា (៥) កថាខណ្ឌ ៣០-៣៣។

គតិ ដោយសារតែពួកគាត់បានដឹងច្បាស់ថា ធាតុផ្សំអង្គហេតុរួម ចាំបាច់ត្រូវតែបង្កើតឡើងថ្មី នៅក្នុងគ្រប់សំណុំរឿងទាំងអស់[152]។

៦១. ចំពោះការសម្រេចលើអង្គច្បាប់ នៃសាលដីកាសំណុំរឿង០០២/០១ សហព្រះរាជអាជ្ញាបានលើកទឡ្ហីករណ៍ថា ចៅក្រមមិនត្រូវបានហាមឃាត់ មិនឱ្យជំនុំជម្រះលើសវនាការព្រហ្មទណ្ឌពីរដាច់ពីគ្នា ដែលកើតចេញពីបណ្តុំអង្គហេតុរួមគ្នា ដោយមានការត្រួតគ្នានៃបញ្ហាអង្គហេតុ ឬបញ្ហាអង្គច្បាប់ឡើយ ប្រសិនបើចៅក្រមអាចប្រកាន់ចិត្តឥតលំអៀង សម្រាប់ភស្តុតាងនៅក្នុងសំណុំរឿងថ្មី [153] ហើយថាបុរេវិនិច្ឆ័យអាចមានអត្ថិភាព តែក្នុងករណីដែលចៅក្រមរងបណ្តឹង បានសម្រេចក្នុងសំណុំរឿង០០២/០១ លើគ្រប់ធាតុផ្សំទាំងអស់ នៃបទល្មើសសំណុំរឿង០០២/០២ ហើយសម្រេចថា ខៀវ សំផន មានពិរុទ្ធភាពលើពីវិមតិសង្ស័យក្នុងការប្រព្រឹត្តិបទល្មើសនោះ ដែលករណីនេះមិនមានកើតឡើងទេ[154]។

## ២. ការពិភាក្សា

៦២. ក្រុមប្រឹក្សាជំនុំជម្រះពិសេស ជាដំបូងបានកំណត់ពីបទដ្ឋានគតិយុត្តិ ដែលនៅជាធរមាន សម្រាប់បណ្តឹងជំទាស់ចៅក្រម។ បន្ទាប់មកក្រុមប្រឹក្សាជំនុំជម្រះពិសេស បានដោះស្រាយចំពោះសារណា របស់សហមេធាវី និងសហព្រះរាជអាជ្ញា ទាក់ទងនឹងយុត្តិសាស្ត្រពាក់ព័ន្ធនានា។ ក្រុមប្រឹក្សាជំនុំជម្រះពិសេស បានវាយតម្លៃបន្ថែមលើទឡ្ហីករណ៍គតិយុត្តិរបស់ភាគីនានា អំពីការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២ និងសិទ្ធិរបស់ ខៀវ សំផន ក្នុងការប្តឹងសាទុក្ខ ហើយនិងបន្តទៅត្រួតពិនិត្យ លើការចោទប្រកាន់អំពីបុរេ

---

[152] ចម្លើយតបរបស់ សហព្រះរាជអាជ្ញា (៥) កថាខណ្ឌ ៣៤ *យោងទៅរក*សំណុំរឿង ០០២/២ សេចក្តីសម្រេចលើ សំណើសុំប្តឹងជំទាស់ចៅក្រម (ឯកសារ E314/12/1) កថាខណ្ឌ ៩៦ ដកស្រង់សំណុំរឿង ០០២ សេចក្តីសម្រេចលើកទីបី បំបែកកិច្ចដំណើរការនីតិវិធី (ឯកសារ E301/9/1/1/3) កថាខណ្ឌ ៨៣-៨៤។

[153] ចម្លើយតបរបស់ សហព្រះរាជអាជ្ញា (៥) កថាខណ្ឌ ៣៥។

[154] ចម្លើយតបរបស់ សហព្រះរាជអាជ្ញា (៥) កថាខណ្ឌ ៣៥ *យោងទៅរក*Poppe *តទល់នឹង ប្រទេសហូឡង់* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) កថាខណ្ឌ ២៨សំណុំរឿង ០០២/២ សេចក្តីសម្រេចលើ សំណើសុំប្តឹងជំទាស់ចៅក្រម (ឯកសារ E314/12/1) កថាខណ្ឌ ៤១-៤៤ សេចក្តីសម្រេចលើ សំណើសុំប្តឹងជំទាស់ចៅក្រម (ឯកសារ E55/4) កថាខណ្ឌ ១៧-១៨ តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង*Mladić IT-09-92-T សេចក្តីសម្រេចលើញត្តិមេធាវីការពារក្តី ស្នើសុំការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងសច្ចធារណ៍នៃនិរទោស ឬជាជំនួសវិញនូវ ការធ្វើមោឃភាពការចោទប្រកាន់ (a Mistrial) អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៦ កថាខណ្ឌ ១១-១២។

វិនិច្ឆ័យ របស់សាលដីកាសំណុំរឿង០០២/១ អំពីការសម្រេចលើអង្គហេតុ និងអង្គច្បាប់ ក្នុងសំណុំរឿង ០០២/០២។

៦៣. មានការកំណត់យ៉ាងច្បាស់លាស់ ហើយមិនមានការជំទាស់ពីភាគីឡើយ[155] ថា លក្ខខណ្ឌតម្រូវនៃអនាគតិត្រូវបានរំលោភបំពាន នៅពេលដែលមានភាពលំអៀង ឬការស្តែងចេញនូវភាពលំអៀង របស់ចៅក្រម [156]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេស សូមរំឭកថាការស្តែងចេញនូវភាពលំអៀង ត្រូវបានបង្ហាញប្រសិនបើ៖

> (ក) ចៅក្រមរូបនោះគឺជាភាគីណាមួយក្នុងរឿងក្តី ឬមានផលប្រយោជន៍ផ្ទាល់ខ្លួន ឬហិរញ្ញវត្ថុ ចំពោះលទ្ធផលនៃរឿងក្តី ឬប្រសិនបើការសម្រេចរបស់ចៅក្រមរូបនោះ នឹងនាំឱ្យកើតចេញនូវបុព្វហេតុអ្វីមួយផ្សេងទៀត ដែលចៅក្រមរូបនោះមានការពាក់ព័ន្ធ ឬកាលៈទេសៈទាំងនោះ ដែលធ្វើឱ្យអ្នកសង្កេតការណ៍មិនលម្អៀងម្នាក់ ដែលបានទទួលព័ត៌មានគ្រប់គ្រាន់ យល់ឃើញដោយសមហេតុផលថា មានភាពលម្អៀង។
>
> អ្នកសង្កេតការណ៍មិនលំអៀង ដែលឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យនេះ ត្រូវតែជា "បុគ្គលដែលបានទទួលព័ត៌មាន គ្រប់កាលៈទេសៈពាក់ព័ន្ធទាំងអស់ ដោយរួមបញ្ចូលទាំងប្រពៃណីនៃសេចក្តីថ្លៃថ្នូរ និងភាពអនាគតិ ហើយអ្នកសង្កេតការណ៍នោះយល់ថា អនាគតិគឺជាភារកិច្ចមួយ ក្នុងចំណោមភារកិច្ចនានា ដែលចៅក្រមត្រូវតែប្រកាន់យកឱ្យបានខ្ជាប់ខ្ជួន។[157]

៦៤. ក្រុមប្រឹក្សាជំនុំជម្រះពិសេសសម្រេច ដូចដែលអង្គជំនុំជម្រះនានានៃ អ.វ.ត.ក និងតុលាការអន្តរជាតិដទៃទៀតបានសម្រេចដែរនោះ ថាចៅក្រមទទួលបានសច្ចធារណ៍នៃអនាគតិ ដែលតម្រូវឱ្យមាន

---

[155] សំណើសុំប្តឹងជំទាស់ចិត្តរបស់ខៀវ សំផន (១) កថាខណ្ឌ១៩-២២, ការឆ្លើយតបរបស់សហព្រះរាជអាជ្ញា (៥) កថាខណ្ឌ៩។

[156] វិធាន៣៤(២) នៃវិធានផ្ទៃក្នុង, សេចក្តីសម្រេចលើសំណើសុំរបស់អៀង ធីរិទ្ធ ក្នុងសំណុំរឿង ០០២ ឯការ 1/4 កថាខណ្ឌ១០, សេចក្តីសម្រេចលើពាក្យសុំប្តឹងជំទាស់ចិត្តរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២ ឯកសារ E55/4 កថាខណ្ឌ១១-១២, សំអាងហេតុនៃសេចក្តីសម្រេចជំទាស់ចិត្ត ឯកសារ E314/12/1 កថាខណ្ឌ៣៣។

[157] សំណុំរឿង ០០២ សេចក្តីសម្រេចលើសំណើប្តឹងជំទាស់ចិត្តរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ E55/4 កថាខណ្ឌ១១ -១២ *យោងទៅ* សេចក្តីសម្រេចនៃបណ្តឹងសាទុក្ខរបស់ *Furundžija* (ICTY) កថាខណ្ឌ១៨៩-១៩០, *សូមមើលផងដែរ* សំណុំរឿង ០០២ សំអាងហេតុនៃសេចក្តីសម្រេចជំទាស់ចិត្ត ឯកសារ E314/12/1 កថាខណ្ឌ៣៣។

លក្ខខណ្ឌតម្រូវនៃភស្តុតាងខ្ពស់ សម្រាប់ភាគីដែលបានដាក់សំណើ ដើម្បីដកចេញនូវសច្ចធារណ៍នេះ [158] ។ ដើម្បីប្តឹងជំទាស់ចៅក្រមមួយរូប អត្ថិភាពនៃការយល់ឃើញដោយសមហេតុផល អំពីភាពលំអៀងត្រូវតែ "បង្កើតឡើងយ៉ាងរឹងមាំ" [159] ។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសសូមរំឭកថា ចាំបាច់ត្រូវមានលក្ខខណ្ឌតម្រូវខ្ពស់ ដោយសារតែវាជាការគម្រាមកំហែង ទៅលើផលប្រយោជន៍នៃរដ្ឋបាលតុលាការ ប្រកបដោយយុត្តិធម៌ និងឥតលំអៀង ដែលចៅក្រមត្រូវបានប្តឹងជំទាស់ ដោយផ្អែកលើមូលដ្ឋាននៃការចោទប្រកាន់ ដែលគ្មានមូលដ្ឋាន ឬគ្មានការគាំទ្រ នៃភាពលម្អៀងជាក់ស្តែង ថាជាការបង្ហាញយ៉ាងពិតប្រាកដពីភាពលំអៀង[160]។ សច្ចធារណ៍នៃអនាគតិចៅក្រម ត្រូវបានបកស្រាយថាជាការសន្មតថា តាមរយៈការបណ្តុះបណ្តាល និងបទពិសោធន៍របស់ពួកគាត់ ចៅក្រម "អាចកែប្រែចិត្តគំនិតរបស់ខ្លួន ចំពោះជំនឿ ឬការរៀបចំជាមុន ជាលក្ខណៈផ្ទាល់ខ្លួន ដែលមិនពាក់ព័ន្ធនានា" លើកលែងតែមានការបង្ហាញភស្តុតាងផ្ទុយពីនេះ[161]។

៦៥. ងាកទៅមើលការចោទប្រកាន់អំពីភាពលំអៀង លើបុរេវិនិច្ឆ័យនៃបណ្តឹងសាទុក្ខ នៅក្នុងសំណុំរឿង ០០២/០២ ក្រុមប្រឹក្សាជំនុំជម្រះពិសេស បានកត់សម្គាល់ឃើញថា សហមេធាវីបានយោងទៅរកយុត្តិសា

---

[158] សំណុំរឿង ០០២/២ សេចក្តីសម្រេចលើ សំណើសុំប្តឹងជំទាស់ចៅក្រម (ឯកសារ E314/12/1) កថាខណ្ឌ ៣៣ សេចក្តីសម្រេចលើសំណើសុំប្តឹងជំទាស់ចៅក្រម (ឯកសារ E55/4) កថាខណ្ឌ ១២ *យោងទៅរក* កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣(៣) ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ១០ ថ្មី, សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រមបន្ទាន់របស់សហមេធាវី (ឯកសារ C11/29) កថាខណ្ឌ ១៥-១៧ សាលដីការឿងក្តី Furundžija (តុលាការ ICTY) កថាខណ្ឌ ១៩៦-១៩៧ *Delalić និងអ្នកដទៃទៀត* សាលដីកា (តុលាការ ICTY) កថាខណ្ឌ ៧០៧, សាលដីការឿងក្តី *Nahimana និងអ្នកដទៃទៀត* (តុលាការ ICTR) កថាខណ្ឌ ៤៨- ៥០។

[159] សាលដីការឿងក្តី Furundžija (តុលាការ ICTY) កថាខណ្ឌ ១៩៧ តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង* *Blagojević*, IT-02-60-R សេចក្តីសម្រេចលើបណ្តឹងប្តឹងជំទាស់ចៅក្រម ថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៨ ("សេចក្តីសម្រេចលើ Blagojević (តុលាការ ICTY)") កថាខណ្ឌ ៣ សេចក្តីសម្រេចលើរឿងក្តី *Brđanin និង Talić (*តុលាការ *ICTY)* កថាខណ្ឌ ១៨។

[160] សំណុំរឿង ០០២/២ សេចក្តីសម្រេចលើ សំណើសុំប្តឹងជំទាស់ចៅក្រម (ឯកសារ E314/12/1) កថាខណ្ឌ ៣៥ *យោងទៅរក*តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹងKaradzić* IT-95-5/18-PT សេចក្តីសម្រេចលើបណ្តឹងជំទាស់ ចៅក្រម Picard និងរបាយការណ៍ជូនទៅអនុប្រធាន អនុលោមតាមវិធាន ១៥(ខ)(២) អង្គជំនុំជម្រះរបស់តុលាការ ICTY បានកោះប្រជុំតាមបញ្ជារបស់លោកអនុប្រធាន ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ ("សេចក្តីសម្រេចលើ Karadzić (តុលាការ ICTY)") កថាខណ្ឌ ១៧ សេចក្តីសម្រេចលើ Blagojević (តុលាការ ICTY) កថាខណ្ឌ ៣, សាលដីការឿងក្តី *Delalić និងអ្នកដទៃទៀត* (តុលាការ ICTY) កថាខណ្ឌ ៧០៧។

[161] សាលដីការឿងក្តី Furundžija (តុលាការ ICTY) កថាខណ្ឌ ១៩៧ សាលដីការឿងក្តី *Nahimana និងអ្នកដទៃទៀត* (តុលាការ ICTR) កថាខណ្ឌ ៤៨, ៧៨ ("តាមការសន្មត ក្នុងករណីមិនមានភស្តុតាងផ្ទុយ ដោយសារការបណ្តុះបណ្តាល និងបទពិសោធន៍របស់ពួកគាត់ ចៅក្រមនឹងសម្រេចដោយយុត្តិធម៌ លើបញ្ហាទៅចំពោះមុខខ្លួន ដោយពឹងផ្អែកទាំងស្រុងនិងតែទៅលើ ភស្តុតាងដែលបានបង្ហាញ នៅក្នុងរឿងក្តីជាក់លាក់") សាលដីការឿងក្តី *Akayesu* (តុលាការ ICTR) កថាខណ្ឌ ២៦៩, សាលដីការឿងក្តី *Renzaho* (តុលាការ ICTR) កថាខណ្ឌ ២៣។

ស្ត្ររបស់ អ.វ.ត.ក MICT និងតុលាការសិទ្ធិមនុស្សអឺរ៉ុប ដើម្បីគាំទ្រជំហររបស់ពួកគេ[162]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេស ពិចារណាទឡ្ហីករណ៍របស់សហមេធាវី ទាក់ទងនឹងយុត្តិសាស្ត្ររបស់ អ.វ.ត.ក ដែលថាក្រុមប្រឹក្សាជំនុំជម្រះពិសេស របស់អង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គងក្នុងការបដិសេធ សំណើសុំប្ដឹងជំទាស់ចិត្ត ដោយផ្អែកលើមតិជំទាស់មួយផ្នែករបស់ចៅក្រម DOWNING នោះ[163] គឺមិនមានភស្តុតាងគាំទ្រទេ។ ក្រុមប្រឹក្សាជំនុំជម្រះពិសេស កត់សម្គាល់ដូចដែលសហមេធាវី បានឯកភាពដែរនោះ[164] ថាមតិជំទាស់មួយផ្នែករបស់ចៅក្រម DOWNING បង្កើតបានជាមតិយោបល់ផ្ទុយ ពីគោលជំហររបស់មតិភាគច្រើនលើសលប់ នៃក្រុមប្រឹក្សាជំនុំជម្រះពិសេសរបស់អង្គជំនុំជម្រះសាលាដំបូង។ ដើម្បីគាំទ្រដល់គោលជំហររបស់ពួកគេ សហមេធាវីបានយោងទៅរកយុត្តិសាស្ត្រ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ជាពិសេសសេចក្ដីសម្រេចរបស់ចៅក្រម ANTONETTI មួយរូប ក្នុងរឿងក្ដី *Mladić*[165] ដែលក្រុមប្រឹក្សាជំនុំជម្រះពិសេស នឹងបកស្រាយនៅផ្នែកខាងក្រោម។ ក្រៅពីនេះ សហមេធាវីមិនបានផ្ដល់ ទឡ្ហីករណ៍រឹងមាំ ឬឧទាហរណ៍ប្រកបដោយអត្ថន័យណាមួយ ដើម្បីគាំទ្រការចោទប្រកាន់របស់ពួកគេ ដែលថាមតិភាគច្រើនលើសលប់ របស់ក្រុមប្រឹក្សាជំនុំជម្រះពិសេស នៃអង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គងក្នុងការបដិសេធ សំណើសុំប្ដឹងជំទាស់ចិត្តឡើយ។

៦៦. ចំពោះការពឹងផ្អែករបស់សហមេធាវី ទៅលើសេចក្ដីសម្រេចរបស់ ចៅក្រម ANTONETTI មួយរូប ក្នុងរឿងក្ដី *Mladić*[166] ក្រុមប្រឹក្សាជំនុំជម្រះពិសេសកត់សម្គាល់ថា យុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដទៃ មិនមានអានុភាពចងកាតព្វកិច្ចឡើយនៅ អ.វ.ត.ក[167]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេស កត់សម្គាល់បន្ថែមទៀតថា សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ចិត្ត *Mladić* បានដកចេញពីយុត្តិសាស្ត្រជាធរមានកន្លងមក របស់តុលាការសិទ្ធិមនុស្សអឺរ៉ុប និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ទាក់ទងសច្ចធារណ៍នៃអនាគតិ[168]។ ជាពិសេស បើទោះបីជាបានទទួលយក មតិយោបល់ជំទាស់របស់ចៅក្រម DOWNING ក្ដី ប៉ុន្តែ

---

[162] សំណើរបស់ ខៀវ សំផន ប្ដឹងជំទាស់ចិត្ត (១) កថាខណ្ឌ ២៥-៤០។

[163] សំណើរបស់ ខៀវ សំផន ប្ដឹងជំទាស់ចិត្ត (១) កថាខណ្ឌ ២៥-២៨។

[164] សំណើរបស់ ខៀវ សំផន ប្ដឹងជំទាស់ចិត្ត (១) កថាខណ្ឌ ២៥-២៧។

[165] សំណើរបស់ ខៀវ សំផន ប្ដឹងជំទាស់ចិត្ត (១) កថាខណ្ឌ ២៨, ៣០-៣៥។

[166] សំណើរបស់ ខៀវ សំផន ប្ដឹងជំទាស់ចិត្ត (១) កថាខណ្ឌ ៣០-៣៦។

[167] សាលដីកា សំណុំរឿង ០០១ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ (ឯកសារ F28) កថាខណ្ឌ ៩៧ *យោងទៅរក* លក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ មាត្រា ៣៨។

[168] *សូមមើលជាឧទាហរណ៍* សេចក្ដីសម្រេចរឿងក្ដី *Šešelj* (តុលាការ ICTY) កថាខណ្ឌ ២៨ ដកស្រង់សេចក្ដីសម្រេចលើរឿងក្ដី

ចៅក្រម ANTONETTI បានច្រានចោល "លក្ខណៈវិនិច្ឆ័យពាក់ព័ន្ធទាំងអស់ ដែលចាំបាច់សម្រាប់បង្កើត ជាបទល្មើសព្រហ្មទណ្ឌ" ហើយពិចារណាផ្សេងទៅលើបុរេវិនិច្ឆ័យដែលមានស្រាប់ថាជា "ការស្រាយបំភ្លឺ" និង "មិនមែនជាលក្ខណៈវិនិច្ឆ័យដាច់ខាត" [169] ។ បើយោងតាមការបកស្រាយរបស់ចៅក្រម ANTONETTI ភាពលំអៀងមានអត្ថិភាពប្រសិនបើ ចៅក្រមដែលរងបណ្តឹងបានសម្រេច លើតួនាទីរបស់ម្ចាស់បណ្តឹង ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋកម្ម ដោយមិនបានពិភាក្សា "លក្ខណៈវិនិច្ឆ័យពាក់ព័ន្ធទាំងអស់" នៃបទល្មើសព្រហ្មទណ្ឌ[170]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសពិចារណាថា ការបកស្រាយនេះមិនគ្រប់ដណ្តប់ លើការស្រាយបំភ្លឺបន្តបន្ទាប់លើបញ្ហា ដោយតុលាការសិទ្ធិមនុស្សអឺរ៉ុបឡើយ ដែលដូច្នេះ គឺងាកចេញពីយុត្តិសាស្ត្រដែលបានកំណត់រួចហើយ[171]។

៦៧. ក្រុមប្រឹក្សាជំនុំជម្រះពិសេសសូមរំឭកថា ផ្ទុយពីការសម្រេចរបស់ចៅក្រម ANTONETTI[172] ត្រឹមតែការទទួលបានភស្តុតាង គឺមិនអាចផ្តល់យុត្តិកម្មដល់អត្ថិភាពនៃការស្តែងចេញនូវភាពលំអៀងឡើយ

---

*Brđanin និង Talić (តុលាការ ICTY)* កថាខណ្ឌ ១៨ សេចក្តីសម្រេចលើរឿងក្តី Ntawukulilyayo (តុលាការ ICTR) កថាខណ្ឌ ៧, ១២, ១៣ សាលដីការឿងក្តី *Nahimana និងអ្នកដទៃទៀត* (តុលាការ ICTR) កថាខណ្ឌ ៤៨, ៧៨ សាលដីការឿងក្តី*Renzaho* (តុលាការ ICTR) កថាខណ្ឌ ២២-២៣ *Poppe តទល់នឹង ប្រទេសហូឡង់* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) កថាខណ្ឌ ២៦, *Miminoshvili* តទល់នឹង *Russia* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) កថាខណ្ឌ ១១៥-១១៦, តុលាការសិទ្ធិមនុស្សអឺរ៉ុប *Khodorkovskiy និង Lebedev* តទល់នឹង *Russia* សំណើសុំលេខ 11082/06 និង 13772/05 សាលក្រម Judgment ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៣ ("*Khodorkovskiy and Lebedev* តទល់នឹង *Russia* (តុលាការសិទ្ធិមនុស្សអឺរ៉ុប)") កថាខណ្ឌ ៥៤៤។

[169] សេចក្តីសម្រេចលើបណ្តឹងជិតចិត្ត Mladić កថាខណ្ឌ ២៥។

[170] សេចក្តីសម្រេចលើបណ្តឹងជិតចិត្ត Mladić កថាខណ្ឌ ២៥ *យោងទៅរក*តុលាការសិទ្ធិមនុស្សអឺរ៉ុប *Rojas Morales* តទល់នឹង *ប្រទេសអ៊ីតាលី* សំណើសុំលេខ 39676/98សាលក្រម ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០០ ("*Rojas Morales* តទល់នឹង *ប្រទេសអ៊ីតាលី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប)") កថាខណ្ឌ ២៩, ៣៣-៣៤ តុលាការសិទ្ធិមនុស្សអឺរ៉ុប *Ferrantelli និង Santangelo* តទល់នឹង *ប្រទេសអ៊ីតាលី*, សំណើសុំលេខ 19874/92 សាលក្រម ថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៦ ("*Ferrantelli និង Santangelo* តទល់នឹង *ប្រទេសអ៊ីតាលី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប)") កថាខណ្ឌ ៥៩។

[171] *សូមមើលជាឧទាហរណ៍* *Miminoshvili* តទល់នឹង *Russia* (តុលាការសិទ្ធិមនុស្សអឺរ៉ុប កថាខណ្ឌ ១១៥-១១៦ *Khodorkovskiy និង Lebedev* តទល់នឹង *Russia* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) កថាខណ្ឌ ៥៤៤ *Poppe តទល់នឹង ប្រទេសហូឡង់* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) កថាខណ្ឌ ២៦ តុលាការសិទ្ធិមនុស្សអឺរ៉ុប *OOO 'Vesti' និង Ukhov* តទល់នឹង *Russia* សំណើសុំលេខ 21724/03 សាលក្រម (អង្គសេចក្តី) ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ("*OOO 'Vesti' និង Ukhov* តទល់នឹង *Russia* (តុលាការសិទ្ធិមនុស្សអឺរ៉ុប)") កថាខណ្ឌ ៧៦-៧៧។ សម្រាប់ព័ត៌មានបន្ថែម សូមមើលខាងក្រោម កថាខណ្ឌ ២៥។

[172] សេចក្តីសម្រេចលើបណ្តឹងជិតចិត្ត Mladić កថាខណ្ឌ ៤៩, ៥២ ("ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល រួមទាំងចៅក្រម

ហើយតាមរយៈការបណ្តុះបណ្តាល និងបទពិសោធន៍របស់ពួកគាត់ ចៅក្រមនឹងសម្រេចដោយយុត្តិធម៌ទៅលើ បញ្ហានៅចំពោះមុខពួកគាត់ ដោយពឹងផ្អែកទាំងស្រុងនិងទៅលើតែភស្តុតាង ដែលបានបង្ហាញក្នុងរឿងក្តីជាក់លាក់ លើកលែងតែមានភស្តុតាងបង្ហាញផ្សេងពីនេះ[173]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសសង្កត់ធ្ងន់ថា ដើម្បីសម្រេចលើការស្តែងចេញនូវភាពលំអៀង ការចោទប្រកាន់ចាំបាច់ត្រូវតែ "បង្ហាញឱ្យច្បាស់តាមរយៈភស្តុតាង" ដែលមានន័យថាចាំបាច់ត្រូវបំពេញបានតាម លក្ខណៈវិនិច្ឆ័យដ៏ខ្ពស់ ដើម្បីជំទាស់ចំពោះសច្ចធារណ៍នៃអនាគតិ[174]។ បន្ថែមលើនេះ ចៅក្រមអាចចូលរួមពាក់ព័ន្ធ ក្នុងការជំនុំជម្រះដែល តាមលក្ខណៈជាក់ស្តែងនៃសវនាការនោះ គ្រប់ដណ្តប់លើបញ្ហាត្រួតគ្នា ឬដោះស្រាយចំពោះបញ្ហាអង្គហេតុ និងបញ្ហាអង្គច្បាប់ប្រហែលគ្នា[175]។ ហេតុដូច្នេះក្រុមប្រឹក្សាជំនុំជម្រះពិសេស ពិចារណាថា សំអាងហេតុរបស់ចៅក្រម

---

Meron ត្រូវបានសួរដេញដោលយ៉ាងតានតឹង ដោយភស្តុតាង ដែលបានទទួលយកដោយ អង្គជំនុំជម្រះសាលាដំបូង និងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង [...]។ ជាលទ្ធផល ពិតជាពិបាកក្នុងការស្រម័យមើលថាតើចៅក្រម Meron អាចទទួលយកបណ្តឹងសាទុក្ខដែលដាក់ដោយជនជាប់ចោទ Ratko Mladić ដោយរបៀបនា ដោយមិនទទួលឥទ្ធិពលពី ភស្តុតាងដាក់បន្ទុកដែលគាត់បានវិភាគប្រឆាំងជនជាប់ចោទរូបនេះ រួមជាមួយការសម្រេចកន្លងមករបស់លោក [...]។ ដោយពិចារណាទៅលើអ្វីដែលមានកន្លងមក ការវិភាគទៅលើឯកសារយោង ដាក់បន្ទុកទៅលើ Ratko Mladic ដោយវិភាគរួមគ្នា ហាក់ដូចជាបង្ហាញថាមានការស្តែងចេញដោយសមហេតុផល នូវភាពលម្អៀង (ដោយគូសបញ្ជាក់បន្ថែម)។

[173] សាលដីការឿងក្តី Furundžija (តុលាការ ICTY) កថាខណ្ឌ ១៩៧ សាលដីការឿងក្តី *Nahimana និងអ្នកដទៃទៀត* (តុលាការ ICTR) កថាខណ្ឌ ៤៨, ៧៨ ("មានការសន្មតថា ក្នុងករណីមិនមានភស្តុតាងបង្ហាញផ្ទុយ តាមរយៈការបណ្តុះបណ្តាល និងបទពិសោធន៍របស់គាត់ ចៅក្រមនឹងសម្រេចសេចក្តីដោយយុត្តិធម៌ លើបញ្ហានៅចំពោះមុខខ្លួន ដោយពឹងផ្អែកទាំងស្រុង និងតែទៅលើភស្តុតាង ដែលបានបង្ហាញក្នុងរឿងក្តីជាក់លាក់នោះ"), សាលដីការឿងក្តី *Akayesu* (តុលាការ ICTR) កថាខណ្ឌ ២៦៩ សាលដីការឿងក្តី *Renzaho* (តុលាការ ICTR) កថាខណ្ឌ ២៣។

[174] សាលដីការឿងក្តី *Akayesu* (តុលាការ ICTR) កថាខណ្ឌ ៩១ ដកស្រង់សាលដីការឿងក្តី Furundžija (តុលាការ ICTY) កថាខណ្ឌ ១៩៧ សេចក្តីសម្រេចលើ Blagojević (តុលាការ ICTY) កថាខណ្ឌ ៣, សាលដីការឿងក្តី *Delalić និងអ្នកដទៃទៀត* (តុលាការ ICTY) កថាខណ្ឌ ៧០៧ សំណុំរឿង 00២/២ សេចក្តីសម្រេចលើ សំណើសុំប្តឹងជំទាស់ (ឯកសារ E314/12/1) កថាខណ្ឌ ៣៥ សេចក្តីសម្រេចលើ សំណើសុំប្តឹងជំទាស់ (ឯកសារ E55/4) កថាខណ្ឌ ១២ *យោងទៅរក*សេចក្តីសម្រេចលើបណ្តឹងជំទាស់បន្ទាន់របស់សហមេធាវី (ឯកសារ C11/29) កថាខណ្ឌ ១៥។

[175] សេចក្តីសម្រេចលើ សំណើសុំប្តឹងជំទាស់ (ឯកសារ E55/4) កថាខណ្ឌ ១៥ សាលដីការឿងក្តី *Karera* (តុលាការ ICTR) កថាខណ្ឌ ៣៧៨ សាលដីកា *Nahimana និងអ្នកដទៃទៀត* (តុលាការ ICTR) កថាខណ្ឌ ៧៨ តុលាការ SCSL *រដ្ឋអាជ្ញា តទល់នឹង* Sesay និងអ្នកដទៃទៀត SCSL-04-I5-T សេចក្តីសម្រេចលើសំណើរបស់ Sesay និង Gbao សុំឱ្យដកចេញដោយស្ម័គ្រចិត្ត ឬប្តឹងជំទាស់ចៅក្រម Bankole Thompson ចេញពីរឿងក្តី RUF អង្គជំនុំជម្រះសាលាដំបូង I ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០០៧ ("*Sesay និងអ្នកដទៃទៀត* (តុលាការ SCSL)") កថាខណ្ឌ ៥៥ តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង Kordić និង Čerkez*, IT-95-I4/2- PT សេចក្តីសម្រេចលើសំណើសុំប្តឹងជំទាស់ ចៅក្រម Jorda និង Riad, Bureau ថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៩៨ ("សេចក្តីសម្រេចលើសំណើរបស់ Kordić

ANTONETTI តែមួយរូប បានដកចេញពីយុត្តិសាស្ត្រជាធរមាន លើសច្ចធារណ៍នៃអនាគតិរបស់ចៅក្រម ហើយក្រុមប្រឹក្សាជំនុំជម្រះពិសេស មិនជឿជាក់ថាសេចក្តីសម្រេចរបស់ចៅក្រម ANTONETTI តែមួយរូប ឬករួមជាមួយមតិជំទាស់មួយផ្នែករបស់ចៅក្រម DOWNING អាចបង្កើតបានជាចំណុចផ្លាស់ប្តូរ លើការបន្ថយបទដ្ឋានដើម្បីជំទាស់ ចំពោះសច្ចធារណ៍នៃអនាគតិរបស់ចៅក្រមនោះឡើយ[176]។

៦៨. ចំពោះយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ក្រុមប្រឹក្សាជំនុំជម្រះពិសេសកត់សម្គាល់ថា សហមេធាវីគាំទ្រទឡ្ហីករណ៍របស់ខ្លួន ដោយផ្អែកលើអត្ថិភាពនៃភាពលំអៀង ដោយយោង[177]ទៅរកការបកស្រាយរបស់ចៅក្រម DOWNING និងចៅក្រម ANTONETTI ក្នុងរឿងក្តី *Poppe តទល់នឹងប្រទេសហូឡង់* ដែលថា "លក្ខណវិនិច្ឆ័យពាក់ព័ន្ធទាំងអស់ ដែលចាំបាច់បង្កើតបានជាបទល្មើសព្រហ្មទណ្ឌមួយនោះ គឺគ្រាន់តែជាការស្រាយបំភ្លឺប៉ុណ្ណោះ ប៉ុន្តែមិនបង្កើតបានជាលក្ខណៈវិនិច្ឆ័យដាច់ខាត សម្រាប់បុរេវិនិច្ឆ័យទេ"[178]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសកត់សម្គាល់ថា លក្ខណៈវិនិច្ឆ័យសម្រាប់អត្ថិភាពនៃបុរេវិនិច្ឆ័យដែលបានកំណត់ក្នុងរឿងក្តី *Poppe តទល់នឹង ប្រទេសហូឡង់*[179] ត្រូវបានអនុវត្តជាលក្ខណៈវិនិច្ឆ័យដាច់ខាត នៅក្នុងយុត្តិសាស្ត្រតុលាការសិទ្ធិមនុស្សអឺរ៉ុប[180]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសពិចារណាបន្ថែមថា ការយោង

---

និង Čerkez (តុលាការ ICTY)")។

[176] ***សូមមើលផងដែរ*** Joseph POWDERLY ***ចៅក្រមនិងការបង្កើត ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ*** (Brill, 2020) ទំព័រ ១៧៣-១៨៣ រួមទាំងការសង្កេតនៅទំព័រ ១៧៩-១៨០ ដែលសំអាងហេតុរបស់ចៅក្រម Antonetti "ហាក់ដូចជាមិនបានភ្ជាប់នូវស្ថានទម្ងន់ណាមួយសោះ ជាមួយយុត្តិសាស្ត្រដែលបានកំណត់ស្រាប់ របស់តុលាការចំពោះកិច្ច លើបញ្ហានោះ (ក្រៅពីការនិយាយបញ្ចិតបញ្ចៀងកន្លងមក) និងជាពិសេសជំនឿដែលអះអាងជាញឹកញាប់ ក្នុងសមត្ថភាពផ្លូវចិត្តរបស់ចៅក្រម ក្នុងការតម្រង់ដោយខ្លួនឯង នូវមតិដែលបង្ហាញ ឬការសម្រេចដែលត្រូវធ្វើឡើង ក្នុងរឿងក្តីពាក់ព័ន្ធ។ លក្ខណៈវិនិច្ឆ័យនេះ ត្រូវបានដកចេញយ៉ាងច្បាស់ ពីលក្ខណៈវិនិច្ឆ័យអ្នកសង្កេតការណ៍ ដោយសមហេតុផល [...]"។

[177] សំណើរបស់ ខៀវ សំផន ប្តឹងដិតចិត្ត (១) កថាខណ្ឌ ៣៧។

[178] សំណុំរឿង ០០២/២ សេចក្តីសម្រេចលើ សំណើសុំប្តឹងដិតចិត្ត (ឯកសារ E314/12/1) មតិជំទាស់ដោយផ្នែករបស់ចៅក្រម DOWNING កថាខណ្ឌ ១៦ សេចក្តីសម្រេចលើបណ្តឹងដិតចិត្ត Mladić កថាខណ្ឌ ២៥។

[179] *Poppe តទល់នឹង ប្រទេសហូឡង់* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) កថាខណ្ឌ ២៨ ("ថាតើការចូលរួមរបស់អ្នកដាក់ពាក្យសុំ [...] បានបំពេញគ្រប់លក្ខខណ្ឌតម្រូវពាក់ព័ន្ធទាំងអស់ ដែលចាំបាច់សម្រាប់បង្កើតបទល្មើសព្រហ្មទណ្ឌ និងប្រសិនបើដូច្នេះ ថាតើអ្នកដាក់ពាក្យសុំមានពិរុទ្ធភាព ហួសពីវិមតិសង្ស័យដែរឬទេ ក្នុងការប្រព្រឹត្តបទល្មើសបែបនេះ [...] ដែលត្រូវពិភាក្សា សម្រេច ឬវាយតម្លៃ [...] ដោយចៅក្រម ដែលអ្នកដាក់ពាក្យសុំចង់ជំទាស់ ចំពោះអនាគតិរបស់គាត់")។

[180] *Miminoshvili* តទល់នឹង *Russia* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) កថាខណ្ឌ ១១៦, ១១៨ *Khodorkovskiy និង Lebedev* តទល់នឹង *Russia* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) កថាខណ្ឌ ៥៤៧-៥៤៩, ៥៥៦ ("សាលក្រមមិនបានវិភាគ ការចូលរួម [របស់អ្នកដាក់ពាក្យ

របស់សហមេធាវីទៅរករឿងក្តី *Ferrantelli និង Santangelo តទល់នឹង ប្រទេសអ៊ីតាលី* និងរឿងក្តី *Rojas Morales តទល់នឹង ប្រទេសអ៊ីតាលី* របស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ដើម្បីគាំទ្រដល់ជំហររបស់ខ្លួននោះ[181] គឺមិនអាចជឿជាក់បានឡើយ ព្រោះរឿងក្តីទាំងអស់នេះ រួមមានទាំងបុរេវិនិច្ឆ័យលើ "សហចារីនៃឧក្រិដ្ឋកម្ម"[182] ឬ "ការរៀបចំផែនការ ឬជម្រុញដល់ឧក្រិដ្ឋកម្ម"[183]។ ហេតុដូច្នេះរឿងក្តីទាំងអស់នោះ គឺខុស

---

សុំ] នៅក្នុងឧក្រិដ្ឋកម្មដែលរងការជំទាស់ឡើយ [...] ហើយមិនបានកំណត់ធាតុផ្សំចម្បង នៃការទទួលខុសត្រូវព្រហ្មទណ្ឌ របស់អ្នកដាក់ពាក្យសុំដែរ។ [...] តុលាការសន្និដ្ឋានថា សាលក្រម [...] មិនមានការសម្រេចដែលបុរេវិនិច្ឆ័យ លើបញ្ហាពិរុទ្ធភាពរបស់ជនជាប់ចោទ ក្នុងកិច្ចដំណើរការនីតិវិធីបន្ទាប់ឡើយ"), តុលាការសិទ្ធិមនុស្សអឺរ៉ុប *Lindon, Otchakovsky-Laurens* និង *July* តទល់នឹង *ប្រទេសបារាំង* សំណើសុំលេខ 21279/02 និង 36448/02សាលក្រម ថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៧ កថាខណ្ឌ ៧៨ ("បន្ថែមលើនេះច្បាស់ណាស់ថា សាលក្រមដែលបានចេញក្នុងរឿងក្តី របស់អ្នកដាក់ពាក្យសុំពីរនាក់ដំបូង មិនមានបុរេវិនិច្ឆ័យណាមួយ អំពីពិរុទ្ធភាពរបស់អ្នកដាក់ពាក្យសុំទីបីឡើយ"), *Schwarzenberger* តទល់នឹង *Germany* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) កថាខណ្ឌ ៤៣ *OOO 'Vesti' និង Ukhov* តទល់នឹង *Russia* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) កថាខណ្ឌ ៧៩-៨០, ៨២ ("ចៅក្រមមិនបានធ្វើការសម្រេចណាមួយ អំពីការទទួលខុសត្រូវរបស់ [...]។ ចៅក្រមក៏មិនបានប្រើប្រាស់ការថ្លែងណាមួយ ដែលអាចបង្កើតបានជាការយល់ឃើញថា គាត់បានកំណត់ទស្សនៈ អំពីការទទួលខុសត្រូវរួចហើយនោះដែរ")។

[181] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ (១) កថាខណ្ឌ ៣៧ និងជើងទំព័រ ៦១។

[182] ក្រុមប្រឹក្សាជំនុំជម្រះពិសេស កត់សម្គាល់ឃើញថា នៅក្នុងរឿងក្តី *Ferrantelli and Santangelo* តទល់នឹង *ប្រទេសអ៊ីតាលី* តុលាការសិទ្ធិមនុស្សអឺរ៉ុប បានរកឃើញពីភាពលំអៀងរបស់ចៅក្រម ដោយសារតែនៅក្នុងសាលក្រមពីមុន ចៅក្រមដែលរងបណ្តឹងបានយោងទៅរក អ្នកដាក់ពាក្យសុំថាជា "សហចារីនៃឧក្រិដ្ឋកម្មទ្វេ" ហើយលើកឡើងអំពី "ចម្លើយយ៉ាងល្អច្បាស់លាស់របស់ G.V.ដែលថា G.G.រួមជាមួយ Santangelo [អ្នកដាក់ពាក្យសុំ] ត្រូវទទួលខុសត្រូវចំពោះ ការអនុវត្តដោយផ្ទាល់នូវអំពើមនុស្សឃាត" ព្រមទាំងបានសម្រេចថា "Ferrantelli [អ្នកដាក់ពាក្យសុំ] បានជួយស្វែងរកបន្ទាយ និងជួយដឹកសម្ភារៈ"។ *សូមមើល Ferrantelli និងSantangelo* តទល់នឹង *ប្រទេសអ៊ីតាលី*(តុលាការសិទ្ធិមនុស្សអឺរ៉ុប) កថាខណ្ឌ ៥៩-៦០។

[183] ក្រុមប្រឹក្សាជំនុំជម្រះពិសេស កត់សម្គាល់ថានៅក្នុងរឿងក្តី *Rojas Morales* តទល់នឹង *ប្រទេសអ៊ីតាលី* តុលាការសិទ្ធិមនុស្សអឺរ៉ុប បានរកឃើញការរំលោភបំពានទៅលើសិទ្ធិ ទទួលបានការជំនុំជម្រះដោយតុលាការអព្យាក្រិត ដោយសារតែចៅក្រមដែលរងបណ្តឹង បានចេញសាលក្រមប្រឆាំងសហជនជាប់ចោទ របស់អ្នកដាក់ពាក្យសុំ ដោយលើកឡើងអំពីតួនាទី របស់អ្នកដាក់ពាក្យសុំនៅក្នុងអង្គការឧក្រិដ្ឋ ហើយយោងទៅរកអ្នកដាក់ពាក្យសុំថាជា "អ្នករៀបផែនការ ឬអ្នកជម្រុញ" ឧក្រិដ្ឋកម្មដែលរងការចោទ ដែលសហជនជាប់ចោទត្រូវផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មនោះ។ សូមមើល *Rojas Morales* តទល់នឹង *ប្រទេសអ៊ីតាលី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) កថាខណ្ឌ ៣៣-៣៤។

ប្លែកពីរឿងក្តី *Poppe តទល់នឹង ប្រទេសហូឡង់*[184] ហើយនិងយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ស្តីពីអនាគតិរបស់ចៅក្រម[185]។

៦៩. ពាក់ព័ន្ធនឹងការយោងរបស់សហមេធាវី ទៅលើរឿងក្តី *Mancel និង Blanquart តទល់នឹង ប្រទេសបារាំង* ក្រុមប្រឹក្សាជំនុំជម្រះពិសេសកត់សម្គាល់ថា តុលាការសិទ្ធិមនុស្សអឺរ៉ុបបានរកឃើញ ការរំលោភបំពានទៅលើសិទ្ធិ ទទួលបានការជំនុំជម្រះ ដោយតុលាការអព្យាក្រិត នៅក្នុងរឿងក្តីនោះ ព្រោះចៅក្រមប្រាំពីររូប ក្នុងចំណោមចៅក្រមប្រាំបួនរូប នៃតុលាការកំពូល បានកំណត់ប្រភេទនៃ "ធាតុផ្សំសត្យានុម័ត និងអត្តនោម័ត នៃបទល្មើស" នៅក្នុងសេចក្តីសម្រេចរបស់ពួកគេ ក្នុងបណ្តឹងសាទុក្ខលើកទីមួយ ហើយបន្ទាប់មកត្រូវបានចាត់តាំង ឱ្យជំនុំជម្រះលើបណ្តឹងសាទុក្ខលើកទីពីរ ក្នុងរឿងក្តីដដែល ពាក់ព័ន្ធបទល្មើសដែលបានលើកឡើងខាងលើ [186] ។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសពិចារណាថា ស្ថានភាពក្នុងរឿងក្តី

---

[184] *Poppe តទល់នឹង ប្រទេសហូឡង់* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) កថាខណ្ឌ ២៨ ("មិនមានគុណវុឌ្ឍិជាក់លាក់ អំពីការចូលរួមរបស់អ្នកដាក់ពាក្យសុំ ឬអំពីអំពើដែលគាត់បានប្រព្រឹត្ត ទោះជាអំពើឧក្រិដ្ឋ ឬផ្សេងយ៉ាងណាក្តី។ ក្នុងករណីនេះ អង្គហេតុរបស់រឿងក្តីអ្នកដាក់ពាក្យសុំ គឺខុសពីអង្គហេតុរបស់ *Ferrantelli និង Santangelo* និង *Rojas Morales*")។ ក្រុមប្រឹក្សាជំនុំជម្រះពិសេស កត់សម្គាល់ឃើញថា នៅក្នុងរឿងក្តីដទៃ ពាក់ព័ន្ធបុរេវិនិច្ឆ័យ តុលាការសិទ្ធិមនុស្សអឺរ៉ុប ក៏បានញែកផងដែររវាង ស្ថានភាពនៅក្នុង *Ferrantelli និង Santangelo* និង *Rojas Morales*។ សូមមើល *Schwarzenberger* តទល់នឹង *Germany* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) កថាខណ្ឌ ៤៤-៤៥ *Miminoshvili* តទល់នឹង *Russia* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) កថាខណ្ឌ ១១៥-១១៦។ សូមមើលផងដែរ សេចក្តីសម្រេចលើ សំណើសុំប្តឹងជំទាស់ (ឯកសារ E55/4) កថាខណ្ឌ ២១ និងជើងទំព័រ ៤៥, សំណុំរឿង ០០២/២ សេចក្តីសម្រេចលើ សំណើសុំប្តឹងជំទាស់ (ឯកសារ E314/12/1) កថាខណ្ឌ ៤៤។

[185] *Khodorkovskiy និង Lebedev* តទល់នឹង *Russia* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) កថាខណ្ឌ ៥៤៤ ("នៅក្នុងរឿងក្តីថ្មីៗនេះ តុលាការបានបញ្ជាក់បំភ្លឺ អំពីជំហររបស់ខ្លួន និងបានសម្រេចថា ត្រឹមអង្គហេតុដែលថាចៅក្រម បានជំនុំជម្រះរួចហើយលើសហជនជាប់ចោទ គឺមិនមានភាពគ្រប់គ្រាន់ឡើយ ដើម្បីបង្កើតជាមន្ទិលសង្ស័យ លើអនាគតិរបស់ចៅក្រម នៅក្នុងរឿងក្តីរបស់អ្នកដាក់ពាក្យសុំនោះ។ [...] ទោះជាយ៉ាងណាក្តី ទាមទារចាំបាច់នូវការត្រួតពិនិត្យ ដើម្បីសម្រេចថាតើសាលក្រមលើកមុន មានការសម្រេចដែលពិតជាបុរេវិនិច្ឆ័យ ទៅលើបញ្ហាពិរុទ្ធភាពរបស់ អ្នកដាក់ពាក្យសុំដែរឬទេ") *Miminoshvili* តទល់នឹង *Russia* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) កថាខណ្ឌ ១១៥-១១៦ ("តុលាការបានផ្តល់សំអាងហេតុកាន់តែលម្អិត [...] ដែលសម្រេចថាជាកត្តាកំណត់ដែល [...] ចៅក្រមជំនុំជម្រះមិនបានពិភាក្សា សម្រេច ឬវាយតម្លៃថាតើ ការចូលរួមរបស់អ្នកដាក់ពាក្យសុំ បានបំពេញគ្រប់លក្ខខណ្ឌតម្រូវពាក់ព័ន្ធ ដែលចាំបាច់សម្រាប់បង្កើតបានជា បទល្មើសព្រហ្មទណ្ឌដែរឬទេ និងប្រសិនបើដូច្នេះមែន ថាតើអ្នកដាក់ពាក្យសុំមានពិរុទ្ធភាពដែរឬទេ ចំពោះការប្រព្រឹត្តបទល្មើសបែបនេះ") (ដោយគូសបញ្ជាក់បន្ថែម), *Poppe តទល់នឹង ប្រទេសហូឡង់* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) កថាខណ្ឌ ២៦ *OOO 'Vesti' និង Ukhov* តទល់នឹង *Russia* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) កថាខណ្ឌ ៧៦-៧៧។

[186] *Mancel and Branquart* តទល់នឹង *ប្រទេសបារាំង* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) កថាខណ្ឌ ៣៩។

*Mancel និង Blanquart តទល់នឹង ប្រទេសបារាំង* គឺខុសប្លែកពីករណីបច្ចុប្បន្ន ព្រោះសំណុំរឿង០០២/២ ទាក់ទងឧក្រិដ្ឋកម្ម ទីតាំងឧក្រិដ្ឋកម្ម និងបណ្ដុំភស្តុតាងដែលខុសប្លែកពីសំណុំរឿង០០២/១[187]។ ហេតុដូច្នេះ ក្រុមប្រឹក្សាជំនុំជម្រះពិសេសយល់ឃើញថា ទឡ្ហីករណ៍របស់សហមេធាវី ទាក់ទងយុត្តិសាស្ត្រពាក់ព័ន្ធ គឺមិនអាចជឿជាក់បានឡើយ។

៧០. ក្រុមប្រឹក្សាជំនុំជម្រះពិសេស សូមបញ្ជាក់សារជាថ្មី ចំពោះលក្ខណៈវិនិច្ឆ័យសម្រាប់បុរេវិនិច្ឆ័យ ដែលបានអនុវត្តដោយក្រុមប្រឹក្សាជំនុំជម្រះពិសេស នៃអង្គជំនុំជម្រះសាលាដំបូង គឺថាតើ "សំអាងហេតុនៅក្នុងរឿងក្ដីនាពេលមុនៗ បង្ហាញការសន្មតនូវការទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះបទចោទនានា ដែលត្រូវវិនិច្ឆ័យនៅក្នុងរឿងក្ដីក្រោយៗដែរឬទេ" [188] ហើយក្រុមប្រឹក្សាជំនុំជម្រះពិសេសនិងត្រួតពិនិត្យ លើទឡ្ហីករណ៍របស់សហមេធាវី លើបណ្ដឹងជំទាស់។

៧១. ជាដំបូង ចំពោះការចោទប្រកាន់អំពីការរំលោភបំពានទៅលើសិទ្ធិ ទទួលបានការជំនុំជម្រះដោយតុលាការអព្យាក្រឹត ដោយសារតែការត្រួតគ្នា នៃសំណុំរឿង០០២/១ និងសំណុំរឿង០០២/២ ដែលបណ្ដាលមកពីការបំបែកកិច្ចដំណើរការនីតិវិធី សំណុំរឿង០០២នោះ[189] ក្រុមប្រឹក្សាជំនុំជម្រះពិសេសកត់សម្គាល់ថា បរិបទនៃកាលៈទេសៈពិសេស នៃការបំបែកកិច្ចដំណើរការនីតិវិធី សំណុំរឿង០០២ ត្រូវបានដោះស្រាយនិងស្រាយបំភ្លឺជាច្រើនលើករួចហើយ ដោយអង្គជំនុំជម្រះនានារបស់ អ.វ.ត.ក[190]។ អាស្រ័យហេតុនេះ ក្រុមប្រឹក្សាជំនុំជម្រះពិសេសសូមរំឭកថា ទោះបីជាមានបញ្ហាត្រួតគ្នាខ្លះៗក្ដី សំណុំរឿង០០២/១ និងសំណុំរឿង ០០២/២ គឺពាក់ព័ន្ធជាមួយហេតុការណ៍ផ្សេងគ្នាយ៉ាងច្បាស់ក្រឡែត[191]។ ជាពិសេសនោះ សំណុំរឿង០០២/១ កម្រិតត្រឹមការចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងពីរដំណាក់កាល នៃការផ្លាស់ទី

---

[187] សូមមើលខាងក្រោម កថាខណ្ឌ ៧១។

[188] សំណុំរឿង ០០២/២ សេចក្ដីសម្រេចលើ សំណើសុំប្ដឹងជំទាស់ (ឯកសារ E314/12/1) កថាខណ្ឌ ៧០, ៨១ *យោងទៅរក*សំណុំរឿង ០០២ សេចក្ដីសម្រេចលើកទីបី បំបែកកិច្ចដំណើរការនីតិវិធី (ឯកសារ E301/9/1/1/3) កថាខណ្ឌ ៨៥។

[189] សំណើរបស់ ខៀវ សំផន ប្ដឹងជំទាស់ (១) កថាខណ្ឌ ៤២-៥៩។

[190] ផ្ទុយ សំណើរបស់ ខៀវ សំផន ប្ដឹងជំទាស់ (១) កថាខណ្ឌ ៤៣-៤៦។ *សូមមើល* សំណុំរឿង ០០២/២ សេចក្ដីសម្រេចលើសំណើសុំប្ដឹងជំទាស់ (ឯកសារ E314/12/1) កថាខណ្ឌ ៤៩-៥៤, ៩៣, ៩៥-៩៦ សំណុំរឿង ០០២ សេចក្ដីសម្រេចលើកទីបី បំបែកកិច្ចដំណើរការនីតិវិធី (ឯកសារ E301/9/1/1/3) កថាខណ្ឌ ៦៣-៨៦, សំណុំរឿង ០០២/១ សេចក្ដីសម្រេចលើសំណើរបស់ ខៀវ សំផន សុំពន្យាពេលការចាប់ផ្ដើម សវនាការលើសំណុំរឿង ០០២/០២ រហូតដល់មានសាលក្រមស្ថាពរ លើសំណុំរឿង ០០២/០១ ឯកសារ E301/5/5/1 ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៤ កថាខណ្ឌ ១២។

[191] *សូមមើល*សំណុំរឿង ០០២/២ សេចក្ដីសម្រេចលើ សំណើសុំប្ដឹងជំទាស់ (ឯកសារ E314/12/1) កថាខណ្ឌ ៩៣។

លំនៅប្រជាជនដោយបង្ខំ និងការសម្លាប់អតីតអ្នករដ្ឋការសាធារណរដ្ឋខ្មែរ ដែលបានប្រព្រឹត្តឡើងនៅទួលពោធិ៍ជ្រៃ ភ្លាមៗបន្ទាប់ពីមានការជម្លៀសចេញពីទីក្រុងភ្នំពេញ[192] ដែលការនេះផ្ទុយពីសំណុំរឿង ០០២/២ ដែលគ្របដណ្ដប់តែទៅលើចំណុចដូចតទៅ៖ អំពើប្រល័យពូជសាសន៍ប្រឆាំង ជនជាតិវៀតណាមនិងជនជាតិចាម, ឧក្រិដ្ឋកម្មដែលកើតឡើងនៅ មន្ទីរសន្តិសុខស-២១ ក្រាំងតាចាន់ អូរកន្សែង និងភ្នំក្រោល, ឧក្រិដ្ឋកម្មដែលកើតឡើងនៅ ការដ្ឋានទំនប់ត្រពាំងថ្ម និង១មករា សហករណ៍ត្រាំកក់ ព្រលានយន្តហោះកំពង់ឆ្នាំង, ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទ នៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការបោសសម្អាតផ្ទៃក្នុង[193]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសសូមរំឭកថា នៅពេលដែលបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង០០២ អង្គជំនុំជម្រះតុលាការកំពូល បានផ្ដល់ការស្រាយបំភ្លឺពាក់ព័ន្ធ ផលវិបាកនីតិវិធីនៃការបំបែក កិច្ចដំណើរការនីតិវិធី ដោយបញ្ជាក់លម្អិតថា ទោះបីជាភស្តុតាងអាចមានភាពដូចគ្នាក្នុងសំណុំរឿង ០០២/១ និងសំណុំរឿង ០០២/២ ក្ដី តែធាតុផ្សំអង្គហេតុក្នុងសំណុំរឿងទាំងពីរ ចាំបាច់ត្រូវតែបង្កើតឡើងជាថ្មី[194]។ ហេតុដូច្នេះក្រុមប្រឹក្សាជំនុំជម្រះពិសេស កត់សម្គាល់បន្ថែមទៀតថា នឹងមានភាពខុសគ្នាខ្លាំងរវាង ភស្តុតាងនៅក្នុងសំណុំរឿងមួយៗ រួមទាំងបញ្ជីឯកសារ និងសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញជាច្រើន ដែលកន្លងមកមិនបានដាក់មកឡើយ សម្រាប់សំណុំរឿង០០២/២[195]។

---

[192] សំណុំរឿង ០០២ សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី (ឯកសារ E284) ផ្នែកសម្រេចសេចក្ដី ទំព័រ ៧០។

[193] សំណុំរឿង ០០២ សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម (ឯកសារ E301/9/1) កថាខណ្ឌ ២១។

[194] សំណុំរឿង ០០២ សេចក្ដីសម្រេចលើកទីបី បំបែកកិច្ចដំណើរការនីតិវិធី (ឯកសារ E301/9/1/1/3) កថាខណ្ឌ ៨៣, ៨៥, ៨៦។ *សូមមើលផងដែរ* តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង Milošević* IT-99-37-AR73, IT-01-50-AR73, IT-OI-51-AR73 សំអាងហេតុសម្រាប់សេចក្ដីសម្រេចលើ បណ្ដឹងសាទុក្ខបន្ទាន់បង្ខំរបស់រដ្ឋអាជ្ញា ប្រឆាំងការបដិសេធមិនចេញដីការួម អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០២ កថាខណ្ឌ ២៩ ("ប្រសិនបើត្រូវទទួលយកភស្តុតាង នៅក្នុងតុលាការកូសូវ៉ូ ដែលជាបុរេវិនិច្ឆ័យលើជនជាប់ចោទ ក្នុងការជំនុំជម្រះ Croatia និង Bosnia សមាជិកនៃអង្គជំនុំជម្រះសាលាដំបូង ក្នុងនាមជាចៅក្រមវិជ្ជាជីវៈ នឹងអាចដកចេញនូវភស្តុតាងបុរេវិនិច្ឆ័យ ពីចិត្តគំនិតរបស់ខ្លួន នៅពេលដែលពួកគាត់ធ្វើការសម្រេចលើ ការជំនុំជម្រះ Croatia និង Bosnia trial")។

[195] *សូមមើលជាឧទាហរណ៍* សំណុំរឿង ០០២/២ ឯកសារស្នើឡើងដោយមេធាវីការពារក្ដី ខៀវ សំផន សម្រាប់សំណុំរឿង ០០២/០២ ឯកសារ E305/12 ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ សំណុំរឿង ០០២/២ បញ្ជីឯកសារសវនាការរបស់ សហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៨0(៣) នៃវិធានផ្ទៃក្នុង ឯកសារ E305/13 ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ សំណុំរឿង ០០២/២ បញ្ជីឯកសារនិងវត្ថុតាង របស់សហមេធាវីនាំមុខ តំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានធ្វើបច្ចុប្បន្នភាព ស្របតាមវិធាន៨0 សម្រាប់សំណុំរឿង ០០២/០២ ជាមួយឧបសម្ព័ន្ធសម្ងាត់ V ឯកសារ E305/14 ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ សំណុំរឿង ០០២/២ សំណើរបស់សហមេធាវីនាំមុខ តំណាងដើមបណ្ដឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨៧(៤) ដែលស្នើសុំទទួលយកជាភស្ដុ

៧២. លើសពីនេះទៅទៀត ក្រុមប្រឹក្សាជំនុំជម្រះពិសេសកត់សម្គាល់ថា សំអាងហេតុជាចម្បង សម្រាប់អនុសាសន៍របស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរ គឺដើម្បីធានានូវយុត្តិធម៌ប្រកបដោយអត្ថន័យ តាមរយៈការទទួលបានសាលក្រម នៅក្នុងពេលជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះក្នុងសំណុំរឿង០០២ នៅមានជីវិត[196]។ ព្យសនកម្មដែលកើតអាចមាន[197] ចំពោះសិទ្ធិរបស់ជនជាប់ចោទ ដោយបណ្តាលមកពីភាពលំអៀងរបស់ចៅក្រម គឺជាកត្តាមួយក្នុងចំណោមកត្តាជាច្រើន ដែលត្រូវបានពិចារណា ដើម្បីធានាពីផលប្រយោជន៍យុត្តិធម៌ ជាពិសេសនៅក្នុងបរិបទ ការគ្រប់គ្រង និងប្រសិទ្ធិភាពតុលាការ[198]។ ជាចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូល បានអះអាងថា ការទទួលបានសាលក្រមនៅក្នុងពេល ជនជាប់ចោទនៅមានជីវិត មានអាទិភាពលើក្តីបារម្ភនានា នៅក្នុងការជំនុំជម្រះនាពេលខាងមុខ នៃសំណុំរឿង ០០២/១ និង ០០២/២[199]។

---

តាង នូវសក្ខីកម្មផ្ទាល់មាត់ និងឯកសារ ព្រមទាំងវត្ថុតាង ដែលពាក់ព័ន្ធនឹងសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានស្នើសុំឱ្យមកផ្តល់សក្ខីកម្ម ក្នុងសំណុំរឿង ០០២/០២ ឯកសារ E307/6 ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ សំណុំរឿង ០០២/២ បញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា និងសេចក្តីសង្ខេបសម្រាប់ជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ (ជាមួយឧបសម្ព័ន្ធសម្ងាត់ចំនួន ៥៖ I, II, IIក, III និងIIIA) ឯកសារ E305/6 ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៤ សំណុំរឿង ០០២/២ សំណើរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងសាក្សីដែលបានស្នើសុំ សម្រាប់សវនាការ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សម្រាប់សំណុំរឿង ០០២/០២ ឯកសារ E307/3/2 ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៤បញ្ជីរបស់សហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្តីពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០ សម្រាប់សំណុំរឿង ០០២/០២ រួមជាមួយឧបសម្ព័ន្ធសម្ងាត់ ឯកសារ E305/7 ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៤ សំណុំរឿង ០០២/២ សេចក្តីសម្រេចស្តីពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលត្រូវបានស្នើសុំស្តាប់សក្ខីកម្ម នៅក្នុងសំណុំរឿង ០០២/០២ ឯកសារ E459 ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧, សំណុំរឿង ០០២/២ សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំដាក់ភស្តុតាងបន្ថែម ឯកសារ F51/3 ថ្ងៃទី៦ ខែមករា ឆ្នាំ២០២០។

[196] ផ្ទុយ សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ចៅក្រម (១) កថាខណ្ឌ ៤៧-៥០។*សូមមើល* សំណុំរឿង ០០២ សេចក្តីសម្រេចលើកទីមួយ បំបែកកិច្ចដំណើរការនីតិវិធី (ឯកសារ E163/5/1/13) កថាខណ្ឌ ៥១, សំណុំរឿង ០០២ សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីលើកទីបី (ឯកសារ E301/9/1/1/3) កថាខណ្ឌ ៥៣-៥៥, ៦១-៦២។

[197] អង្គជំនុំជម្រះតុលាការកំពូល បានបញ្ជាក់យ៉ាងច្បាស់ថា នៅពេលនោះ "បញ្ហានៃភាពលំអៀង ពុំទាន់កើតឡើង ដែលជាការប៉ះពាល់ដល់សិទ្ធិជាក់ច្បាស់នៅឡើយទេ" ។ *សូមមើល* សំណុំរឿង ០០២ សេចក្តីសម្រេចលើកទីបី បំបែកកិច្ចដំណើរការនីតិវិធី (ឯកសារ E301/9/1/1/3) កថាខណ្ឌ ៨៥។

[198] សំណុំរឿង ០០២ សេចក្តីសម្រេចលើកទីពីរ បំបែកកិច្ចដំណើរការនីតិវិធី (ឯកសារ E284/4/8) កថាខណ្ឌ ៤៤-៤៦។

[199] សំណុំរឿង ០០២ សេចក្តីសម្រេចលើការបំបែក កិច្ចដំណើរការនីតិវិធីលើកទីបី (ឯកសារ E301/9/1/1/3) កថាខណ្ឌ ៥៣-៥៥, ៩០។

៧៣. សម្រាប់ការចោទប្រកាន់អំពី ការត្រួតគ្នាជាចម្បងនៃបញ្ហាអង្គហេតុនិងអង្គច្បាប់ សហមេធាវីពឹងផ្អែកទៅលើមតិជំទាស់មួយផ្នែករបស់ចៅក្រម DOWNING ហើយអះអាងថា ក្រុមប្រឹក្សាជំនុំជម្រះពិសេស នៃអង្គជំនុំជម្រះសាលាដំបូង មិនបានអនុវត្តវិធីសាស្ត្រដែលធានាអំពី សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការអព្យាក្រឹត និងការពារសុចរិតភាពរបស់ កិច្ចដំណើរការនីតិវិធីឡើយ[200]។ ទឡ្ហីករណ៍នេះត្រូវបានជំទាស់ដោយ បទដ្ឋានដែលមានជាធរមាន ដែលក្រុមប្រឹក្សាជំនុំជម្រះពិសេសបានអនុម័តយក ដូចបានពិភាក្សានៅផ្នែកខាងលើ[201]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសសូមរំឭកថា មានការសន្មតថា ដោយផ្អែកលើការបណ្ដុះបណ្ដាល និងបទពិសោធន៍របស់ខ្លួន ចៅក្រមអាចអាចកែប្រែចិត្តគំនិតរបស់ខ្លួន ចំពោះជំនឿ ឬការរៀបចំជាមុន ជាលក្ខណៈផ្ទាល់ខ្លួន ដែលមិនពាក់ព័ន្ធនានា[202] ហើយក្រុមប្រឹក្សាជំនុំជម្រះពិសេស សូមបញ្ជាក់ឡើងវិញថា ត្រឹមតែអត្ថិភាពនៃបញ្ហាត្រួតគ្នា ដោយមិនបង្កើតបានជា ការទទួលខុសត្រូវព្រហ្មទណ្ឌទេនោះ គឺមិនគ្រប់គ្រាន់ដើម្បីជំទាស់ ចំពោះសច្ចធារណ៍នៃអនាគតិរបស់ចៅក្រមឡើយ[203]។ ការចោទប្រកាន់ដែលគ្មានមូលដ្ឋាន និងគ្មានការគាំទ្រអំពី ភាពលំអៀងជាក់ស្ដែង ដោយសហមេធាវីនេះ មិនអាចផ្ដល់យុត្តិកម្មសម្រាប់ការប្ដឹងជំទាស់ ឬការចាកចេញដោយស្ម័គ្រចិត្ត របស់ចៅក្រមដែលរងបណ្ដឹងឡើយ[204]។

៧៤. ហេតុដូច្នេះ ក្រុមប្រឹក្សាជំនុំជម្រះពិសេសយល់ឃើញថា សហមេធាវីមិនបានបង្ហាញថា អ្នកសង្កេតការណ៍ដែលមានហេតុផលម្នាក់ នឹងពិចារណាថា ចៅក្រមដែលរងបណ្ដឹង នឹងមិនមានអនាគតិ ក្នុងការកាត់សេចក្ដីលើបណ្ដឹងសាទុក្ខ ក្នុងសំណុំរឿង០០២/២ ក្នុងបរិបទនៃបញ្ហាត្រួតគ្នា នៃសំណុំរឿង០០២/១ និងសំណុំរឿង០០២/២ ឡើយ។

៧៥. ទីពីរ ពាក់ព័ន្ធការចោទប្រកាន់ទៅលើ ការរំលោភសិទ្ធិក្នុងការប្ដឹងសាទុក្ខ ក្រុមប្រឹក្សាជំនុំជម្រះពិសេសសូមរំឭកថា ពេលខ្លះចៅក្រមចូលរួមក្នុងសវនាការជាច្រើន ដែលតាមលក្ខណៈនោះ គឺគ្រប់ដណ្ដប់

[200] សំណើរបស់ ខៀវ សំផន ប្ដឹងជំទាស់ (១) កថាខណ្ឌ ៥១-៥២ *យោងទៅរក*សំណុំរឿង ០០២/២ សេចក្ដីសម្រេចលើ សំណើសុំប្ដឹងជំទាស់ (ឯកសារ E314/12/1) សំណុំរឿង ០០២/២ សេចក្ដីសម្រេចលើ សំណើសុំប្ដឹងជំទាស់ (ឯកសារ E314/12/1) មតិជំទាស់ដោយផ្នែករបស់ចៅក្រម DOWNING កថាខណ្ឌ ៣។

[201] *សូមមើល ខាងលើ* កថាខណ្ឌ ៦៣-៦៤។

[202] សាលដីការឿងក្ដី Furundžija (តុលាការ ICTY), កថាខណ្ឌ ១៩៧ សាលដីការឿងក្ដី *Nahimana និងអ្នកដទៃទៀត* (តុលាការ ICTR) កថាខណ្ឌ ៤៨, ៧៨ សាលដីការឿងក្ដី *Akayesu* (តុលាការ ICTR) កថាខណ្ឌ ២៦៩ សាលដីការឿងក្ដី *Renzaho* (តុលាការ ICTR) កថាខណ្ឌ ២៣។

[203] *សូមមើល ខាងលើ* កថាខណ្ឌ ៧០។

[204] ផ្ទុយពីនេះ សំណើរបស់ ខៀវ សំផន ប្ដឹងជំទាស់ (១) កថាខណ្ឌ ៥៣-៥៥។

ទៅលើបញ្ហា ដែលមានភាពត្រួតគ្នា [205] ។ លើសពីនេះក្រុមប្រឹក្សាជំនុំជម្រះពិសេស បញ្ជាក់ឡើងវិញថា "ចៅក្រមមិនអាចត្រូវប្តឹងជំទាស់ មិនឲ្យជំនុំជម្រះលើសវនាការព្រហ្មទណ្ឌ ពីរឬច្រើន ដែលកើតចេញពីបណ្តុំព្រឹត្តិការណ៍ដូចគ្នា ដែលចៅក្រមរូបនោះ បានទទួលភស្តុតាងទាក់ទង ព្រឹត្តិការណ៍ទាំងអស់នេះ ក្នុងរឿងក្តីទាំងពីរឡើយ" [206] ។ ក្នុងករណីបច្ចុប្បន្ន ទោះបីជាក្រុមប្រឹក្សាជំនុំជម្រះពិសេស យល់ស្របជាមួយសហមេធាវីដែលថា កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង០០២/២ នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល បង្កើតបានជាករណីស្ពាពរចុងក្រោយសម្រាប់ ខៀវ សំផន ក្តី[207] ប៉ុន្តែត្រឹមតែការពិតដែលថា ចៅក្រមដែលរងបណ្តឹង បានសម្រេចសេចក្តីនៅក្នុងសំណុំរឿង ០០២/១ មិនបានជំទាស់ចំពោះអនាគតិរបស់ពួកគាត់ឡើយ[208]។

៧៦. សហមេធាវីបានដកស្រង់ សេចក្តីសម្រេចលើបណ្តឹងជំទាស់ក្នុងរឿងក្តី *Mladić* របស់ចៅក្រម ANTONETTI [209] ហើយបានលើកទឡ្ហីករណ៍ថា មិនអាចទៅរួចឡើយដែល ចៅក្រមដែលរងបណ្តឹង ត្រូវជំនុំជម្រះលើបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង ០០២/២ ដោយមិនទទួលរងឥទ្ធិពល ពីភស្តុតាងដាក់បន្ទុកដែលពួកគាត់ បានវាយតម្លៃប្រឆាំង ខៀវ សំផន និងដោយការសម្រេចដែលពួកគាត់ បានសម្រេចក្នុងសំណុំរឿង ០០២/១។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសកត់សម្គាល់ថា ការទទួលបានភស្តុតាងក្នុងសំណុំរឿង ០០២/១ គឺ

---

[205] សេចក្តីសម្រេចលើ សំណើសុំប្តឹងជំទាស់ (ឯកសារ E55/4) កថាខណ្ឌ ១៥ សាលដីការឿងក្តី *Karera* (តុលាការ ICTR) កថាខណ្ឌ ៣៧៨ សាលដីការឿងក្តី *Nahimana និងអ្នកដទៃទៀត* (តុលាការ ICTR) កថាខណ្ឌ ៧៨ *Sesay និងអ្នកដទៃទៀត* (តុលាការ SCSL) កថាខណ្ឌ ៥៥ សេចក្តីសម្រេចលើសំណើរបស់ Kordić និង Čerkez (តុលាការ ICTY)។

[206] សាលដីការឿងក្តី *Nahimana និងអ្នកដទៃទៀត* (តុលាការ ICTR) កថាខណ្ឌ ៧៨ *យោងទៅរក*សេចក្តីសម្រេចលើសំណើរបស់ Kordić និង Čerkez (តុលាការ ICTY)។

[207] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ (១) កថាខណ្ឌ ៥៦។

[208] *សូមមើល* តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹងStanišić and Župljanin* IT-08-91-A សេចក្តីសម្រេចលើសំណើសុំឲ្យដកខ្លួនចេញ ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៣ 2013 ("សេចក្តីសម្រេចលើរឿងក្តី Stanišić និង Župljanin (តុលាការ ICTY)") កថាខណ្ឌ ២៣ ("ជាច្រើនលើកដែលអង្គជំនុំជម្រះ បានសង្កេតឃើញថា ការស្តែងចេញដោយសមហេតុផល នូវភាពលំអៀងរបស់ចៅក្រម នៅក្នុងសំណុំរឿង នឹងមិនកើតឡើងដោយគ្រាន់តែដោយសារ ចៅក្រមបានដោះស្រាយកន្លងមកលើភស្តុតាង ដែលទាក់ទងទៅនឹងអង្គហេតុតែមួយ ក្នុងរឿងក្តីដទៃឡើយ") *យោងទៅរក*សាលដីការឿងក្តី *Galić* (តុលាការ ICTY) កថាខណ្ឌ ៤៤ សេចក្តីសម្រេចលើ Karadzić (តុលាការ ICTY), កថាខណ្ឌ ២៤ តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹងBrđanin* IT-99-36-R77 សេចក្តីសម្រេចលើសំណើសុំ ប្តឹងជំទាស់ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៤ កថាខណ្ឌ ១៣ សាលដីការឿងក្តី *Karera* (តុលាការ ICTR) កថាខណ្ឌ ៣៧៨។

[209] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ (១) កថាខណ្ឌ ៥៧ *យោងទៅរក*សេចក្តីសម្រេចលើបណ្តឹងជំទាស់ Mladić កថាខណ្ឌ ៤៩, ៦៧។

មិនអាចផ្តល់ជាមូលដ្ឋាន សម្រាប់ការស្តែងចេញដោយសមហេតុផលណាមួយ នូវភាពលំអៀងរបស់ចៅក្រមដែលរងបណ្តឹងឡើយ[210]។ មានការសន្មតថា ក្នុងករណីមិនមានភស្តុតាងផ្ទុយពីនេះទេ ដោយផ្អែកលើការបណ្តុះបណ្តាល និងបទពិសោធន៍ ចៅក្រមអាចអាចកែប្រែចិត្តគំនិតរបស់ខ្លួន ចំពោះជំនឿ ឬរៀបចំជាមុន ជាលក្ខណៈផ្ទាល់ខ្លួន ដែលមិនពាក់ព័ន្ធនានា[211]។ សហមេធាវីមិនបានផ្តល់ភស្តុតាងរឹងមាំណាមួយដើម្បីគាំទ្រដល់ចម្លើយដែលអះអាងថា អង្គជំនុំជម្រះតុលាការកំពូល "ស្ទើរតែទាំងស្រុង" នឹងសម្រេចផ្តន្ទាទោស ខៀវ សំផន ដែលធ្វើឱ្យសិទ្ធិក្នុងការប្តឹងសាទុក្ខរបស់គាត់ ទៅជាលែងមានប្រសិទ្ធភាព[212]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេស មិនជឿជាក់តាមការអះអាងរបស់សហមេធាវីដែលថា ខៀវ សំផន នឹងមិនអាចប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាព នូវសិទ្ធិប្តឹងសាទុក្ខរបស់គាត់ ក្នុងសំណុំរឿង០០២/២ ប្រសិនបើចៅក្រមដែលរងបណ្តឹង មិនត្រូវបានប្តឹងជំទាស់ចិត្តនោះ[213]។ ហេតុដូច្នេះក្រុមប្រឹក្សាជំនុំជម្រះពិសេសយល់ឃើញថា សហមេធាវីមិនបានកំណត់ថា អ្នកសង្កេតការណ៍ដែលមានហេតុផលម្នាក់ នឹងយល់ឃើញថា ចៅក្រមដែលរងបណ្តឹង មិនអាចប្រើប្រាស់ចិត្តឥតលំអៀងរបស់ខ្លួន សម្រាប់សំណុំរឿង០០២/២ ឡើយ។

៧៧. ជាចុងក្រោយ ក្រុមប្រឹក្សាជំនុំជម្រះពិសេស នឹងពិនិត្យលើការជំទាស់របស់សហមេធាវី ចំពោះការត្រួតគ្នាលើការសម្រេចអង្គហេតុ និងអង្គច្បាប់ ក្នុងសាលដីកាសំណុំរឿង០០២/១ និងបញ្ហានៃបុរេវិនិច្ឆ័យ។ សហមេធាវីបានលើកឡើងថា ចៅក្រមដែលរងបណ្តឹង បានធ្វើការសម្រេចលើអង្គហេតុនិងអង្គច្បាប់ ពាក់ព័ន្ធការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន[214]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេស នឹងអនុវត្តបទដ្ឋាន

---

[210] *សូមមើល* តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹងSešelj* IT-03-67-T ដីកាសម្រេចលើសំណើរបស់រដ្ឋអាជ្ញា ប្តឹងជំទាស់ចិត្តចៅក្រម Frederik Harhoff ថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៨ កថាខណ្ឌ ២៤-២៥ សេចក្តីសម្រេចលើរឿងក្តី Stanišić និង Župljanin (តុលាការ ICTY) កថាខណ្ឌ ២៣ សាលដីការឿងក្តី *Nahimana និងអ្នកដទៃទៀត* (តុលាការ ICTR) កថាខណ្ឌ ៧៨-៧៩, ៨៤-៨៥ សាលដីការឿងក្តី *Akayesu* (តុលាការ ICTR) កថាខណ្ឌ ២៦៩។

[211] សាលដីការឿងក្តី Furundžija (តុលាការ ICTY) កថាខណ្ឌ ១៩៧ សាលដីការឿងក្តី *Nahimana និងអ្នកដទៃទៀត* (តុលាការ ICTR) កថាខណ្ឌ ៤៨, ៧៨ សាលដីការឿងក្តី *Akayesu* (តុលាការ ICTR) កថាខណ្ឌ ២៦៩ សាលដីការឿងក្តី *Renzaho* (តុលាការ ICTR) កថាខណ្ឌ ២៣។

[212] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ចិត្ត (១) កថាខណ្ឌ ៥៩។

[213] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ចិត្ត (១) កថាខណ្ឌ ៥៩។

[214] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ចិត្ត (១) កថាខណ្ឌ ៦០-៧៥។

សមស្រប សម្រាប់ការប្តឹងជំទាស់ដៅក្រុម[215] ដើម្បីវាយតម្លៃទៅលើសារណា របស់សហមេធាវីដូចខាងក្រោម។

៧៨. សហមេធាវីជំទាស់ចំពោះការសម្រេចលើអង្គហេតុ នៃសាលដីកាសំណុំរឿង ០០២/១ ទាក់ទង៖ គោលនយោបាយឧក្រិដ្ឋដែលរងការចោទប្រកាន់ គឺការបង្កើតសហករណ៍និងការដ្ឋាន, ការកំណត់គោលដៅលើក្រុមជាក់លាក់ នៃអតីតអ្នករដ្ឋការ និងយោធាសាធារណរដ្ឋខ្មែរ, ការសម្លាប់ខ្មាំង, ការចោទប្រកាន់ពីការចូលរួមរបស់ ខៀវ សំផន នៅក្នុងសហឧក្រិដ្ឋកម្មរួម និងការចោទប្រកាន់ពីការដឹងឮរបស់ ខៀវ សំផន អំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត និងអំពីចេតនារបស់គាត់[216]។

៧៩. ចំពោះការចោទប្រកាន់ពីគោលនយោបាយ បង្កើតសហករណ៍និងការដ្ឋាន ខៀវ សំផន បានកំណត់អត្តសញ្ញាណនៃការសម្រេចជាច្រើន នៅក្នុងសាលដីកាសំណុំរឿង ០០២/១ ដែលចោទថាជាបុរេវិនិច្ឆ័យលើបញ្ហាក្នុងសំណុំរឿង ០០២/២។ ជាដំបូង ក្រុមប្រឹក្សាជំនុំជម្រះពិសេសសង្កេតឃើញថា ការសម្រេចដែលរងការចោទថាជាបុរេវិនិច្ឆ័យ លើបញ្ហានៃអត្ថិភាពគោលនយោបាយ បង្កើតការដ្ឋាន[217] មិនបង្កើតបានជាការសម្រេច ដែលធ្វើឡើងដោយអង្គជំនុំជម្រះតុលាការកំពូលទេ ប៉ុន្តែជាការយោងទៅរកដីកាដំណោះស្រាយ[218]។ ទីពីរ ក្រុមប្រឹក្សាជំនុំជម្រះពិសេស ពិចារណាលើការនិយាយដោយចៃដន្យ (*obiter dictum*) ដែលសហមេធាវីបានចោទប្រកាន់[219] និងសម្រេចថានេះ គឺជាការថ្លែងដែលធ្វើឡើងដោយចៃដន្យ ដែលមិនបានបង្កើតជាធាតុផ្សំ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ដាក់ឲ្យទៅជាទាសករ ឬការទទួលខុសត្រូវព្រហ្ម

---

[215] *សូមមើល* សំណុំរឿង ០០២/២ សេចក្តីសម្រេចលើ សំណើសុំប្តឹងជំទាស់ (ឯកសារ E314/12/1) កថាខណ្ឌ ៧០, ៩១ *យោងទៅរក* សំណុំរឿង ០០២ សេចក្តីសម្រេចលើកទីបី បំបែកកិច្ចដំណើរការនីតិវិធី (ឯកសារ E301/9/1/1/3) កថាខណ្ឌ ៨៥ ដែលកំណត់ពីបទដ្ឋាន "ថាតើការសម្រេចនៅក្នុងរឿងក្តីកន្លងមក ផ្តល់ជាភស្តុតាងសម្រាប់ ការទទួលខុសត្រូវព្រហ្មទណ្ឌ ទាក់ទងបទចោទដែលត្រូវវិនិច្ឆ័យ នៅក្នុងរឿងក្តីបន្ទាប់"។

[216] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ (១) កថាខណ្ឌ ៦១។

[217] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ (១) កថាខណ្ឌ ៦២ និងជើងទំព័រ ៨៧។

[218] សំណុំរឿង ០០២/១ សាលដីកា (ឯកសារ F36) កថាខណ្ឌ ២២៧ ("យោងតាមដីកាដំណោះស្រាយ (D427) គោលដៅមួយក្នុងចំណោមនោះ អំពីការផ្លាស់ទីលំនៅប្រជាជន គឺ "ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវ ការងារសហករណ៍ និងការដ្ឋានធ្វើការ"")។

[219] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ (១) កថាខណ្ឌ ៦២-៦៣ ("ការដាក់ប្រជាជនជាទាសករ ហាក់ដូចជាគោលបំណងមួយក្នុងចំណោមគោលបំណងដ៏សំខាន់ផ្សេងទៀត នៃរបបខ្មែរក្រហម ហើយការផ្លាស់ទីលំនៅប្រជាជន គ្រាន់តែជាជំហានដំបូងតែប៉ុណ្ណោះ")។

ទណ្ឌរបស់ ខៀវ សំផន តាមរយៈសហឧក្រិដ្ឋកម្មរួម ឡើយ[220]។ ទីបី ផ្ទុយពីការអះអាងរបស់សហមេធាវី អង្គជំនុំជម្រះតុលាការកំពូល មិនបានសម្រេចលើការចោទប្រកាន់ ពីការចុះត្រួតពិនិត្យរបស់ ខៀវ សំផន ទៅកាន់ការដ្ឋាន ដែលទាក់ទងសំណុំរឿង ០០២/២ ឡើយ[221]។ ផ្ទុយទៅវិញអង្គជំនុំជម្រះតុលាការកំពូល ទទួលស្គាល់ថាភស្តុតាង ទាក់ទងការចោទប្រកាន់ពីការចុះពិនិត្យការដ្ឋាន គឺគ្រាន់តែពាក់ព័ន្ធជាមួយ ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ដែលស្ថិតក្នុងវិសាលភាពសំណុំរឿង ០០២/១[222]។ ទីបួន ចំពោះសេចក្តីថ្លែងអំពី ការចោទប្រកាន់ពីការចូលរួមរបស់ ខៀវ សំផន ក្នុងការរៀបចំគោលនយោបាយសេដ្ឋកិច្ច[223] ក្រុមប្រឹក្សាជំនុំជម្រះពិសេសសង្កេតឃើញថា កថាខណ្ឌដែលសហមេធាវីបានយោង គឺមិនមានការសម្រេចលើអង្គហេតុណាមួយ ទាក់ទងបញ្ហានេះឡើយ។ ផ្ទុយទៅវិញអង្គជំនុំជម្រះតុលាការកំពូល បានដោះស្រាយបញ្ហាថាតើ ការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើឯកសារខែកញ្ញា ឆ្នាំ១៩៧៥ និងផែនការសេដ្ឋកិច្ចឆ្នាំ១៩៧៧ ពិតជាមិនមានសំអាងហេតុដែរឬយ៉ាងណា ដោយអង្គជំនុំជម្រះតុលាការកំពូល មិនបានបង្កើតជាការវិនិច្ឆ័យលើពិរុទ្ធភាពរបស់ ខៀវ សំផន ឡើយ[224]។ ហេតុដូច្នេះក្រុមប្រឹក្សាជំនុំជម្រះពិសេសយល់ឃើញថា ការជំទាស់របស់សហមេធាវី ទាក់ទងនឹងចំណុចការចោទប្រកាន់ ពីគោលនយោបាយបង្កើតសហករណ៍និងការដ្ឋាន មិនបានបង្ហាញពីការស្តែងចេញដោយសមហេតុផល នូវភាពលំអៀងនោះទេ។

៨០. ចំពោះការសម្រេចលើការចោទប្រកាន់ ពីគោលនយោបាយកំណត់គោលដៅ លើក្រុមជាក់លាក់នៃអតីតមន្ត្រីរដ្ឋការ និងយោធាសាធារណរដ្ឋខ្មែរ ក្រុមប្រឹក្សាជំនុំជម្រះពិសេសកត់សម្គាល់ថា សហមេធាវីបានបង្ហាញពីកថាខណ្ឌចំនួនបី ដែលអះអាងបានបង្កើតជាបុរេវិនិច្ឆ័យ ទៅលើពិរុទ្ធភាពរបស់ ខៀវ សំផន[225]។ ក្នុងន័យនេះ ក្រុមប្រឹក្សាជំនុំជម្រះពិសេសកត់សម្គាល់ថា សហមេធាវីបានបង្ហាញដោយខុសឆ្គង នូវការសម្រេចរបស់ អង្គជំនុំជម្រះតុលាការកំពូល លើបញ្ហានេះ។ ជាដំបូង ការពិនិត្យមើលទៅលើកថាខណ្ឌ២២៧

---

[220] *សូមមើល* Poppe *តទល់នឹង ប្រទេសហូឡង់* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) កថាខណ្ឌ ២៨។

[221] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ (១) កថាខណ្ឌ ៦៤ និងជើងទំព័រ ៨៩។

[222] សំណុំរឿង ០០២/១សាលដីកា (ឯកសារ F36) កថាខណ្ឌ ១០២៨ ("អង្គជំនុំជម្រះតុលាការកំពូល កត់សម្គាល់ឃើញថា ភស្តុតាងនេះជាប់ពាក់ព័ន្ធត្រង់ចំណុចថា ប្រជាជនមួយចំនួនដែលត្រូវបានផ្លាស់ទីលំនៅ ដំណាក់កាលទីពីរ ត្រូវបានបញ្ជូនទៅកាន់ការដ្ឋាននានា")។ *យោងទៅរក*សំណុំរឿង ០០២/០១ សាលក្រម ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ៦០១។

[223] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ (១) កថាខណ្ឌ ៦៤ និង ជើងទំព័រ ៩០-៩១។

[224] សំណុំរឿង ០០២/១ សាលដីកា (ឯកសារ F36) កថាខណ្ឌ ៨៣៨, ៨៤០-៨៤៣។

[225] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ (១) កថាខណ្ឌ ៦៥-៦៦ *យោងទៅរក*សំណុំរឿង ០០២/១ /1 សាលដីកា (ឯកសារ F36) កថាខណ្ឌ ២២៧, ៩៦០ និង៩៧០។

នៃសាលដីកាសំណុំរឿង ០០២/២ បង្ហាញថា អង្គជំនុំជម្រះតុលាការកំពូល បានពិភាក្សាអំពីបញ្ហាត្រួតគ្នា នៃគោលនយោបាយទាំងប្រាំ របស់បក្សកុម្មុយនីស្តកម្ពុជា នៅក្នុងដីកាដំណោះស្រាយ ដោយមិនបានសម្រេចលើអង្គហេតុ អំពីការចោទប្រកាន់ពីគោលនយោបាយ កំណត់គោលដៅលើក្រុមជាក់លាក់ នៃអតីតអ្នករដ្ឋការនិងយោធា សាធារណរដ្ឋខ្មែរឡើយ[226]។ ទីពីរ ក្រុមប្រឹក្សាជំនុំជម្រះពិសេស កត់សម្គាល់ថា កថាខណ្ឌដែលសហមេធាវីបានយោង ពាក់ព័ន្ធនឹងការត្រួតពិនិត្យលើការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលរួមមានផងដែរនូវអត្ថិភាពនៃការចោទប្រកាន់ពីគោលនយោបាយ កំណត់គោលដៅលើអតីតអ្នករដ្ឋការនិងយោធាសាធារណរដ្ឋខ្មែរ ក្នុងអំឡុងរយៈពេលមុន និងក្រោយបន្ទិចពីហេតុការណ៍នៅទួលពោធិ៍ជ្រៃ និងថាតើមានការកំណត់ដែរឬទេថា មានអត្ថិភាពគោលនយោបាយ ដែលគាំទ្រដល់ការសម្លាប់ អតីតអ្នករដ្ឋការនិងយោធា សាធារណរដ្ឋខ្មែរ នៅក្នុងអំឡុងហេតុការណ៍នៅទួលពោធិ៍ជ្រៃ [227] ។ ទោះបីជាអង្គជំនុំជម្រះតុលាការកំពូល បានយោងជាច្រើនទៅរក "ភស្តុតាងទាក់ទងទៅនឹងអំឡុងពេលនៅក្រោយនោះនៅទួលពោធិ៍ជ្រៃ"[228] ប៉ុន្តែច្បាស់ណាស់ថា អង្គជំនុំជម្រះតុលាការកំពូល ពឹងផ្អែកទៅលើភស្តុតាងបែបនេះ តែក្នុងករណីដែលវាពាក់ព័ន្ធជាមួយនឹងការចោទប្រកាន់លើអង្គហេតុ ដែលជាមូលដ្ឋាននៃការចោទប្រកាន់ ក្នុងសំណុំរឿង ០០២/១ ប៉ុណ្ណោះ [229] ។ ផ្ទុយពីការអះអាងរបស់សហមេធាវី ដែលថាអង្គជំនុំជម្រះតុលាការកំពូល បាន

[226] សំណុំរឿង ០០២/១ សាលដីកា (ឯកសារ F36) កថាខណ្ឌ ២២៧។ ក្រុមប្រឹក្សាជំនុំជម្រះពិសេស កត់សម្គាល់ថា អង្គជំនុំជម្រះតុលាការកំពូល បានបញ្ជាក់យ៉ាងច្បាស់ថា ទោះបីជាមានការត្រួតគ្នាលើគោលនយោបាយ "បញ្ហាសំខាន់សម្រាប់ការត្រួតពិនិត្យឡើងវិញ លើបណ្តឹងសាទុក្ខ គឺនៅត្រង់ការបង្ហាញគ្រប់គ្រាន់ ទាក់ទងទៅនឹងបទចោទអំពី "ការផ្លាស់ទីលំនៅប្រជាជន ដោយបង្ខំដំណាក់កាលទីមួយ និងទីពីរ ការសម្លាប់នៅទួលពោធិ៍ជ្រៃ ក្រោយពេលភ្លាមនៃការជម្លៀសប្រជាជន ចេញពីទីក្រុងភ្នំពេញ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពាក់ព័ន្ធដទៃទៀត" និងចុងក្រោយ ភាពគ្រប់គ្រាន់នៃការយល់ឃើញផ្អែកអង្គហេតុ ដែលជាមូលដ្ឋានសម្រាប់ការសម្រេចដាក់ពិរុទ្ធភាព ហើយពុំមែនជាការចាត់ទុក ភស្តុតាងមូលដ្ឋាននៃរឿងក្តីថា មានសារៈសំខាន់តិចជាគោលនយោបាយនោះឡើយ"។ ការអះអាងនេះបង្ហាញថា អង្គជំនុំជម្រះតុលាការកំពូល ផ្តោតការត្រួតពិនិត្យរបស់ខ្លួន ទៅលើបញ្ហាទាក់ទងសំណុំរឿង ០០២/១ ប៉ុណ្ណោះ។

[227] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ (១) កថាខណ្ឌ ៦៦ *យោងទៅរក*សំណុំរឿង ០០២/១ សាលដីកា (ឯកសារ F36) កថាខណ្ឌ ៨៦០, ៨៨៣-៨៨៤, ៨៩១, ៩០០, ៩០២, ៩០៣, ៩០៨, ៩៣០, ៩៣៣, ៩៤៧, ៩៥១-៩៥២, ៩៥៨, ៩៦០, ៩៦២, ៩៦៥, ៩៦៧, ៩៦៨, ៩៧០, ៩៧១។

[228] សំណុំរឿង ០០២/១ សាលដីកា (ឯកសារ F36) កថាខណ្ឌ ៩៦០, ៩៦៨, ៩៧០។

[229] សំណុំរឿង ០០២/១ សាលដីកា (ឯកសារ F36) កថាខណ្ឌ ៩០៨, ៩៥៦ ("នេះពុំមែនមានន័យថា អង្គជំនុំជម្រះសាលាដំបូង ពុំអាចសំអាងលើភស្តុតាងក្រោយព្រឹត្តិការណ៍ ដើម្បីទាញសេចក្តីសន្និដ្ឋានអំពី គោលនយោបាយនៅមុនព្រឹត្តិការណ៍បាននោះទេ ដរាបណាអង្គជំនុំជម្រះបានផ្តល់ ហេតុផលគ្រប់គ្រាន់ទាក់ទងទៅនឹងមូលហេតុ ដែលភស្តុតាងនេះបានបង្ហាញ អំពីការបន្តគោលនយោបាយនេះ ពុំមែនបង្ហាញគោលនយោបាយ ដែលត្រូវបានកែប្រែ ឬបង្កើតថ្មីឡើយ") កថាខណ្ឌ ៩៧១ ("ការពិចារណានេះ

សម្រេចលើគោលនយោបាយដែលរងការចោទប្រកាន់ ក្នុងអំឡុងពេលពាក់ព័ន្ធនឹងសំណុំរឿង ០០២/២[230] ក្រុមប្រឹក្សាជំនុំជម្រះពិសេស ពិចារណាថា ចំណុចដែលបានដកស្រង់ មិនបានបុរេវិនិច្ឆ័យពិរុទ្ធភាពរបស់ ខៀវ សំផន នោះឡើយ ពាក់ព័ន្ធទៅនឹងបញ្ហា ក្នុងសំណុំរឿង ០០២/២។

៨១. ចំពោះការសម្រេចលើការចោទប្រកាន់ពីគោលនយោបាយ ក្នុងការសម្លាប់ខ្មាំងវិញ ក្រុមប្រឹក្សាជំនុំជម្រះពិសេសសង្កេតឃើញថា ដោយពិចារណាទៅលើបរិបទរួម នៃផ្នែកនេះក្នុងសាលដីកា[231] ការសម្រេចដែលជំទាស់ដោយសហមេធាវី[232] ពាក់ព័ន្ធជាក់ស្តែងជាមួយគោលនយោបាយ "បន្តពេញមួយរយៈកាលនៃសំណុំរឿង០០២/០១"[233] ដែលដូច្នេះហើយមិនអាចផ្តល់ភស្តុតាងគាំទ្រ ការចោទប្រកាន់ពីការស្តែងចេញដោយសមហេតុផល នូវភាពលំអៀងឡើយ។ ក្រុមប្រឹក្សាជំនុំជម្រះពិសេស កត់សម្គាល់បន្ថែមទៀតថា ការសម្រេចមួយទៀតដែល សហមេធាវីបានចោទប្រកាន់[234] គឺយោងតែទៅរក "ត្រឹមអំឡុងពេលមុន ឬក្រោយពេលភ្លាមៗ នៃព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ" ដែលស្ថិតនៅក្នុងវិសាលភាព នៃសំណុំរឿង០០២/១[235] ហើយមិនបានយោងទៅរកការទទួលខុសត្រូវព្រហ្មទណ្ឌណាមួយឡើយ[236]។ ហេតុដូច្នេះ ក្រុមប្រឹក្សាជំនុំ

---

ទទួលរងនូវផលប៉ះពាល់ ដោយសារការកម្រិតពេលវេលា ដែលធ្វើឱ្យភស្តុតាងមួយផ្នែកធំ ទៅជាលែងជាប់ពាក់ព័ន្ធ តាមពេលវេលានេះ ដោយសារតែអង្គជំនុំជម្រះសាលាដំបូង ពុំអាចបង្ហាញពីមូលហេតុអ្វី បានជាសេចក្តីណែនាំចេញក្នុងឆ្នាំ ១៩៧៦ និងក្រោយមក បង្ហាញដោយប្រយោលថា គោលនយោបាយមានអត្ថិភាព ក្នុងខែមេសា ឆ្នាំ១៩៧៥ ទៅវិញនោះ")។

[230] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ (១) កថាខណ្ឌ ៦៦។

[231] *សូមមើល* តុលាការ ICTR *រដ្ឋអាជ្ញា តទល់នឹង Nyiramasuhuko* និងអ្នកដទៃទៀត ICTR-98-42-A សេចក្តីសម្រេចលើញត្តិប្តឹងជំទាស់ ចៅក្រម Fausto Pocar ថ្ងៃទី២ ខែតុលា ឆ្នាំ២០១២ កថាខណ្ឌ ១៦ ("ក្នុងករណីដែលការចោទប្រកាន់ពីភាពលំអៀង ត្រូវបានលើកឡើងទាក់ទង ការលើកឡើងរបស់ចៅក្រម ជាការចាំបាច់ដែលពិចារណា លើការលើកឡើងរបស់ចៅក្រម នៅក្នុងបរិបទដែលត្រឹមត្រូវ [...]។ ការពិចារណាទៅលើមតិដែលរងការជំទាស់ នៅក្នុងបរិបទត្រឹមត្រូវ "គឺជាវិធីសាស្ត្រដែលបានរំពឹងសម្រាប់អ្នកសង្កេតការណ៍ដោយសមហេតុផល")។

[232] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ (១) កថាខណ្ឌ ៦៧ និងជើងទំព័រ ៩៥5 *យោងទៅរក*សំណុំរឿង ០០២/១ សាលដីកា (ឯកសារ F36) កថាខណ្ឌ ៩៣៣។

[233] សំណុំរឿង ០០២/១ សាលដីកា (ឯកសារ F36) កថាខណ្ឌ ៩២៣។ *សូមមើលផងដែរ* កថាខណ្ឌ ៩២៤-៩៣៣។

[234] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ (១) កថាខណ្ឌ ៦៧ និងជើងទំព័រ ៩៥ *យោងទៅរក*សំណុំរឿង ០០២/១ សាលដីកា (ឯកសារ F36) កថាខណ្ឌ ៩៦៧។

[235] សំណុំរឿង ០០២/១ សាលដីកា (ឯកសារ F36) កថាខណ្ឌ ៩៦១-៩៧២។

[236] សំណុំរឿង ០០២/១ សាលដីកា (ឯកសារ F36) កថាខណ្ឌ ៩៦៧ (ទោះបីជាអង្គជំនុំជម្រះតុលាការកំពូល "យល់ឃើញថា ជាការគួរឱ្យជឿជាក់ថា សេចក្តីថ្លែងការណ៍របស់បក្ស ដែលបានដកស្រង់នោះ អាចត្រូវចាត់ទុកបានថា ជាការត្រួសត្រាយផ្លូវសម្រាប់គោលនយោបាយ ដែលកំណត់គោលដៅសម្លាប់ខ្មាំង" ប៉ុន្តែអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា អង្គជំនុំជម្រះ

ជម្រះពិសេស ពិចារណាថា ចំណុចទាំងអស់នេះ មិនអាចចាត់ទុកដោយសមហេតុផល ថាជាការឆ្លុះបញ្ចាំងពីការវិនិច្ឆ័យលើពិរុទ្ធភាពរបស់ ខៀវ សំផន នៅក្នុងសំណុំរឿង០០២/២ ទេ។

៨២. ចំពោះការសម្រេចលើការចោទប្រកាន់ពីការចូលរួមរបស់ ខៀវ សំផន ក្នុងសហឧក្រិដ្ឋកម្មរួម ក្រុមប្រឹក្សាជំនុំជម្រះពិសេសកត់សម្គាល់ថា សហមេធាវីបានបង្ហាញពីការសម្រេចលើអង្គហេតុជាក់លាក់ និងទូទៅមួយចំនួន ដែលអះអាងថាបានបុរេវិនិច្ឆ័យ លើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន នៅក្នុងសំណុំរឿង០០២/២ [237] ។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសសូមរំឭកថា បើទោះបីជាមាន "លទ្ធភាពនៃការសម្រេចបុរេវិនិច្ឆ័យ លើបញ្ហាដែលពាក់ព័ន្ធគ្នាជារួម" នៅក្នុងសំណុំរឿង ០០២/១ និង០០២/២ ដូចជាការចូលរួមចំណែក ក្នុងសហឧក្រិដ្ឋកម្មរួមក្តី តែធាតុផ្សំអង្គហេតុរួមគ្នា នៅក្នុងសំណុំរឿងទាំងពីរ ចាំបាច់ត្រូវតែបង្កើតឡើងថ្មី [238] ។ ក្នុងការវាយតម្លៃថាតើ ការសម្រេចដែលរងការចោទ បង្ហាញពីការស្តែងចេញនូវភាពលំអៀងដែរឬអត់នោះ ក្រុមប្រឹក្សាជំនុំជម្រះពិសេសសូមរំឭកថា បុរេវិនិច្ឆ័យលើបញ្ហាកើតមានឡើងប្រសិនបើ សំអាងហេតុនៅក្នុងរឿងក្តីនាពេលមុនៗ បង្ហាញការសន្និតនូវការទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះបទចោទនានា ដែលត្រូវវិនិច្ឆ័យនៅក្នុងរឿងក្តីក្រោយៗដែរឬទេ [239] ។ ការកំណត់ពីធាតុផ្សំនៃសហឧក្រិដ្ឋកម្មរួម ដែលជាទម្រង់នៃការទទួលខុសត្រូវ មិនបង្កើតបានជាការចូលរួមចំណែក ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះគ្រប់ឧក្រិដ្ឋកម្មសក្តានុពលទាំងអស់ ដែលត្រូវបានប្រព្រឹត្តឡើង ក្រោមសហឧក្រិដ្ឋកម្មរួមនោះទេ។

៨៣. ជាដំបូង ក្រុមប្រឹក្សាជំនុំជម្រះពិសេសសង្កេតឃើញថា នៅក្នុងកថាខណ្ឌដែលអះអាងថា ទាក់ទងទៅនឹងការចោទប្រកាន់ ពីតួនាទីរបស់ ខៀវ សំផន ជាសមាជិកមន្ទីរ ៨៧០ និងត្រួតពិនិត្យលើគណៈកម្មាធិការពាណិជ្ជកម្មនោះ [240] អង្គជំនុំជម្រះតុលាការកំពូល បានពិភាក្សាអំពីភាពសមហេតុផល នៃការវាយតម្លៃរបស់ អង្គជំនុំជម្រះសាលាដំបូង ទៅលើភស្តុតាងលើបញ្ហានេះ ដោយមិនមានមូលដ្ឋាននៃការវិនិច្ឆ័យណា

---

សាលាដំបូង មិនបានពន្យល់ថាតើសេចក្តីថ្លែងការណ៍អរូបីយ៍ទូទៅ អំពីទ្រឹស្តីកុម្មុយនីស្ត និងការតស៊ូវណ្ណៈ បានអនុញ្ញាតឲ្យខ្លួនអាចសន្និដ្ឋានបានយ៉ាងសមហេតុផលថា មានគោលនយោបាយសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបប សាធារណរដ្ឋខ្មែរឡើយ)។

[237] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ (១) កថាខណ្ឌ ៦៨ *យោងទៅរក*សំណុំរឿង ០០២/១ សាលដីកា (ឯកសារ F36) កថាខណ្ឌ ១០០៦, ១០១១, ១០១៥, ១០១៧, ១០១៨, ១០២២, ១០២៤, ១០២៧-១០៣០, ១០៤៧, ១០៥០, ១០៨៦។

[238] សំណុំរឿង ០០២ សេចក្តីសម្រេចលើកទីបី បំបែកកិច្ចដំណើរការនីតិវិធី (ឯកសារ E301/9/1/1/3) កថាខណ្ឌ ៨៣, ៨៥។

[239] សំណុំរឿង ០០២/២ សេចក្តីសម្រេចលើ សំណើសុំប្តឹងជំទាស់ (ឯកសា E314/12/1) កថាខណ្ឌ ៧០, ៩១ *យោងទៅរក*សំណុំរឿង ០០២ សេចក្តីសម្រេចលើកទីបី បំបែកកិច្ចដំណើរការនីតិវិធី (ឯកសារ E301/9/1/1/3) កថាខណ្ឌ ៨៥។ *សូមមើល also* Poppe *តទល់នឹង ប្រទេសហូឡង់* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) កថាខណ្ឌ ២៨។

[240] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ (១) កថាខណ្ឌ ៦៨ និងជើងទំព័រ ៩៦-៩៧។

មួយ ទៅលើពិរុទ្ធភាពរបស់ ខៀវ សំផនឡើយ។ ទីពីរ ចំពោះការសម្រេចលើការចោទប្រកាន់ ពីការចូលរួមចំណែករបស់ ខៀវ សំផន តាមរយៈការចូលរួមកិច្ចប្រជុំនយោបាយ និងអប់រំ និងការថ្លែងជាសាធារណៈនោះ[241] ក្រុមប្រឹក្សាជំនុំជម្រះពិសេសកត់សម្គាល់ថា ការសម្រេចដែលសហមេធាវីបានជំទាស់ ពាក់ព័ន្ធការប្រព្រឹត្តរបស់ ខៀវ សំផន គឺទាក់ទងតែនៅក្នុងសំណុំរឿង ០០២/១ ប៉ុណ្ណោះ[242] ដូច្នេះហើយមិនអាចមើលឃើញដោយសមហេតុផល ថាជាការផ្ទុះបញ្ចាំងពីការវិនិច្ឆយ លើពិរុទ្ធភាពរបស់ ខៀវ សំផន នៅក្នុងសំណុំរឿង ០០២/២ ឡើយ។ ទីបី ចំពោះការសម្រេចទាក់ទង ការចោទប្រកាន់ពីការថ្លែងជាសាធារណៈរបស់ ខៀវ សំផន តួនាទីរបស់គាត់ជាអ្នកកាទូត សិទ្ធិអំណាច និងឥទ្ធិពល ព្រមទាំងការចូលរួមចំណែករបស់គាត់ក្នុងគោលបំណងរួម[243] ក្រុមប្រឹក្សាជំនុំជម្រះពិសេសសង្កេតឃើញថា ទោះបីជាការសម្រេចទាំងអស់នេះយោងទៅរកការប្រព្រឹត្តរបស់ ខៀវ សំផន ក្តី តែការសម្រេចទាំងអស់នោះ មិនបានវាយតម្លៃ ឬកំណត់ពីធាតុផ្សំអត្តនោម័ត ឬសត្យានុម័ត ទាក់ទងឧក្រិដ្ឋកម្មក្នុងសំណុំរឿង ០០២/២ ឡើយ[244]។ ប្រហែលគ្នានេះ ការសម្រេចដែលរងការជំទាស់លើ "តួនាទីគណៈកម្មាធិការមជ្ឈឹម"[245] មិនបានកំណត់ពីពិរុទ្ធភាពរបស់ ខៀវ សំផន ទាក់ទងនឹងឧក្រិដ្ឋកម្ម ដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/២ ឡើយ[246]។ ហេតុដូច្នេះ ក្រុមប្រឹក្សាជំនុំជម្រះពិសេស ពិចារណាថា ការសម្រេចដែលសហមេធាវីបានជំទាស់ មិនបានបង្ហាញនូវភស្តុតាងស្តីពីអត្ថិភាពនៃការស្តែងចេញ ដោយសមហេតុផលនូវភាពលំអៀងឡើយ។

៨៤. ចំពោះការសម្រេចលើការចោទប្រកាន់ ពីការដឹងឮរបស់ ខៀវ សំផន ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង និងចេតនារបស់គាត់នោះ សហមេធាវីបានកំណត់ពីការសម្រេចជាច្រើន ដែលចោទថាបង្កើត

[241] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ (១) កថាខណ្ឌ ៦៨ និងជើងទំព័រ ៩៨-១០០។

[242] សំណុំរឿង ០០២/១ សាលដីកា (ឯកសារ F36) កថាខណ្ឌ ១០០៦ (ពាក់ព័ន្ធអត្ថិភាពនៃគោលនយោបាយ ផ្លាស់ទីលំនៅប្រជាជន) កថាខណ្ឌ ១០១១ (ពិភាក្សាអំពីការប្រជុំ ស្តីពីការផ្លាស់ទីលំនៅដោយបង្ខំ លើប្រជាជនទីក្រុងភ្នំពេញ) ១០១៥ (ពិភាក្សាអំពីបញ្ហានៃការផ្លាស់ទីប្រជាជន ជាពិសេសការជម្លៀសប្រជាជន ចេញពីទីក្រុង) ១០២៤ (អង្គជំនុំជម្រះតុលាការកំពូល កត់សម្គាល់ច្បាស់លាស់ថា "ការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូង លើសុន្ទរកថា និងការប្រើប្រាស់សុន្ទរកថានេះ គឺស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ទាំងស្រុង") កថាខណ្ឌ ១០៨៦ (ពិភាក្សាអំពីការសម្លាប់ ដែលកើតឡើងនៅក្នុងអំឡុងពេល ជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ)។

[243] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ (១) កថាខណ្ឌ ៦៨ និងជើងទំព័រ ១០០-១០៣។

[244] សំណុំរឿង ០០២/១ សាលដីកា (ឯកសារ F36) កថាខណ្ឌ ១០២២, ១០២៧-១០៣០។

[245] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ (១) កថាខណ្ឌ ៦៨ និងជើងទំព័រ ១០៤-១០៥។

[246] សំណុំរឿង ០០២/១ សាលដីកា (ឯកសារ F36) កថាខណ្ឌ ១០៤៧, ១០៥០។

បានជាការសម្រេចទុកជាមុន លើបញ្ហាស្តីពីពិរុទ្ធភាពរបស់ ខៀវ សំផន[247]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេស បានកត់សម្គាល់ថា ការត្រួតពិនិត្យទៅលើបណ្តាកថាខណ្ឌ ដែលសហមេធាវីបានជំទាស់ [248] បង្ហាញថា ចេតនាឧក្រិដ្ឋរបស់ ខៀវ សំផន ទាក់ទងនឹងឧក្រិដ្ឋកម្មក្នុងសំណុំរឿង ០០២/២ មិនត្រូវបានយកមកពិភាក្សា នៅទីនោះឡើយ។ ហេតុដូច្នេះក្រុមប្រឹក្សាជំនុំជម្រះពិសេសយល់ឃើញថា សហមេធាវីមិនបានកំណត់អំពី ភាពលំអៀង ឬការស្តែងចេញនូវភាពលំអៀងដោយសមហេតុផលទេ។

៨៥. ចំពោះការចោទប្រកាន់ របស់សហមេធាវី ពីការសម្រេចលើអង្គច្បាប់វិញ ជាបឋម ក្រុមប្រឹក្សាជំនុំជម្រះពិសេសកត់សម្គាល់ថា សហមេធាវីផ្អែកការវាយតម្លៃរបស់ខ្លួន ចំពោះភាពលំអៀងរបស់ ចៅក្រម ដែលរងបណ្តឹង ផ្អែកលើសំអាងហេតុរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ក្នុងរឿងក្តី *Mancel និង Blanquart តទល់នឹង ប្រទេសបារាំង* គឺ "បញ្ហានានាដែលចៅក្រម [ត្រូវ] ដោះស្រាយក្នុងបណ្តឹងឧទ្ធរណ៍លើកទីពីរនេះ ស្រដៀងគ្នានឹងបញ្ហាដែលពួកគាត់បានសម្រេចក្នុងបណ្តឹងឧទ្ធរណ៍លើកទីមួយ" [249] ។ ការណ៍នេះត្រូវបាន ក្រុមប្រឹក្សាជំនុំជម្រះពិសេស សម្រេចថាមិនអាចអនុវត្តបានឡើយ[250]។ ជាជំនួសវិញ ក្រុមប្រឹក្សាជំនុំជម្រះ ពិសេស បញ្ជាក់ឡើងវិញថា លក្ខណៈវិនិច្ឆ័យសម្រាប់បុរេវិនិច្ឆ័យ គឺថាតើ "សំអាងហេតុនៅក្នុងរឿងក្តីនា ពេលមុនៗ បង្ហាញការសន្និដ្ឋាននូវការទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះបទចោទនានា ដែលត្រូវវិនិច្ឆ័យនៅក្នុង រឿងក្តីក្រោយៗដែរឬទេ"[251]។ សហមេធាវីបានជំទាស់ ចំពោះការសម្រេចលើអង្គច្បាប់ នៃសាលដីកាសំណុំ រឿង០០២/១ ទាក់ទងនឹងធាតុផ្សំបរិបទនៃ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ [252] ធាតុផ្សំអត្តនោម័តនៃអំពើ

---

[247] សំណើរបស់ ខៀវ សំផន ប្តឹងមិនចិត្ត (១) កថាខណ្ឌ ៦៩ និងជើងទំព័រ ១០៧។

[248] សំណុំរឿង ០០២/១ សាលដីកា (ឯកសារ F36) កថាខណ្ឌ ៨៣៧, ៨៣៩-៨៤២, ១០០៥-១០០៦, ១០៥៤-១០៥៥, ១០៧១-១០៧៧, ១០៧៩, ១០៨១-១០៨២, ១០៨៤, ១០៨៥-១០៩០។

[249] សំណើរបស់ ខៀវ សំផន ប្តឹងមិនចិត្ត (១) កថាខណ្ឌ ៧០ *យោងទៅរក*Mancel and Branquart តទល់នឹង *ប្រទេសបារាំង* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) កថាខណ្ឌ ៣៧។

[250] *សូមមើលខាងលើ* កថាខណ្ឌ ៦៩។

[251] សំណុំរឿង ០០២/២ សេចក្តីសម្រេចលើ សំណើសុំប្តឹងមិនចិត្ត (ឯកសា E314/12/1) កថាខណ្ឌ ៧០, ៩១ *យោងទៅរក*សំណុំរឿង ០០២ សេចក្តីសម្រេចលើកទីបី បំបែកកិច្ចដំណើរការនីតិវិធី (ឯកសារ E301/9/1/1/3) កថាខណ្ឌ ៨៥។

[252] សំណើរបស់ ខៀវ សំផន ប្តឹងមិនចិត្ត (១) កថាខណ្ឌ ៧២ *យោងទៅរក*សំណុំរឿង ០០២/១ សាលដីកា (ឯកសារ F36) កថាខណ្ឌ ៧១១-៧៣២, ៧៣៨-៧៤០, ៧៤៤-៧៤៩, ៧៥៣-៧៥៤។

មនុស្សឃាត ជាទម្រង់មួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ [253] យុត្តាធិការលើពេលវេលា [254] ភាពអាចប្រមើលមើលបាន និងគោលការណ៍នីត្យានុកូលភាព[255] និងសហឧក្រិដ្ឋកម្មរួម[256]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសសង្កេតឃើញថា ការសម្រេចលើអង្គហេតុដែលបានអះអាងនេះ បង្កើតបានជាការបកស្រាយផ្នែកគតិយុត្តិ ទៅលើគោលការណ៍ច្បាប់ទូទៅ ធាតុផ្សំឧក្រិដ្ឋកម្ម ឬទម្រង់នៃការទទួលខុសត្រូវ ដែលមិនប៉ះពាល់ដល់ឧក្រិដ្ឋកម្មជាក់លាក់ណាមួយ ដែលត្រូវបានចោទប្រកាន់នៅក្នុងវិសាលភាព នៃសំណុំរឿង០០២/២ ឡើយ។ ហេតុដូច្នេះក្រុមប្រឹក្សាជំនុំជម្រះពិសេសយល់ឃើញថា សហមេធាវីមិនបានកំណត់អំពីភាពលំអៀង ឬការស្តែងចេញនូវភាពលំអៀងដោយសមហេតុផលទេ។

៨៦. សម្រាប់សំអាងហេតុដូចបានរៀបរាប់ខាងលើ ក្រុមប្រឹក្សាជំនុំជម្រះពិសេសពិចារណាថា សហមេធាវីមិនបានលើកនូវភស្តុតាងគ្រប់គ្រាន់ ដើម្បីបង្ហាញថាអ្នកសង្កេតការណ៍ដែលមានហេតុផល និងទទួលបានព័ត៌មានសមស្រប មានទស្សនៈថា ចៅក្រមដែលរងបណ្តឹង មិនអាចប្រើប្រាស់ចិត្តឥតលំអៀង និងគ្មានបុរេវិនិច្ឆ័យរបស់ខ្លួន សម្រាប់បញ្ហានៃអង្គហេតុ និងអង្គច្បាប់ ដែលបានលើកឡើង ដើម្បីធ្វើការសម្រេចលើបញ្ហានានា នៅក្នុងសំណុំរឿង ០០២/២ នោះឡើយ។

៨៧. ហេតុដូច្នេះ ក្រុមប្រឹក្សាជំនុំជម្រះពិសេសយល់ឃើញថា សហមេធាវីមិនអាចជំទាស់ប្រឆាំង ចំពោះសច្ចធារណ៍នៃអនាគតិដ៏រឹងមាំដែលចៅក្រមទាំងនោះមាននោះឡើយ ហើយក្រុមប្រឹក្សាជំនុំជម្រះពិសេសសម្រេចបដិសេធមូលដ្ឋានទីមួយ។

## ខ. មូលដ្ឋានទី២៖ អត្ថិភាពនៃភាពលម្អៀងនៃការសំអាងហេតុដោយមានកំហុសក្នុងសាលដីកានៃសំណុំរឿង ០០២/១

[253] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ចិត្ត (១) កថាខណ្ឌ ៧២ *យោងទៅរក*សំណុំរឿង ០០២/១ សាលដីកា (ឯកសារ F36) កថាខណ្ឌ ៣៩០-៤១០, ៥១៦, ៧៦៥។

[254] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ចិត្ត (១) កថាខណ្ឌ ៧២ *យោងទៅរក* សំណុំរឿង ០០២/១ សាលដីកា (ឯកសារ F36) កថាខណ្ឌ ២១៣-២២១, ២២៩, ៧៤១។

[255] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ចិត្ត (១) កថាខណ្ឌ ៧២ *យោងទៅរក* សំណុំរឿង ០០២/១ សាលដីកា (ឯកសារ F36) កថាខណ្ឌ ៥៧៦, ៥៨៩, ៧៦១-៧៦២, ៧៦៥, ១០៩៣, ១០៩៥។

[256] សំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ចិត្ត (១) កថាខណ្ឌ ៧២ *យោងទៅរក* សំណុំរឿង ០០២/១ សាលដីកា (ឯកសារ F36) កថាខណ្ឌ ៧៧៣-៧៨៩, ៨០៣-៨១០, ៨១៤-៨១៧, ៨៥៧, ៨៦០, ៩៨០-៩៨៤, ១០៥៣-១០៥៥។

១. សារណា

៨៨. សហមេធាវីសន្និដ្ឋានថា សំអាងហេតុដោយមានកំហុសរបស់ចៅក្រមរងបណ្តឹងជំទាស់ ដែលបានបង្ហាញនៅក្នុងសាលដីកានៃសំណុំរឿង ០០២/១ ស្តែងចេញអំពីអត្ថិភាពនៃភាពលំអៀង និង/ឬ អាការៈនៃភាពលំអៀង[257]។ សហមេធាវីអះអាងថា ចៅក្រមដែលត្រូវបានប្តឹងជំទាស់ "បានប្រព្រឹត្តកំហុសជាច្រើនដែលមិនមែនជាលទ្ធផលនៃការអនុវត្តច្បាប់ ដែលមានការបកស្រាយលើសពីមួយ" ដូចបានបង្ហាញតាមរយៈការសន្និដ្ឋានលើបញ្ហាដូចជា៖ (i) គោលការណ៍នីត្យានុកូលភាព (ii) *ចេតនាអត្តនោម័តិ*នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់អំពើមនុស្សឃាត (iii) សហឧក្រិដ្ឋកម្មរួម (JCE) និង (iv) ការកំណត់ប្រភេទបទល្មើស ដើម្បីធ្វើយ៉ាងណាផ្តន្ទាទោស ខៀវ សំផន ឲ្យខាងតែបាន[258]។

៨៩. ចំណុចទី១ សហមេធាវីការពារក្តីចោទប្រកាន់ថា ចៅក្រមរងបណ្តឹងជំទាស់ "បានបំបាត់សារធាតុនៃគោលការណ៍នីត្យានុកូលភាព ដោយលើកវាឡើងដើម្បីបង្គ្រប់កិច្ចតែប៉ុណ្ណោះ" ដោយអនុវត្ត "វិធីសាស្ត្រច្បាប់ស្តីពីការដាក់ទណ្ឌកម្ម" [259] ។ អង្គជំនុំជម្រះតុលាការកំពូលបានដកចេញពីយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប និង អ.វ.ត.ក[260] ដោយបានពិចារណាថា វាគ្រប់គ្រាន់កាលណាមាន "ឧក្រិដ្ឋកម្ម ឬ ទម្រង់

---

[257] សំណើរបស់លោក ខៀវ សំផន សុំប្តឹងជំទាស់ចៅក្រម (១), កថាខណ្ឌ ៧៦។

[258] សំណើរបស់លោក ខៀវ សំផន សុំប្តឹងជំទាស់ចៅក្រម (១), កថាខណ្ឌ ៧៩។

[259] សំណើរបស់លោក ខៀវ សំផន សុំប្តឹងជំទាស់ចៅក្រម (១), កថាខណ្ឌ ៨០។

[260] សំណើរបស់លោក ខៀវ សំផន សុំប្តឹងជំទាស់ចៅក្រម (១), កថាខណ្ឌ ៨០ *ដែលយោងទៅលើ* សាលដីកាសម្រេចលើបណ្តឹងសារទុក្ខក្នុងសំណុំរឿង ០០១ (F28), កថាខណ្ឌ ៩៧។ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់លោក ខៀវ សំផន (០០២/០២), ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៧, ដែលបានកែប្រែកាលពីថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៧, ឯកសារ E457/6/4/1 ("សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល (០០២/០២) (E457/6/4/1)"), កថាខណ្ឌ ៣០០-៣៣០ *ដែលយោងទៅលើ* តុលាការសិទ្ធិមនុស្សអឺរ៉ុប, *រឿងក្តីរវាង* Kokkinakis *ទល់នឹង ប្រទេសក្រិច,* សំណុំរឿងលេខ ១៤៣០៧/៨៨, សាលក្រម, ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៩៣, កថាខណ្ឌ ៤០, ៥២។ តុលាការសិទ្ធិមនុស្សអឺរ៉ុប, *រឿងក្តីរវាង* Vasiliauskas *ទល់នឹង លីទុយអានី,* សំណុំរឿងលេខ ៣៥៣៤៣/០៣, សាលក្រម, ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៩៣, កថាខណ្ឌ ១៥៤, ១៦៦-១៦៨, ១៧៨, ១៨១, ១៨៥-១៨៦, ១៩១។ តុលាការសិទ្ធិមនុស្សអឺរ៉ុប, *រឿងក្តីរវាង* Jamil *ទល់នឹង ប្រទេសបារាំង,* សំណុំរឿងលេខ ១៥៩១៧/៨៩, សាលក្រម, ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ១៩៩៥, កថាខណ្ឌ ៣៤-៣៦។ តុលាការសិទ្ធិមនុស្សអឺរ៉ុប, *រឿងក្តីរវាង* Korbely *ទល់នឹង ប្រទេសហុងគ្រី,* សំណុំរឿងលេខ ៩១៧៤/០២, សាលក្រម, ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨, កថាខណ្ឌ ៧៤-៧៥។ តុលាការសិទ្ធិមនុស្សអឺរ៉ុប, *រឿងក្តីរវាង* Kononov *ទល់នឹង ប្រទេសឡាតវី,* សំណុំរឿងលេខ ៣៦៣៧៦/០៤, សាលក្រម, ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១០, កថាខណ្ឌ ២៣៥, ២៣៩, ២៤៤។ តុលាការសិទ្ធិមនុស្សអឺរ៉ុប, *រឿងក្តីរវាង* Kafkaris *ទល់នឹង ប្រទេសឡាស៊ីព្រុស,* សំណុំរឿងលេខ ២១៩០៦/០៤, សាលក្រម, ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៨, កថាខណ្ឌ ១៤០, ១៤៣-១៤៨, ១៥០។

នៃទំនួលខុសត្រូវ ដែលមាននៅក្រោមនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅសម័យអង្គហេតុ និងកាលណាជនជាប់ចោទមានមុខតំណែងខ្ពស់" ហើយបានអះអាងថា លក្ខខណ្ឌនៃភាពអាចព្យាករណ៍បានត្រូវបានបំពេញ"ប្រសិនបើជនជាប់ចោទដឹងថាអំពើរបស់គាត់មានលក្ខណៈឧក្រិដ្ឋ ក្នុងន័យដែលមនុស្សទូទៅអាចយល់បាន ដោយមិនចាំបាច់យោងទៅលើបទប្បញ្ញត្តិជាក់លាក់ណាមួយ ដែលនេះជាលក្ខណៈវិនិច្ឆ័យសម្រាប់ "[ឧក្រិដ្ឋកម្ម] ធ្ងន់ធ្ងរបំផុតនានាមិនដែលធ្លាប់បានចុះបញ្ជី"[261]។

៩០. ចំណុចទីពីរ សហមេធាវីចោទប្រកាន់ថា អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចយកដោយភាន់ច្រឡំ និងលំអៀងនូវនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលក្តោបបញ្ចូលទាំងចេតនាប្រយោល[262]។ សហមេធាវីអះអាងថា ការបន្ទាបលក្ខខណ្ឌនៃធាតុផ្សំអត្តនោម័តិគឺរំលោភគោលការណ៍នីត្យានុកូលភាព និងបានសំអាង "ខុសច្បាប់ដោយជ្រើសរើស" លើ "យុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិមួយចំនួន ដែលតាក់តែងឡើងក្រោយអង្គហេតុ និងដោយផ្អែកលើការបកស្រាយខុសនៃ "រឿងក្តីវេជ្ជបណ្ឌិត" ហើយបានយោងទៅច្បាប់ជាតិ ដែលត្រូវបានតាក់តែងឡើងក្រោយឆ្នាំ១៩៧៥"[263]។ សហមេធាវីអះអាងថា ក្នុងករណីគ្មានភ័ស្តុតាងបង្ហាញអំពីចេតនាសម្លាប់ដោយផ្ទាល់ ចៅក្រមរងបណ្តឹងដឹតចិត្ត បានដាក់បញ្ចូលចេតនាប្រយោលនៅក្នុងនិយមន័យស្តីពីទម្រង់នៃការទទួលខុសត្រូវដើម្បីផ្តន្ទាទោសឲ្យខាងតែបាន[264]។

៩១. ចំណុចទី៣ សហមេធាវីចោទប្រកាន់ថា អង្គជំនុំជម្រះតុលាការកំពូល មានកំហុសអង្គច្បាប់ និងបានបង្ហាញភាពលំអៀង ដោយបាន "បង្កើតសហឧក្រិដ្ឋកម្មរួម [កូនកាត់] មួយ ដែលប្ញូកបញ្ចូលគ្នានូវធាតុផ្សំនៃអំពើឧក្រិដ្ឋនៃសហឧក្រិដ្ឋកម្មទម្រង់ទី I និងធាតុផ្សំនៃចេតនាឧក្រិដ្ឋទម្រង់ទី III ដែលមិនអាចអនុវត្ត

[261] សំណើរបស់លោក ខៀវ សំផន សុំប្តឹងដឹតចិត្តចៅក្រម (១), កថាខណ្ឌ ៨០ *ដែលយោងទៅលើ* សាលដីកាលើសំណុំរឿង ០០២/១ (F36), កថាខណ្ឌ ៧៦២, ៧៦៥។

[262] សំណើរបស់លោក ខៀវ សំផន សុំប្តឹងដឹតចិត្តចៅក្រម (១), កថាខណ្ឌ ៨២។

[263] សំណើរបស់លោក ខៀវ សំផន សុំប្តឹងដឹតចិត្តចៅក្រម (១), កថាខណ្ឌ ៨៣ *ដែលយោងទៅលើ* សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល (០០២/០២) (E457/6/4/1), កថាខណ្ឌ ៣៩៤-៤២៩ *ដែលសំអាងទៅលើរឿងក្តីរវាង ស.រ.អា ទល់នឹង* Karl Brandt *និងអ្នកផ្សេងទៀត* (ករណីវេជ្ជសាស្ត្រ), សាលក្រម ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៤៧, ការជំនុំជម្រះលើឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធាទីក្រុងនូរឹមប៊ឺក នៅក្រោមច្បាប់ស្តីពីក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ វ៉ុល ॥ ("ករណីវេជ្ជសាស្ត្រ") ទំព័រ ១៧៤-១៨០, ១៨៦, ១៩៤, ១៩៨, ២០០-២០១, ២០៧, ២១៧, ២២២, ២២៨, ២៣៤-២៣៧, ២៤១, ២៤៨, ២៥៥-២៥៦, ២៨១-២៨២, ២៨៥, ២៩០, ២៩៥, ២៩៧។

[264] សំណើរបស់លោក ខៀវ សំផន សុំប្តឹងដឹតចិត្តចៅក្រម (១), កថាខណ្ឌ ៨៤។

បាននៅ អ.វ.ត.ក"[265]។ សហមេធាវីអះអាងថា អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/២ បានច្រានចោលសំអាងហេតុនេះយ៉ាងត្រឹមត្រូវ ហើយអះអាងថា វានឹងបង្កើតនូវបញ្ហា ដែលចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូលដដែល ត្រូវវិនិច្ឆ័យអំពី JCE លើបណ្ដឹងសាទុក្ខ[266]។ សហមេធាវីអះអាងបន្ថែមទៀតថា ការបកស្រាយយ៉ាងទូលំទូលាយលើ JCE I គឺដើម្បី "ឈានទៅដល់ការដាក់បន្ទុកលើផែនការរួម និងបានបង្វិលតម្រែតម្រង់សហឧក្រិដ្ឋកម្មរួមដ៏យឺតដូចកៅស៊ូនេះ ដើម្បីបញ្ចូលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើមនុស្សឃាត ទៅក្នុងវិសាលភាពនៃផែនការរួម"[267]។ ពួកគេអះអាងថា ចៅក្រមរងបណ្ដឹងដិតចិត្ត "មានភាពលំអៀងជាក់ស្ដែង ឬ [...] បានបង្ហាញអាការៈនៃភាពលំអៀង" នៅពេលពង្រីកការទទួលខុសត្រូវដល់កម្រិតអតិបរមាដើម្បីបង្កើតទំនួលខុសត្រូវព្រហ្មទណ្ឌបុគ្គល ហើយថា "ការបន្ទាបចេតនាឧក្រិដ្ឋ ដែលបង្កគ្រោះថ្នាក់ និងមិនធ្លាប់មានពីមុនមកនេះ គឺជាភ័ស្តុតាងនៃការតាក់តែងកាត់កងតម្រឹមច្បាប់ឱ្យសមល្មមនឹងផ្ដន្ទាទោស ខៀវ សំផន បាន[268]។

៩២. ចំណុចទី៤ សហមេធាវីចោទប្រកាន់ថា អង្គជំនុំជម្រះតុលាការកំពូលមានកំហុសអង្គច្បាប់ដោយកំណត់អង្គហេតុមិនត្រឹមត្រូវ "ដាក់បញ្ចូលទៅក្នុងសហឧក្រិដ្ឋកម្មរួមនូវឧក្រិដ្ឋកម្មជាអតិបរមា ជាពិសេសឧក្រិដ្ឋកម្មដែលបណ្ដាលឱ្យមានមនុស្សស្លាប់"[269]។ សហមេធាវីបានរំលឹកថា ទោះបីមានការជំទាស់ជាក់លាក់ក៏ដោយ ការអះអាងថាការកំណត់ប្រភេទបទល្មើសសហឧក្រិដ្ឋកម្មរួមកូនកាត់ បានរំលោភ៖ (i) វិធាន ១១០ (២) ដោយដាក់បញ្ចូលធាតុផ្សំថ្មី (ii) គោលការណ៍មិនធ្វើឱ្យម្ចាស់បណ្ដឹងធ្លាក់ក្នុងស្ថានភាពអាក្រក់ជាងមុនពេលបណ្ដឹង បើប្ដឹងតែម្នាក់ឯង និង (iii) សិទ្ធិប្ដឹងសាទុក្ខចំពោះការសម្រេចជាលើកដំបូងលើបណ្ដឹងឧទ្ធរណ៍ចំពោះការទទួលខុសត្រូវរបស់ខៀវ សំផន[270] (បញ្ជាក់ថា អង្គជំនុំជម្រះតុលាការកំពូលបានកំណត់ប្រភេទបទល្មើសនៃការសម្លាប់រង្គាលជាអំពើមនុស្សឃាតដោយមានចេតនាប្រយោលក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី ២)[271]។ នេះជាកិច្ច "ខុសច្បាប់" ដោយសារសហមេធាវីពុំបានទទួលការ

---

[265] សំណើរបស់លោក ខៀវ សំផន សុំប្ដឹងដិតចិត្តចៅក្រម (១), កថាខណ្ឌ ៨៥-៨៦។

[266] សំណើរបស់លោក ខៀវ សំផន សុំប្ដឹងដិតចិត្តចៅក្រម (១), កថាខណ្ឌ ៨៧-៨៨ *ដែលយោងទៅលើ* សាលក្រមសំណុំរឿង ០០២/០២ (E465), កថាខណ្ឌ ៣៧១៤, ៣៧១៥, ៣៩២១។

[267] សំណើរបស់លោក ខៀវ សំផន សុំប្ដឹងដិតចិត្តចៅក្រម (១), កថាខណ្ឌ ៨៩-៩០។

[268] សំណើរបស់លោក ខៀវ សំផន សុំប្ដឹងដិតចិត្តចៅក្រម (១), កថាខណ្ឌ ៩១-៩២។

[269] សំណើរបស់លោក ខៀវ សំផន សុំប្ដឹងដិតចិត្តចៅក្រម (១), កថាខណ្ឌ ៩៣។

[270] សំណើរបស់លោក ខៀវ សំផន សុំប្ដឹងដិតចិត្តចៅក្រម (១), កថាខណ្ឌ ៩៤-៩៦។

[271] សំណើរបស់លោក ខៀវ សំផន សុំប្ដឹងដិតចិត្តចៅក្រម (១), កថាខណ្ឌ ៩៦-៩៧។

ជូនដំណឹង ឬ មានឱកាសជជែកដេញដោលតទល់មុខគ្នា[272] ហើយការកំណត់ប្រភេទបទល្មើសបែបនេះត្រូវបានគេចោទប្រកាន់ថាជាការកេងយក "ឱកាស" ពីព្រោះឧក្រិដ្ឋកម្មនៃអំពើមនុស្សឃាតក្នុងកំឡុងពេលផ្លាស់ទីលំនៅដំណាក់កាលទី ២ មិនត្រូវបានចោទប្រកាន់ និងបែរទៅជាអាចផ្តន្ទាទោសបានក្រោយពីការកំណត់ប្រភេទបទល្មើសឡើងវិញតែប៉ុណ្ណោះ[273]។

៩៣. សហមេធាវីអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះតុលាការកំពូលបានអនុវត្តដោយប្រយោលនូវ "ការកែប្រែបទចោទ ដែលត្រូវបានហាមឃាត់" មួយផ្សេងទៀត ទាក់ទងនឹងឧក្រិដ្ឋកម្មនៃការបាត់ខ្លួនដោយបង្ខំ ដោយគ្រាន់តែបញ្ជាក់នៅក្នុងកំណត់សម្គាល់ជើងទំព័រនៃសាលដីកា[274]។ សហមេធាវីអះអាងថា អង្គជំនុំជម្រះតុលាការកំពូល មិនអាចរកឃើញពិរុទ្ធភាពនៅក្រោមសហឧក្រិដ្ឋកម្មរួម ប្រសិនបើមិនឆ្លងកាត់ដំណើរការកែប្រែទម្រង់នៃការទទួលខុសត្រូវ ប៉ុន្តែបែរជាមិនបានធ្វើដូច្នោះនោះទេ ហើយអង្គជំនុំជម្រះ "តាមរយៈមធ្យោបាយលាក់បំពួនវៀចវេរ និងភាន់ច្រឡំច្បាស់ក្រឡែត" បានដាក់បញ្ចូលទៅក្នុងសហឧក្រិដ្ឋកម្មរួមនូវឧក្រិដ្ឋកម្មទាំងឡាយ ដែលខ្លួនបានសម្រេចតម្កល់ការប្រកាសពិរុទ្ធភាព និង "ដើម្បីធានាបាននូវការផ្តន្ទាទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិត"[275]។ ចំណុចចុងក្រោយ សហមេធាវីបានអះអាងថា ចាប់តាំងពីអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/២ បានទទួលយកនិយមន័យរបស់អង្គជំនុំជម្រះតុលាការកំពូលនៃអំពើមនុស្សឃាត ហើយបានផ្លាស់ប្តូរការកំណាប់បទចោទលើឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលទៅជាអំពើមនុស្សឃាតដោយមាន *ចេតនាប្រយោល* ខៀវ សំផន "ឥតសំណាងទាល់តែសោះក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខលើសំណុំរឿង ០០២/០២" នៅចំពោះមុខចៅក្រមរងបណ្តឹងដិតចិត្តនៅក្នុងករណីនេះ ដែលមានភាពលំអៀងលើបញ្ហាដូចគ្នា[276]។

៩៤. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាសន្និដ្ឋានថា បណ្តឹងដិតចិត្ត "គឺជាកិច្ចដំណើរការនីតិវិធីដែលរារាំងនូវបណ្តឹងឧទ្ធរណ៍ក្លែងបន្លំមួយថាជាសំណើសុំប្តឹងដិតចិត្ត"[277] ដែលក្នុងនោះ សហមេធាវីបានបង្ហាញខុសអំពីកំហុសច្បាប់ ដោយបានអះអាងថាមានភាពលំអៀង និងមិនបានបំពេញតាមបទដ្ឋាននៃភស្តុតាង

[272] សំណើរបស់លោក ខៀវ សំផន សុំប្តឹងដិតចិត្តចៅក្រម (១), កថាខណ្ឌ ៩៨។

[273] សំណើរបស់លោក ខៀវ សំផន សុំប្តឹងដិតចិត្តចៅក្រម (១), កថាខណ្ឌ ៩៩-១០១។

[274] សំណើរបស់លោក ខៀវ សំផន សុំប្តឹងដិតចិត្តចៅក្រម (១), កថាខណ្ឌ ១០២។

[275] សំណើរបស់លោក ខៀវ សំផន សុំប្តឹងដិតចិត្តចៅក្រម (១), កថាខណ្ឌ ១០៤-១០៧។

[276] សំណើរបស់លោក ខៀវ សំផន សុំប្តឹងដិតចិត្តចៅក្រម (១), កថាខណ្ឌ ១០៨-១០៩។

[277] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (៥), កថាខណ្ឌ ៤៥។

ចំពោះភាពលំអៀង និង/ឬ អាការៈនៃភាពលំអៀង[278]។ សហព្រះរាជអាជ្ញាអះអាងថា ដូចបានទទួលស្គាល់ដោយសហមេធាវី ការចោទប្រកាន់អំពីកំហុសអង្គច្បាប់មិនគ្រប់គ្រាន់ដើម្បីបង្ហាញអំពីភាពលំអៀង ហើយភាគីមិនត្រូវប្រើប្រាស់បណ្តឹងជំទាស់ជាវេទិកា ជំទាស់អង្គសេចក្តីនៃសេចក្តីសម្រេចពីមុន ដែលខ្លួនមិនយល់ស្របនោះឡើយ[279]។

៩៥. ម្យ៉ាងវិញទៀត ទាក់ទងនឹងការអះអាងរបស់សហមេធាវីថា កំហុសទាំងបួនដូចបានចោទប្រកាន់បង្ហាញអំពីភាពលំអៀង [280] ឬ ជាមធ្យោបាយតែមួយគត់សម្រាប់អង្គជំនុំជម្រះតុលាការកំពូលក្នុងការផ្តន្ទាទោសនៅក្នុងសំណុំរឿង ០០២/១ សហព្រះរាជអាជ្ញាអះអាងថា ចំណុចនេះមិនត្រូវបានគាំទ្រដោយភស្តុតាង និងផ្ទុយជាមួយនឹងការរកឃើញផ្សេងទៀតនៅក្នុងសាលដីកាក្នុងសំណុំរឿង ០០២/១ ដែលនាំឱ្យមានការបដិសេធផ្នែកខ្លះនៃការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូង និងការសម្រេចឱ្យរួចផុតពីបទចោទ[281]។

៩៦. ទាក់ទងនឹងគោលការណ៍នៃនីត្យានុកូលភាព សហព្រះរាជអាជ្ញាអះអាងថា ផ្ទុយពីការអះអាងរបស់សហមេធាវី អង្គជំនុំជម្រះតុលាការកំពូលសម្រេចនៅក្នុងសំណុំរឿង ០០១ និង ០០២/១ ថា ឧក្រិដ្ឋកម្ម ឬ ទម្រង់នៃការទទួលខុសត្រូវ ត្រូវតែមានអត្ថិភាពនៅក្រោមច្បាប់ជាតិ ឬ អន្តរជាតិ ហើយជនជាប់ចោទត្រូវដឹង និងអាចប្រមើលដឹងថាមានច្បាប់ចែងនៅពេលចោទប្រកាន់នៃអំពើឧក្រិដ្ឋនោះ[282]។ សហព្រះរាជអាជ្ញាគូសបញ្ជាក់ថា ការរកឃើញនៅក្នុងសំណុំរឿង ០០២/១ របស់អង្គជំនុំជម្រះតុលាការកំពូលទាក់ទងនឹងលក្ខខណ្ឌនៃ "លទ្ធភាពទទួលបាន/ដឹងបាន" និង "ភាពអាចព្យាករណ៍បានជាទូទៅ" គឺស្របនឹងសាលដីកាក្នុងសំណុំរឿង ០០១ យុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ ក៏ដូចជា តុលាការ ICTY និងស្របនឹងគោលការណ៍នៃនីត្យានុកូលភាព[283]។

---

[278] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (៥), កថាខណ្ឌ ៣៧, ៤៥។

[279] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (៥), កថាខណ្ឌ ៣៨-៤០។

[280] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (៥), កថាខណ្ឌ ៣៧។

[281] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (៥), កថាខណ្ឌ ៤១-៤២។

[282] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (៥), កថាខណ្ឌ ៤៧។

[283] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (៥), កថាខណ្ឌ ៤៨-៥០ *ដែលយោងទៅលើ* សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១, ឯកសារ D427/2/15 ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០២ (D427/2/15)"), កថាខណ្ឌ ១០៦។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០២ (D427/1/30), កថាខណ្ឌ ២៣៥។ សំណុំរឿង ០០២ (អ.ប.ជ៣៥), សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច

៩៧. ទាក់ទងនឹងធាតុផ្សំអត្តនោម័តិនៃការសម្លាប់រង្គាលដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ សហព្រះរាជអាជ្ញាអះអាងថា ផ្ទុយពីការចោទប្រកាន់របស់សហមេធាវី ការរកឃើញលើធាតុផ្សំអត្តនោម័តិនៃអំពើមនុស្សឃាតិ ដោយរួមបញ្ចូលចេតនាប្រយោល ពុំបានបង្កើតនូវកំហុស ឬក៏ពុំបានបំពេញបទដ្ឋានខ្ពស់នៃភ័ស្តុតាង សម្រាប់បង្ហាញអំពីភាពលំអៀង ឬ អាការៈនៃភាពលំអៀង[284]។ ម្យ៉ាងវិញទៀត សហព្រះរាជអាជ្ញាអះអាងថា ការរកឃើញនៅក្នុងសាលដីកានៃសំណុំរឿង ០០២/១ ថា "ចេតនាផ្ទាល់ក្នុងការសម្លាប់មិនចាំបាច់ទេនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត" គឺស្របនឹងយុត្តិសាស្ត្ររួមទាំងយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះ អ.វ.ត.ក ក្នុងសំណុំរឿង ០០១ សាលាក្តីចំពោះកិច្ច [285] និងអង្គជំនុំជម្រះតុលាការកំពូល (ដែលបានសង្កេតយ៉ាងត្រឹមត្រូវថា នៅក្នុងរឿងក្តីវេជ្ជសាស្ត្រក្រោយសង្គ្រាមលោកលើកទី ២ អំពើមនុស្សឃាត ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរួមមានសញ្ញាណ

---

របស់សហចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE), ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០, ឯកសារ D97/14/15 ("សាលដីកាលើសំណុំរឿង ០០២ ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (D97/14/15), កថាខណ្ឌ ៤៥។ តុលាការ ICTY, *រឿងក្តីរវាង រដ្ឋអាជ្ញា ទល់នឹង* Hadžihasanović *និង* Kubura, សំណុំរឿងលេខ IT-01-47-A, សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្អំ ជំទាស់នឹងយុត្តាធិការទាក់ទងនឹងការទទួលខុសត្រូវលើការបញ្ជា, អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៣ ("សាលដីកា *Hadžihasanović និង Kubura* (ICTY)"), កថាខណ្ឌ ៣៥។

[284] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (៥), កថាខណ្ឌ ៥១។

[285] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (៥), កថាខណ្ឌ ៥៣ *ដែលយោងទៅលើ* សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១ (F28), កថាខណ្ឌ ៣៣២-*៣៣៤ ដែលសំអាងលើ*សំណុំរឿង ០០១, សាលក្រម, ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, ឯកសារ E188 ("សាលក្រមសំណុំរឿង ០០១ (E188)"), កថាខណ្ឌ ៣៣៣។ តុលាការ ICTY, *រឿងក្តីរវាង រដ្ឋអាជ្ញា ទល់នឹង Kordić & Čerkez*, សំណុំរឿងលេខ IT-95-14/2-A, សាលដីកា, អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤, កថាខណ្ឌ ១១៣។ តុលាការ ICTY, *រឿងក្តីរវាង រដ្ឋអាជ្ញា ទល់នឹង Milošević*, សំណុំរឿងលេខ IT-98-29/1-A, សាលដីកា, អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩, កថាខណ្ឌ ១០៨។ តុលាការ ICTY, *រឿងក្តីរវាង រដ្ឋអាជ្ញា ទល់នឹង Stakić*, សំណុំរឿងលេខ IT-97-24-T, សាលក្រម, អង្គជំនុំជម្រះសាលាដំបូង II, ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៣ ("សាលក្រម *Stakić* (ICTY)"), កថាខណ្ឌ ៥៨៧។ តុលាការ ICTR, *រឿងក្តីរវាង រដ្ឋអាជ្ញា ទល់នឹង Akayesu*, សំណុំរឿងលេខ ICTR-96-4-T, សាលក្រម, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៨ ("សាលក្រម *Akayesu* (ICTR)"), កថាខណ្ឌ ៥៨៩។ តុលាការ SCSL, *រឿងក្តីរវាង រដ្ឋអាជ្ញា ទល់នឹង Taylor*, សំណុំរឿងលេខ SCSL-03-01-T, សាលក្រម, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៩៨ ("សាលក្រម *Akayesu* (ICTR)"), កថាខណ្ឌ ៤១២។ តុលាការ ICTR, *រឿងក្តីរវាង រដ្ឋអាជ្ញា ទល់នឹង* Bikindi, សំណុំរឿងលេខ ICTR-01-72-T, សាលក្រម, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៨, កថាខណ្ឌ ៤២៩។

01648342

នៃចេតនាប្រយោល)[286]។ ចំណុចចុងក្រោយ ទាក់ទងនឹងការតវ៉ារបស់សហមេធាវីទាក់ទងនឹងការសំអាងរបស់អង្គជំនុំជម្រះតុលាការកំពូលលើច្បាប់ក្នុងស្រុកដែលបានប្រកាសក្រោយឆ្នាំ១៩៧៥ ថាបានគាំទ្រចេតនាប្រយោល សហព្រះរាជអាជ្ញាសន្និដ្ឋានថា ឯកសារសំអាង ដែលអង្គជំនុំជម្រះតុលាការកំពូលបានពឹងផ្អែកភាគច្រើនគឺមុនឆ្នាំ១៩៧៥[287]។

៩៨. ទាក់ទងនឹង JCE សហព្រះរាជអាជ្ញាលើកទឡ្ហីករណ៍ថា សហមេធាវីខកខានមិនបានបំពេញបទដ្ឋាននៃការបង្ហាញអំពីភាពលំអៀងជាក់ស្តែង និង/ឬ អាការៈនៃភាពលំអៀងនៅក្នុងការរកឃើញរបស់ចៅក្រមរងបណ្តឹងឧិតចិត្តស្តីពីវិសាលភាពនៃផែនការឧក្រិដ្ឋកម្មរួមរបស់ JCE ឬថា ការរកឃើញនោះ មិនតំណាងការអនុវត្តច្បាប់ពិតប្រាកដ[288]។ សហព្រះរាជអាជ្ញាអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះតុលាការកំពូលសម្រេចស្របនឹងយុត្តិសាស្ត្រដែល អ.វ.ត.ក និងសាលាក្តីចំពោះកិច្ចបានបង្កើតឡើងយ៉ាងត្រឹមត្រូវអំពីធាតុផ្សំអត្តនោម័តិសម្រាប់ JCE I[289]។

៩៩. ទាក់ទងទៅនឹងការកំណត់បទចោទចំពោះអង្គហេតុក្នុងសំណុំរឿង ០០២/១ សហព្រះរាជអាជ្ញាអះអាងថា ការចោទប្រកាន់របស់សហមេធាវី មិនបំពេញបទដ្ឋានខ្ពស់នៃការបង្ហាញភាពលំអៀងជាក់ស្តែង និង/ឬ អាការៈនៃភាពលំអៀងរបស់ចៅក្រមរងបណ្តឹងឧិតចិត្ត[290]។ សហព្រះរាជអាជ្ញាតវ៉ាថា យោងតាមវិធាន ១១០(២) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូលបានកំណត់បទចោទលើអង្គហេតុយ៉ាងស្របច្បាប់ពីការសម្លាប់រង្គាលទៅជាអំពើមនុស្សឃាត[291] (ប្រព្រឹត្តដោយចេតនាប្រយោលនៅក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី ២) ដោយសារការកំណត់បទចោទនេះពុំបានបន្ថែមធាតុផ្សំថ្មីនោះឡើយ[292]។ សហព្រះរាជអាជ្ញាបន្តទៀតថា ការរកឃើញរបស់អង្គជំនុំជម្រះតុលាការកំពូលចំពោះបទឧក្រិដ្ឋរួមទាំងអំពើអមនុស្សធម៌ផ្សេងទៀតក្នុងកំឡុងពេលផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី ២ ក្រោមការ

---

[286] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (៥), កថាខណ្ឌ ៥៤-៥៥ *ដែលយោងទៅលើ* សាលដីកាលើសំណុំរឿង ០០២/១ (F36), កថាខណ្ឌ ៣៩៥ *ដែលសំអាងលើ*ករណីរដ្ឋសាស្ត្រ, ទំព័រ ១៨៩-២០៧, ២៣៥-២៤១, ២៥៣, ២៦៣, ២៧១, ២៩០។

[287] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (៥), កថាខណ្ឌ ៥៦។

[288] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (៥), កថាខណ្ឌ ៥៧-៥៩។

[289] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (៥), កថាខណ្ឌ ៦០។

[290] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (៥), កថាខណ្ឌ ៦១។

[291] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (៥), កថាខណ្ឌ ៦២។

[292] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (៥), កថាខណ្ឌ ៦២។

ទទួលខុសត្រូវ JCE គឺមានលក្ខណៈសមស្របពីព្រោះអង្គជំនុំជម្រះសាលាដំបូងបានទទួលអង្គហេតុទាំងនោះ ដូច្នេះខៀវ សំផន បានការពារខ្លួនស្របតាមការរកឃើញនេះ ហើយសិទ្ធិរបស់គាត់ត្រូវបានការពារយ៉ាងពេញលេញ[293] ។ នៅចុងបញ្ចប់ សហព្រះរាជអាជ្ញាអះអាងថា សហមេធាវីខកខានមិនបានបង្ហាញកំហុសណាមួយចំពោះការផ្តន្ទាទោសលើឧក្រិដ្ឋកម្មទាំងនេះអនុលោមតាម JCE ដែលជាជំនួយនៃការសម្រេចកាត់ទោសដាក់ពន្ធនាគារអស់មួយជីវិត ដោយសារថា ការកាត់ទោសនេះគឺផ្អែកលើការប្រព្រឹត្តរួមទាំងមូលរបស់ជនជាប់ចោទ ហើយមិនមានឋានានុក្រមជាប់មកជាមួយនៃភាពធ្ងន់ធ្ងរសម្រាប់ទម្រង់នៃការទទួលខុសត្រូវឡើយ[294]។

## ២. ការពិភាក្សា

១០០. ក្រុមប្រឹក្សាជំនុំជម្រះពិសេសសង្កេតឃើញថា សហមេធាវីជំទាស់នឹងការរកឃើញនៅក្នុងសាលដីកានៃសំណុំរឿង ០០២/១ ដែលទាក់ទងនឹង៖ (i) គោលការណ៍នីត្យានុកូលភាព[295] (ii) *ចេតនាអត្តនោម័តិ* នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់អំពើមនុស្សឃាត[296] (iii) សហឧក្រិដ្ឋកម្មរួម (JCE)[297] និង (iv) ការកំណត់ប្រភេទបទល្មើស[298]។ សហមេធាវីសន្និដ្ឋានថា កំហុសដូចបានអះអាងនេះពិតណាស់មិនមែនជាលទ្ធផលនៃការអនុវត្តច្បាប់ និងបង្ហាញអំពីភាពលំអៀងរបស់ចៅក្រមរងបណ្តឹងឧទ្ធរណ៍ដិតចិត្ត[299] ។ ក្រុមប្រឹក្សាជំនុំជម្រះពិសេស នឹងវាយតម្លៃអង្គសេចក្តីនៃការតវ៉ានីមួយក្នុងចំណោមការតវ៉ាទាំងនេះម្តងមួយៗ។

១០១. ជាបញ្ហាបឋម ក្រុមប្រឹក្សាជំនុំជម្រះពិសេសរំលឹកថា ហើយភាគីក៏ឯកភាព[300] - នៅពេលដែលការចោទប្រកាន់អំពីភាពលំអៀងបានប្តឹងដោយផ្អែកលើមូលដ្ឋាននៃសេចក្តីសម្រេចតុលាការ ក្រុមប្រឹក្សាជំនុំ

[293] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (៥), កថាខណ្ឌ ៦២-៦៥។

[294] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (៥), កថាខណ្ឌ ៦៦។

[295] សំណើរបស់លោក ខៀវ សំផន សុំប្តឹងដិតចិត្តចៅក្រម (១), កថាខណ្ឌ ៨១-៨២។

[296] សំណើរបស់លោក ខៀវ សំផន សុំប្តឹងដិតចិត្តចៅក្រម (១), កថាខណ្ឌ ៨២-៨៤។

[297] សំណើរបស់លោក ខៀវ សំផន សុំប្តឹងដិតចិត្តចៅក្រម (១), កថាខណ្ឌ ៨៥-៩២។

[298] សំណើរបស់លោក ខៀវ សំផន សុំប្តឹងដិតចិត្តចៅក្រម (១), កថាខណ្ឌ ៩៣-១០៩។

[299] សំណើរបស់លោក ខៀវ សំផន សុំប្តឹងដិតចិត្តចៅក្រម (១), កថាខណ្ឌ ៧៦, ៧៩។

[300] សំណើរបស់លោក ខៀវ សំផន សុំប្តឹងដិតចិត្តចៅក្រម (១), កថាខណ្ឌ ៧៧-៧៨។ ចម្លើយតបរបស់សហព្រះរាជអាជ្ញា (៥), កថាខណ្ឌ ៣៨។

ជម្រះពិសេសមានកាតព្វកិច្ចពិនិត្យអង្គសេចក្តីនៃសេចក្តីសម្រេចតុលាការ ដែលបានដកស្រង់ជាភស្តុតាងនៃភាពលំអៀង[301]។ គោលបំណងនៃការពិនិត្យឡើងវិញនោះមិនមែនដើម្បីរកកំហុសនោះទេ ប៉ុន្តែដើម្បីកំណត់ថាតើប្រសិនបើមានមែន កំហុសបែបនេះបង្ហាញថា ចៅក្រមពិតជាមានភាពលំអៀង ឬ អាការៈនៃភាពលំអៀង ផ្អែកលើលក្ខខណ្ឌសត្យានុម័តដូចបានពិភាក្សាខាងលើដែរឬទេ[302]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសសង្កេតឃើញថា វាមិនគ្រប់គ្រាន់ដោយគ្រាន់តែភាគីចោទប្រកាន់អំពីកំហុសអង្គច្បាប់ ប្រសិនបើមាននោះទេ[303]។ ផ្ទុយទៅវិញ ភាគីត្រូវបង្ហាញថា "សេចក្តីសម្រេចទាំងនេះត្រូវបាន ឬ នឹងត្រូវបានយល់ឃើញយ៉ាងសមហេតុផលថា ជាលទ្ធផលនៃបុរេវិនិច្ឆ័យប្រឆាំងនឹងម្ចាស់បណ្តឹង ដែលមិនមែនជាការអនុវត្តច្បាប់ពិតប្រាកដ ផ្អែកលើលទ្ធផលនៃបកស្រាយច្បាប់ ឬ ការវាយតម្លៃរបស់ចៅក្រមលើនោះទៅលើអង្គហេតុនានា"[304]។ ដូច្នេះ ការមិនឯកភាពរបស់ភាគីជាមួយនឹងអង្គសេចក្តីនៃសេចក្តីសម្រេច មិនមែនជាមូលដ្ឋាន

---

[301] សំអាងហេតុចំពោះសេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រមនៅក្នុងសំណុំរឿង ០០២/២ (E314/12/1), កថាខណ្ឌ ៣៦។ សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំប្តឹងជំទាស់ចៅក្រម (ឯកសារលេខ ៧), កថាខណ្ឌ ៣៤។ តុលាការ ICTR, *រឿងក្តីរវាង រដ្ឋអាជ្ញា ទល់នឹង* Ntahobali, សំណុំរឿងលេខ ICTR-97-21-T, សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម, The Bureau, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០៦ ("សេចក្តីសម្រេចលើសំណើរបស់ *Ntahobali* (ICTR)"), កថាខណ្ឌ ១២។ *Sesay និងអ្នកផ្សេងទៀត*, សេចក្តីសម្រេច (SCSL), កថាខណ្ឌ ៦២។ តុលាការ ICTR, *រឿងក្តីរវាង រដ្ឋអាជ្ញា ទល់នឹង* Seromba, សំណុំរឿងលេខ ICTR-2001-66-T, សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម, ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៦ ("សេចក្តីសម្រេចលើសំណើរបស់ *Seromba* (ICTR)"), កថាខណ្ឌ ១២។

[302] សំអាងហេតុចំពោះសេចក្តីសម្រេចលើបណ្តឹងជំទាស់ ក្នុងសំណុំរឿង ០០២/២ (E314/12/1), កថាខណ្ឌ ៣៦ *ដែលសំអាងលើ*សេចក្តីសម្រេច *Seromba* (ICTR), កថាខណ្ឌ ១២។ សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំប្តឹងជំទាស់ចៅក្រម (ឯកសារលេខ ៧), កថាខណ្ឌ ៣៤ *ដែលសំអាងលើ*សេចក្តីសម្រេច *Ntahobali* (ICTR), កថាខណ្ឌ ១២។ *សូមមើល ខាងលើផងដែរ* កថាខណ្ឌ ៦៣-៦៤ ។

[303] សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំប្តឹងជំទាស់ចៅក្រម (ឯកសារលេខ ៧), កថាខណ្ឌ ៣៤ *ដែលសំអាងលើ*សេចក្តីសម្រេច *Ntahobali* (ICTR), កថាខណ្ឌ ១២។ សេចក្តីសម្រេច *Seromba* (ICTR), កថាខណ្ឌ ១២។ សេចក្តីសម្រេចលើបណ្តឹងជំទាស់ (E55/4), កថខខណ្ឌ ១៣។ សំអាងហេតុចំពោះសេចក្តីសម្រេចលើបណ្តឹងជំទាស់ ក្នុងសំណុំរឿង ០០២/២ (E314/12/1) ,កថាខណ្ឌ ៣៦។ តុលាការ ICTR, *រឿងក្តីរវាង រដ្ឋអាជ្ញា ទល់នឹង* Karemera *និងជនជាប់ចោទផ្សេងទៀត*, សំណុំរឿងលេខ ICTR-98-44-T, សេចក្តីសម្រេចលើសំណើរបស់ Karemera សុំប្តឹងជំទាស់ចៅក្រមជំនុំជម្រះក្តី, ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៤ ("សេចក្តីសម្រេចលើសំណើរបស់ *Karemera និងជនជាប់ចោទផ្សេងទៀត* (ICTR)"), កថាខណ្ឌ ១៣។

[304] សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំប្តឹងជំទាស់ចៅក្រម (ឯកសារលេខ ៧)៎ កថាខណ្ឌ ៣៤ *ដែលសំអាងលើ* សេចក្តីសម្រេច *Ntahobali* (ICTR), កថាខណ្ឌ ១២។ សេចក្តីសម្រេច *Seromba* (ICTR) កថាខណ្ឌ ១២។ ("សេចក្តីសម្រេចលើសំណើរបស់ *Karemera និងជនជាប់ចោទផ្សេងទៀត* (ICTR)"), កថាខណ្ឌ ១៣។ សេចក្តីសម្រេចលើសំណើរបស់ *និងជនជាប់ចោទផ្សេងទៀត* (SCSL), កថាខណ្ឌ ៦២។

ត្រឹមត្រូវសម្រាប់ធ្វើបណ្ដឹងជិតចិត្តនោះទេ ប៉ុន្តែគួរតែត្រូវបានដោះស្រាយនៅក្នុងបណ្ដឹងឧទ្ធរណ៍[305]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសបានបញ្ជាក់សាជាថ្មីថា ទោះបីខ្លួនមិនច្រានចោលទាំងស្រុងនូវលទ្ធភាពដែលថា សេចក្ដីសម្រេចរបស់ចៅក្រមអាចគ្រប់គ្រាន់ដោយខ្លួនឯងក្នុងការបង្ហាញភាពលំអៀងពិតប្រាកដក៏ដោយ ខ្លួនអាចសម្រេចដូច្នេះតែក្នុងករណីអញ្ញត្រកម្មស្រួចស្រាលបំផុតតែប៉ុណ្ណោះ[306]។

១០២. ក្រុមប្រឹក្សាជំនុំជម្រះពិសេស តម្កល់លក្ខខណ្ឌនេះសម្រាប់ការពិនិត្យមើលការចោទប្រកាន់អំពីភាពលំអៀងដោយផ្អែកលើសេចក្ដីសម្រេចរបស់តុលាការ ដែលអង្គជំនុំជម្រះ អ.វ.ត.ក និងសាលាក្ដីឧក្រិដ្ឋកម្មអន្តរជាតិជាច្រើន អនុវត្តតាម។ នៅពេលងាកទៅពិនិត្យការរកឃើញដោយមានកំហុសនៅក្នុងសាលដីកានៃសំណុំរឿង ០០២/១ ក្រុមប្រឹក្សាជំនុំជម្រះពិសេសនឹងពុំមែនកំណត់ថាតើការរកឃើញដែលធ្វើឡើងដោយចៅក្រមរងបណ្ដឹងជិតចិត្ត គឺជា ឬ អាចមានកំហុសអង្គច្បាប់នោះទេ ប៉ុន្តែនឹងកំណត់ថាតើការរកឃើញទាំងនេះ អាចត្រូវបានយល់ឃើញថាបានបង្កើតអាការៈនៃភាពលំអៀងចំពោះ ខៀវ សំផន ដែរឬទេ។

១០៣. ចំណុចទី១ ទាក់ទងនឹងការរកឃើញលើគោលការណ៍នីត្យានុកូលភាព ក្រុមប្រឹក្សាជំនុំជម្រះពិសេសសង្កេតឃើញថា ការអះអាងរបស់សហមេធាវីថា ចៅក្រមរងបណ្ដឹងជិត្តចិត្តបានអនុវត្ត "វិធីសាស្ត្រនីតិប្បញ្ញត្តិដាក់ទណ្ឌកម្ម" និង "បានបំបាត់សារធាតុនៃគោលការណ៍នីត្យានុកូលភាព ដោយលើកវាឡើងដើម្បីបង្គ្រប់កិច្ចតែប៉ុណ្ណោះ" ដោយងាកចេញពីយុត្តិសាស្ត្ររបស់ អ.វ.ត.ក[307] គឺមិនគួរឲ្យជឿជាក់នោះទេ។ អង្គជំនុំជម្រះពិសេសកត់សម្គាល់ថា ផ្ទុយពីសហមេធាវី អង្គជំនុំជម្រះតុលាការកំពូលមិនបានរកឃើញថា "វាជាការគ្រប់គ្រាន់កាលណាមានឧក្រិដ្ឋកម្ម ឬ ទម្រង់នៃការទទួលខុសត្រូវ ដែលមានចែងនៅក្នុងច្បាប់ទំនៀម

---

[305] សេចក្ដីសម្រេចលើសំណើរបស់ ខៀវ សំផន សុំប្ដឹងជិតចិត្តចៅក្រម (ឯកសារលេខ ៧), កថាខណ្ឌ ៣៥ *ដែលសំអាងលើ* សេចក្ដីសម្រេច *Ntahobali* (ICTR), កថាខណ្ឌ ១១។ *Blagojević និងជនជាប់ចោទផ្សេងទៀត,* សេចក្ដីសម្រេចលើពាក្យសុំ ((ICTY), កថាខណ្ឌ ១៤។ សេចក្ដីសម្រេចលើបណ្ដឹងជិតចិត្ត (E55/4), កថាខណ្ឌ ១៣។ សំអាងហេតុចំពោះសេចក្ដីសម្រេចលើបណ្ដឹងជិតចិត្ត ក្នុងសំណុំរឿង ០០២/២ (E314/12/1), កថាខណ្ឌ ៣៦។

[306] សេចក្ដីសម្រេចលើសំណើរបស់ *Ntahobali* (ICTR), កថាខណ្ឌ ១១ *ដែលយោងទៅ*តុលាការ ICTY, សេចក្ដីសម្រេចលើសំណើរបស់ *Blagojević និងជនជាប់ចោទផ្សេងទៀត,* សេចក្ដីសម្រេចលើពាក្យសុំរបស់ Blagojevic ដោយអនុលោមតាមវិធាន ១៥(ខ) ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ("សេចក្ដីសម្រេចលើសំណើរបស់ *Blagojević និងជនជាប់ចោទផ្សេងទៀត* (ICTY)"), កថាខណ្ឌ ១៤។ សេចក្ដីសម្រេចលើសំណើរបស់ *Karemera និងជនជាប់ចោទផ្សេងទៀត* (ICTR), កថាខណ្ឌ ១២ *ដែលសំអាងលើ*រឿងក្ដីរវាង *Liteky ទល់នឹង សហរដ្ឋអាមេរិក*, សំណុំរឿងលេខ 510 US 540, 555 (1994)។

[307] សំណើរបស់លោក ខៀវ សំផន សុំប្ដឹងជិតចិត្តចៅក្រម (១), កថាខណ្ឌ ៨០។

ទម្លាប់អន្តរជាតិ នៅម៉ែយអង្គហេតុ និងកាលណាជនជាប់ចោទមានមុខតំណែងខ្ពស់”[308]។ ផ្ទុយមកវិញ អង្គជំនុំជម្រះតុលាការកំពូលបានអនុវត្តសំអាងហេតុនៃសាលដីកានៅក្នុងសំណុំរឿង ០០១ ដែលលើកឡើងថា បទល្មើស និងទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានចោទប្រកាន់នៅចំពោះមុខ អ.វ.ត.ក ត្រូវតែមានអត្ថិភាពនៅក្នុងច្បាប់ជាតិ ឬ ច្បាប់អន្តរជាតិ នៅពេលចោទប្រកាន់អំពើព្រហ្មទណ្ឌ ហើយជនជាប់ចោទត្រូវដឹង និងអាចប្រមើលមើលឃើញថាមានច្បាប់ចែង[309]។ ទោះបីជាយល់ស្របជាមួយ ខៀវ សំផន ថា “លក្ខខណ្ឌតម្រូវនៃភាពអាចយល់ដឹងជាមុនបានថា មានច្បាប់ចែង និងជាបទល្មើស ត្រូវតែកំណត់តាមរយៈការវិភាគជាសត្យានុម័ត មានន័យថា បទឧក្រិដ្ឋ និងទម្រង់នៃការទទួលខុសត្រូវ ត្រូវតែអាចយល់ដឹងបានជាមុនថាជាបទល្មើស និងមានច្បាប់ចែងជាទូទៅ” ក៏អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា វាមិនមែនមិនសមហេតុផលដែលអង្គជំនុំជម្រះសាលាដំបូងពិចារណាលើឋានៈជាន់ខ្ពស់ ដែលកាន់កាប់ដោយ ខៀវ សំផន ក្នុងការវាយតម្លៃលើអនុលោមភាពជាមួយគោលការណ៍នីត្យានុកូលភាពនោះដែរ[310]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសសង្កេតឃើញថា វិធីសាស្ត្រនេះគឺស្របនឹងគោលការណ៍ ដែលបានអនុវត្តនៅក្នុងសាលដីកាក្នុងសំណុំរឿង ០០១[311]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសកត់សម្គាល់បន្ថែមទៀតថា សំអាងហេតុនៃសាលដីកានៅក្នុងសំណុំរឿង ០០២/១ ទាក់ទងទៅនឹងលក្ខខណ្ឌនៃភាពអាចព្យាករណ៍បានគឺជាការដកស្រង់ដោយផ្ទាល់ចេញពីសាលដីកាសំណុំរឿង ០០១[312] និងឆ្លុះបញ្ចាំងអំពីវិធីសាស្ត្ររបស់អង្គជំនុំជម្រះ អ.វ.ត.ក និងតុលាការ ICTY អំពីបញ្ហានេះ[313]។ ដូច្នេះ ក្រុមប្រឹក្សាជំនុំជម្រះពិសេស មិនជឿជាក់ថា ការរកឃើញរបស់

---

[308] សំណើរបស់លោក ខៀវ សំផន សុំប្តឹងដិតចិត្តចៅក្រម (១), កថាខណ្ឌ ៨០ *ដែលយោងទៅលើ* សាលដីកាលើសំណុំរឿង ០០២/១ (F36), កថាខណ្ឌ ៧៦១-៧៦២, ៧៦៤។

[309] សាលដីកាលើសំណុំរឿង ០០២/១ (F36), កថាខណ្ឌ ៧៦១-៧៦២ *ដែលសំអាងលើ* សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១ (F28), កថាខណ្ឌ ៩១, ៩៦។

[310] *ដែលយោងទៅលើ* សាលដីកាលើសំណុំរឿង ០០២/១ (F36), កថាខណ្ឌ ៧៦១។

[311] សាលដីកាសម្រេចលើបណ្តឹងសារទុក្ខក្នុងសំណុំរឿង ០០១ (F28), កថាខណ្ឌ ២៨០ (“ជនជាប់ចោទ ក្នុងនាមជាកម្មាភិបាលម្នាក់នៃរបបកម្ពុជាប្រជាធិបតេយ្យ អាចយល់ដឹងយ៉ាងគ្រប់គ្រាន់ថា ខ្លួននឹងអាចត្រូវចោទប្រកាន់ពីអំពើសកម្ម ឬ អកម្មនៃការធ្វើទុក្ខបុកម្នេញ ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩”)។

[312] *ផ្ទុយពី* សំណើរបស់លោក ខៀវ សំផន សុំប្តឹងដិតចិត្តចៅក្រម (១), កថាខណ្ឌ ៨០ *ដែលយោងទៅលើ* សាលដីកាលើសំណុំរឿង ០០២/១ (F36), កថាខណ្ឌ ៧៦២, ៧៦៥។ *សូមមើល* សាលដីកាលើសំណុំរឿង ០០២/១ (F36), កថាខណ្ឌ ៧៦២ *ដែលសំអាងលើ*សាលដីកាសម្រេចលើបណ្តឹងសារទុក្ខក្នុងសំណុំរឿង ០០១ (F28), កថាខណ្ឌ ៩៦ *ដែលដកស្រង់*សេចក្តីសម្រេចលើរឿងក្តីរបស់ *Hadžihasanović និង Kubura*, កថាខណ្ឌ ៣៤។

[313] *ផ្ទុយពី*សំណើរបស់លោក ខៀវ សំផន សុំប្តឹងដិតចិត្តចៅក្រម (១), កថាខណ្ឌ ៨១ និងជើងទំព័រយោងលេខ ១២២។ *សូមមើល ឧទា.*, សាលដីកាលើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០២ (D427/1/30), កថាខណ្ឌ ២៣៥ *ដែលយោងទៅលើ* សាលដីកាលើ

អង្គជំនុំជម្រះតុលាការកំពូល លើគោលការណ៍នីត្យានុកូលភាពបានផ្អែកលើសំអាងច្បាប់មិនត្រឹមត្រូវ ឬចំណុះការពិចារណាមិនសមស្រប ដែលបង្ហាញអំពីភាពលំអៀងប្រឆាំងនឹង ខៀវ សំផន នោះឡើយ។

១០៤. ចំណុចទី២ ទាក់ទងនឹងការរកឃើញអំពីធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់នៃអំពើមនុស្សឃាត ក្រុមប្រឹក្សាជំនុំជម្រះពិសេសកត់សំគាល់ថា សហមេធាវីចោទប្រកាន់អំពីភាពលំអៀង ដោយសារការទទួលយកនិយមន័យទូលំទូលាយអំពីធាតុផ្សំអត្តនោម័តនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់នៃអំពើមនុស្សឃាត ដែលរួមបញ្ចូលទាំង*ចេតនាប្រយោល*[314]។ ក្រុមពិសេសជំនុំជម្រះពិសេស រំលឹកថា ដើម្បីបង្ហាញអំពីភាពលំអៀង ត្រូវបង្ហាញឱ្យឃើញថា ការរកឃើញនេះ "ដែលមិនមែនជាការអនុវត្តច្បាប់ពិតប្រាកដ ផ្អែកលើលទ្ធផលនៃបកស្រាយច្បាប់ "[315]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសសង្កេតឃើញថា ដើម្បីរកឃើញថា ធាតុផ្សំអត្តនោម័តិនៃអំពើមនុស្សឃាត ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវតែយល់ថាមានរួមបញ្ចូលទាំងចេតនាដោយផ្ទាល់ និង*ចេតនាប្រយោល* អង្គជំនុំជម្រះតុលាការកំពូលបានវិភាគលំអិតអំពីយុត្តិសាស្ត្ររបស់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិ និងច្បាប់ព្រហ្មទណ្ឌជាតិស្តីពីបញ្ហានេះ[316]។

១០៥. ផ្ទុយពីការអះអាងរបស់សហមេធាវី[317] ការពិនិត្យឡើងវិញអំពីយុត្តិសាស្ត្ររបស់ អ.វ.ត.ក និងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិបានបង្ហាញថា ការកំណត់និយមន័យអំពីធាតុផ្សំអត្តនោម័តិជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងឆ្នាំ ១៩៧៥ ដើម្បីរួមបញ្ចូល *ចេតនាប្រយោល* គឺជាលទ្ធភាពមួយនៃការបកស្រាយអំពី

សំណុំរឿង ០០២ ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (D97/14/15), កថាខណ្ឌ ៤៥។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០២ (D427/2/15), កថាខណ្ឌ ១០៦។ សេចក្តីសម្រេចលើសំណើរបស់ *Hadžihasanović និង Kubura* (ICTY), កថាខណ្ឌ ៣៤។ តុលាការ ICTY, រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង* Milutinović *និងជនជាប់ចោទផ្សេងទៀត*, សំណុំរឿងលេខ IT-99-37-AR72, សេចក្តីសម្រេចលើសំណើរបស់ Dragoljub Ojdanić ជំទាស់តវ៉ាលើបញ្ហាយុត្តាធិការ – *សហឧក្រិដ្ឋកម្មរួម*, អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ ៤២។

[314] សំណើរបស់លោក ខៀវ សំផន សុំប្តឹងដិតចិត្តចៅក្រម (១), កថាខណ្ឌ ៨២។

[315] សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំប្តឹងដិតចិត្តចៅក្រម (ឯកសារលេខ ៧), កថាខណ្ឌ ៣៤ *ដែលសំអាងលើសេ*ចក្តីសម្រេចលើសំណើរបស់ *Ntahobali* (ICTR), កថាខណ្ឌ ១២។ សេចក្តីសម្រេចលើសំណើរបស់ *Seromba* (ICTR), កថាខណ្ឌ ១២។ សេចក្តីសម្រេចលើសំណើរបស់ *Karemera និងជនជាប់ចោទផ្សេងទៀត* (ICTR), កថាខណ្ឌ ១៣។

[316] សាលដីកាលើសំណុំរឿង ០០២/១ (F36), កថាខណ្ឌ ៣៨៧-៤១០។

[317] សំណើរបស់លោក ខៀវ សំផន សុំប្តឹងដិតចិត្តចៅក្រម (១), កថាខណ្ឌ ៨៣ *ដែលយោងទៅលើ* សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល (០០២/០២) (E457/6/4/1), កថាខណ្ឌ ៣៩៤-៤២៩។

យុត្តិសាស្ត្រពាក់ព័ន្ធ ហើយវាទាក់ទងយ៉ាងពិតប្រាកដនឹងការអនុវត្តច្បាប់[318]។ អង្គជំនុំជម្រះតុលាការកំពូលបានវិភាគយ៉ាងលម្អិតអំពីភាពអាចអនុវត្តបាននៃសញ្ញាណ *ចេតនាប្រយោល* នៅក្នុងសម័យក្រោយសង្គ្រាមលោកលើកទី២ និងនិយមន័យអំពីធាតុផ្សំអត្តនោម័តិនៅក្នុងច្បាប់ជាតិមុនឆ្នាំ១៩៧៥[319]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសបញ្ជាក់សាជាថ្មីថា "ការខ្វែងគំនិតលើខ្លឹមសារនៃសេចក្តីសម្រេចគឺជាបញ្ហាសម្រាប់ការប្តឹង

[318] *សូមមើល ឧទា.*, សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១ (F28) កថាខណ្ឌ ៣៣៣ *ដែលសំអាងលើ*សាលក្រមសំណុំរឿង ០០១ (E188), កថាខណ្ឌ ៣៣៣ *ដែលយោងទៅ*តុលាការ ICTY, *រដ្ឋអាជ្ញា ទល់នឹង* Blagojević *និង* Jokić, សំណុំរឿងលេខ IT-02-60-T, សាលក្រម, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥, កថាខណ្ឌ ៥៥៦។ សាលក្រម *Stakić* (ICTY), កថាខណ្ឌ ៥៨៧ ("ដោយពិចារណាលើ*ធាតុចេតន*កនៃឧក្រិដ្ឋកម្មនេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ទាំង ចេតនាផ្ទាល់ *(dolus directus)* និង ចេតនាប្រយោល *(dolus eventualis)* គឺមានលក្ខណៈគ្រប់គ្រាន់ដើម្បីបង្ហាញពីឧក្រិដ្ឋកម្មស្តីពីអំពើមនុស្សឃាត ស្របតាមមាត្រា ៣")។ តុលាការ ICTY, *រដ្ឋអាជ្ញា ទល់នឹង Krnojelac*, សំណុំរឿងលេខ IT-97-25-T, សាលក្រម, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២, កថាខណ្ឌ ៣២៤។ តុលាការ ICTY, *រដ្ឋអាជ្ញា ទល់នឹង Kvočka និងជនជាប់ចោទផ្សេងទៀត*, សំណុំរឿងលេខ ., IT-98-30/1-A, សាលដីកា, អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥, កថាខណ្ឌ ២៦១។ សាលក្រម *Akayesu* (ICTR) កថាខណ្ឌ ៥៨៩។ តុលាការ ICTY, *រដ្ឋអាជ្ញា ទល់នឹង* Delalić *និងជនជាប់ចោទផ្សេងទៀត*, សំណុំរឿងលេខ IT-96-21-T, សាលក្រម, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ("សាលក្រម *Delalić និងជនជាប់ចោទផ្សេងទៀត* (ICTY)"), កថាខណ្ឌ ៤២០-២៣៩ (ក្រោយពីបានពិនិត្យពិច័យទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ពិធីសារបន្ថែមទី ១ និងសេចក្តីអត្ថាធិប្បាយរបស់ពិធីសារនេះ ព្រមទាំងច្បាប់យុត្តិសាស្ត្ររួចមក អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា "គោលបំណងចាំបាច់ មានន័យថា *ធាតុចេតនា* ដែលតម្រូវឱ្យបង្ហាញពីការធ្វើមនុស្សឃាតដោយចេតនា និងការធ្វើមនុស្សឃាត ដូចបានទទួលស្គាល់នៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ ពិតជាមានមែន ដែលតម្រូវឱ្យបង្ហាញពីចេតនារបស់ជនជាប់ចោទក្នុងការសម្លាប់ ឬការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ដោយសារការធ្វេសប្រហែស មិនយកចិត្តទុកដាក់ទៅលើអាយុជីវិតមនុស្ស")។ ក្នុងន័យនេះ អង្គជំនុំជម្រះពិសេស សូមរម្លឹកថា "ធាតុផ្សំនៃបទល្មើសស្តីពីការធ្វើមនុស្សឃាតដោយចេនា ដែលមានចែងនៅក្នុងមាត្រា ៦ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក គឺដូចគ្នាទៅនឹងការធ្វើមនុស្សឃាត ដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)"។*សូមមើល* សាលក្រមសំណុំរឿង ០០១ (E188), កថាខណ្ឌ ៤៣១។ *សូមមើល ផងដែរ* Antonio CASSESE, ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (រោងពុម្ពនៃសាកលវិទ្យាល័យ Oxford, បោះពុម្ពផ្សាយលើកទី២, ឆ្នាំ២០០៨) ("CASSESE, ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (២០០៨)"), ទំព័រ ៦៧-៦៩ (ដែលពិភាក្សាពីយុត្តិសាស្ត្រក្រោយសង្គ្រាមលើកលើកទី II នៃតុលាការអាល្លឺម៉ង់ ដែលគ្រប់គ្រងដោយច្បាប់ស្តីពីក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ ស្តីពីសញ្ញាណនៃ*ចេតនាប្រយោល* (*dolus eventualis*) ឬការធ្វេសប្រហែស ចំពោះ*ធាតុចេតន*កនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)។

[319] *សូមមើល* សាលដីកាលើសំណុំរឿង ០០២/១ (F36), កថាខណ្ឌ ៣៩៣-៤០៩ *ដែលយោងទៅលើ*ករណីវេជ្ជសាស្ត្រ *រួមមាន* កថាខណ្ឌ ១៨៩-២០៧, ២៣៥-២៤១, ២៤៨, ២៥៣-២៦៣, ២៧១, ២៩០។ *ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា* (*Code Pénal et Lois Pénales*) ឆ្នាំ១៩៥៦ មាត្រា ៥០៣-៥០៥។

ឧទ្ធរណ៍ មិនមែនជាបញ្ហាសម្រាប់ការដាក់បណ្តឹងជំទាស់ឡើយ"[320]។ ដោយពិចារណាលើភាពមិនគ្រប់គ្រាន់នៃទឡ្ហីករណ៍ស្តីពី "ការបកស្រាយខុស" និង ការសំអាង "ដោយខុសច្បាប់" លើយុត្តិសាស្ត្រនៃសាលាក្តីព្រហ្មទណ្ឌអន្តរជាតិ[321] ក្រុមប្រឹក្សាជំនុំជម្រះពិសេសយល់ឃើញថា សហមេធាវីខកខានមិនបានបង្ហាញឲ្យបានសមហេតុផលអំពីអាការៈនៃភាពលំអៀងរបស់ចៅក្រមរងបណ្តឹងជំទាស់។

១០៦. ចំណុចទី៣ ចំពោះការរកឃើញដោយមានកំហុសអំពី JCE ក្រុមប្រឹក្សាជំនុំជម្រះពិសេសចោទប្រកាន់អំពីភាពលម្អៀង ដែលផ្តើមចេញពីដីកាសម្រេចលើភាពអាចអនុវត្តបាននៃ *ចេតនាប្រយោល*ទាក់ទងនឹងធាតុផ្សំអត្តនោម័តិនៃ JCE I[322]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសសង្កេតឃើញថា សហមេធាវីបកស្រាយខុសនូវការរកឃើញរបស់អង្គជំនុំជម្រះតុលាការកំពូលលើបញ្ហានេះ។ ផ្ទុយពីការអះអាងរបស់សហមេធាវី[323] ដើម្បីរកឱ្យឃើញការរកឃើញលើ *ចេតនាប្រយោល* ដែលបង្កើតជាផ្នែកមួយនៃ JCE I អង្គជំនុំជម្រះតុលាការកំពូល បានវិភាគយ៉ាងហ្មត់ចត់លើយុត្តិសាស្ត្រអន្តរជាតិ[324]។ អង្គជំនុំជម្រះពិសេសមិនជឿជាក់ការចោទប្រកាន់របស់សហមេធាវីថា អង្គជំនុំជម្រះតុលាការកំពូល "បានបង្កើតសហឧក្រិដ្ឋកម្មរួម [កូនកាត់] មួយ ដែលបូកបញ្ចូលគ្នានូវធាតុផ្សំនៃអំពើឧក្រិដ្ឋនៃសហឧក្រិដ្ឋកម្មទម្រង់ទី I និងធាតុផ្សំនៃចេតនាឧក្រិដ្ឋទម្រង់ទី III [...] ផ្ទុយនឹងយុត្តិសាស្ត្រនៃសាលាក្តីព្រហ្មទណ្ឌអន្តរជាតិ"[325]។ ផ្ទុយមកវិញ អង្គ

---

[320] សេចក្តីសម្រេចលើបណ្តឹងជំទាស់ (E55/4), កថាខណ្ឌ ១៣។ សំអាងហេតុចំពោះសេចក្តីសម្រេចលើបណ្តឹងជំទាស់ ក្នុងសំណុំរឿង ០០២/២ (E314/12/1), កថាខណ្ឌ ៣៦។

[321] សំណើរបស់លោក ខៀវ សំផន សុំប្តឹងជំទាស់ចៅក្រម (១), កថាខណ្ឌ ៨៣។ *សូមមើល* សំណុំរឿង ០០២, សាលដីកាលើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតលេខ D250/3/3 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ និងដីកាសម្រេចលេខ D250/3/2 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ លើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី, ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០, ឯកសារ D250/3/2/1/5, កថាខណ្ឌ ២២ *ដែលសំអាងទៅ*តុលាការ ICTY, រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង* Blaškić, សំណុំរឿងលេខ IT-95-14-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤, កថាខណ្ឌ ១៣។ តុលាការ ICTR, រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Rutaganda*, សំណុំរឿងលេខ ICTR-96-3-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៣, កថាខណ្ឌ ១៨ (ដែលអង្គបុរេជំនុំជម្រះបានសម្រេចថា ខ្លួន "នឹងមិនផ្តល់ជូននូវការពិចារណាលម្អិត ចំពោះសារណាទាំងឡាយដែលមិនច្បាស់លាស់ ផ្ទុយគ្នា ឬស្រពេចស្រពិល ឬប្រសិនបើសារណាទាំងនោះកើតចេញពីភាពមិនគ្រប់គ្រាន់ជាផ្លូវការ និងជាក់ស្តែងណាមួយនោះឡើយ")។

[322] សំណើរបស់លោក ខៀវ សំផន សុំប្តឹងជំទាស់ចៅក្រម (១), កថាខណ្ឌ ៨៥-៩២។

[323] សំណើរបស់លោក ខៀវ សំផន សុំប្តឹងជំទាស់ចៅក្រម (១), កថាខណ្ឌ ៨៦។

[324] *សូមមើល* សាលដីកាលើសំណុំរឿង ០០២/១ (F36), កថាខណ្ឌ ៧៦៧-៨១០។

[325] សំណើរបស់លោក ខៀវ សំផន សុំប្តឹងជំទាស់ចៅក្រម (១), កថាខណ្ឌ ៨៦។

ជំនុំជម្រះតុលាការកំពូលបានបញ្ជាក់សាជាថ្មីថា សញ្ញាណនៃ JCE III មិនមានអត្ថិភាពនៅពេលនៃកំណត់បទចោទទាំងនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬ ជាគោលការណ៍ទូទៅនៃច្បាប់[326]។ ដោយបានវិភាគយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២ និងយុត្តិសាស្ត្ររបស់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិស្តីពី JCE[327] អង្គជំនុំជម្រះតុលាការកំពូល បានធ្វើបែងចែករវាង៖ រឿងក្តី ដែលឧក្រិដ្ឋកម្មមិនត្រូវបានរួមបញ្ចូលគោលបំណងរួម ខណៈដែលការប្រព្រឹត្តរបស់វាគឺជាការសម្រេចចិត្តស្វ័យតរបស់ជនល្មើសផ្ទាល់ (JCE III) និងរឿងក្តី ដែល "សមាជិកនៃសហឧក្រិដ្ឋកម្មរួមត្រូវទទួលយកការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងជាគោលដៅ ទាំងជាផលវិបាកដែលជៀសមិនរួចនៃគោលបំណងបឋម ឬ ទាំងគ្មានការអើពើពីយថាហេតុដែលអាចកើតឡើង" (JCE I រួមបញ្ចូល *ចេតនាប្រយោល*)[328]។ អង្គជំនុំជម្រះតុលាការកំពូល បានពិចារណាថា មានតែរឿងក្តីក្រោយនេះទេ ដែលអាចអនុវត្តបាន[329]។

---

[326] សាលដីកាលើសំណុំរឿង ០០២) ១/F36(, កថាខណ្ឌ ៧៩០-៧៩១ *ដែលក្នុងនោះបានយោងទៅ*សំណុំរឿង ០០២, សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត [*sic*] ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE), ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០, ឯកសារ D97/15/9, កថាខណ្ឌ ៧៩-៨១, ៨៣។ សំណុំរឿង ០០២, សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម, ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១, ឯកសារ E100/6, កថាខណ្ឌ ៣០-៣១។ *សូមមើល ផងដែរ* កថាខណ្ឌ ៧៩២-៨០៧ (ដែលអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា "ការទទួលខុសត្រូវផ្អែកព្រហ្មទណ្ឌ ដោយផ្អែកលើការរួមចំណែក នៅក្នុងការអនុវត្តគោលបំណងឧក្រិដ្ឋរួម នៅក្នុងអំឡុងពេលជាប់ពាក់ព័ន្ធទៅនឹងបទចោទ នៅក្នុងរឿងក្តីចំពោះមុខត្រូវបានកម្រិតត្រឹមបទឧក្រិដ្ឋដែលជាក់ស្តែង មានរួមបញ្ចូលនៅក្នុងគោលបំណងរួមតែប៉ុណ្ណោះ")។

[327] សាលដីកាលើសំណុំរឿង ០០២/១ (F36), កថាខណ្ឌ ៧៧៩-៧៨៩ *ដែលក្នុងនោះបានយោងទៅ*តុលាការ ICTY, រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Tadić*, សំណុំរឿងលេខ IT-94-1-A, សាលដីកា, អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ ដូចដែលបានកែប្រែតាមរយៈ ការកែតម្រូវទៅលើសាលដីកាឧទ្ធរណ៍ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ របស់អង្គជំនុំជម្រះសាលា, ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៩, កថាខណ្ឌ ២២៧ (ដែលយល់ឃើញថា ដើម្បីបង្ហាញពី*ពិរុទ្ធភាព*នៃ JCE គេតម្រូវឱ្យមាន "ផែនការរួម ការរៀបចំ ឬគោលបំណង ដែលបណ្តាលឱ្យ ឬចូលរួមពាក់ព័ន្ធនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មមួយ")។ តុលាការ SCSL, រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Brima និងជនជាប់ចោទផ្សេងទៀត*, សំណុំរឿងលេខ SCSL-2004-16-A, សាលដីកា, អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨, កថាខណ្ឌ ៧៦ ("គោលបំណងឧក្រិដ្ឋ ដែលកំណត់ឱ្យមាន JCE មិនមែនត្រឹមតែអាចកើតចេញតែពីគោលបំណងចុងក្រោយរបស់វាប៉ុណ្ណោះទេ ក៏ប៉ុន្តែ ក៏កើតចេញពីមធ្យោបាយផ្សេងៗ ដែលបានប្រមើលទុកជាមុន ដើម្បីសម្រេចគោលបំណងនោះផងដែរ។ គោលបំណង និងមធ្យោបាយនានាដើម្បីសម្រេចគោលបំណងនោះ បង្កបានជាការរៀបចំ ឬផែនការរួម")។

[328] សាលដីកាលើសំណុំរឿង ០០២/១ (F36), កថាខណ្ឌ ៨០៩។

[329] សាលដីកាលើសំណុំរឿង ០០២/១ (F36), កថាខណ្ឌ ៨០៩។

១០៧. យោងតាមហេតុផលខាងលើ ក្រុមប្រឹក្សាជំនុំជម្រះពិសេស សង្កេតឃើញថា ការរកឃើញនេះគួរចាត់ទុកថាជាជំរើសរបស់អង្គជំនុំជម្រះតុលាការកំពូលរវាងលទ្ធភាពនៃការបកស្រាយមួយចំនួនក្នុងដំណើរនៃការអនុវត្តច្បាប់ជាក់ស្តែងពិតប្រាកដ ពុំមែនជា "ឧបករណ៍សំខាន់ក្នុងផ្នែកសម្រេចសេចក្តីផ្តន្ទាទោស" ឬ "ជាភ័ស្តុតាងនៃការតាក់តែងកាត់កងតម្រឹមច្បាប់ឲ្យសមល្មមនឹងផ្តន្ទាទោស ខៀវ សំផន បាន" ដូចសហមេធាវីបានចោទប្រកាន់នោះឡើយ[330]។ ហេតុដូច្នេះ ក្រុមប្រឹក្សាជំនុំជម្រះពិសេស មិនជឿជាក់ថា ការរកឃើញអំពី JCE បង្ហាញឲ្យឃើញនូវអាការៈសមហេតុផលនៃភាពលំអៀងនោះឡើយ។

១០៨. ចំណុចទីបួន ទាក់ទងនឹងការរកឃើញលើការកំណត់បទចោទ ក្រុមប្រឹក្សាជំនុំជម្រះពិសេសកត់សំគាល់ថា សហមេធាវីចោទប្រកាន់អំពីភាពលំអៀង ដែលកើតឡើងពី (i) ការកំណត់បទចោទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់នៃការសម្លាប់រង្គាលទៅជាអំពើមនុស្សឃាតទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី២[331] និង (ii) ការផ្តន្ទាទោស ខៀវ សំផន ចំពោះបទឧក្រិដ្ឋក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី២ ពុំមែនទម្រង់នៃការទទួលខុសត្រូវផ្សេងទៀតនោះឡើយ[332]។

១០៩. ក្រុមប្រឹក្សាជំនុំជម្រះពិសេស កំណត់សម្គាល់បឋម ហើយភាគីយល់ស្របថា[333] មុនពេលកំណត់បទចោទ អង្គជំនុំជម្រះតុលាការកំពូលបានជូនដំណឹងដល់ភាគីទាំងអស់អំពីចេតនារបស់ខ្លួន និងបានផ្តល់ឱកាសឲ្យដាក់សេចក្តីសន្និដ្ឋានលើបញ្ហានេះ ដើម្បីធានាសិទ្ធិរបស់ជនជាប់ចោទរួចអស់ហើយ[334]។

១១០. ចំណុចទី១ ក្រុមប្រឹក្សាជំនុំជម្រះពិសេសយល់ឃើញថា ការអះអាងរបស់សហមេធាវីថា *ចេតនាប្រយោល*នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់នៃអំពើមនុស្សឃាត ត្រូវបានដាក់បញ្ចូលជាធាតុផ្សំថ្មីក្នុងអំឡុងពេលកំណត់បទចោទដោយបានរំលោភវិធាន ១១០(២) នៃវិធានផ្ទៃក្នុង[335] គឺមិនអាចជឿជាក់បា

---

[330] សំណើរបស់លោក ខៀវ សំផន សុំប្តឹងជំទាស់ចៅក្រម (១), កថាខណ្ឌ ៩១-៩២។

[331] សំណើរបស់លោក ខៀវ សំផន សុំប្តឹងជំទាស់ចៅក្រម (១), កថាខណ្ឌ ៩៣-៩៩។

[332] សំណើរបស់លោក ខៀវ សំផន សុំប្តឹងជំទាស់ចៅក្រម (១), កថាខណ្ឌ ១០០-១០៦។

[333] សំណើរបស់លោក ខៀវ សំផន សុំប្តឹងជំទាស់ចៅក្រម (១), កថាខណ្ឌ ៩៥-៩៦។ ចម្លើយតបរបស់សហព្រះរាជអាជ្ញា (៥) កថាខណ្ឌ ៦៥។

[334] សំណុំរឿង ០០២, ដីកាកំណត់កាលបរិច្ឆេទសវនាការបណ្តឹងសាទុក្ខ, ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥, ឯកសារ F30 ("ដីកាកំណត់កាលបរិច្ឆេទសវនាការបណ្តឹងសាទុក្ខ (F30)"), ទំព័រ ៥ ជើងទំព័រយោងលេខ ១១។

[335] សំណើរបស់លោក ខៀវ សំផន សុំប្តឹងជំទាស់ចៅក្រម (១), កថាខណ្ឌ ៩៧-៩៩។ វិធាន ១១០(២) នៃវិធានផ្ទៃក្នុងចែងថា (" គ្រប់ករណីទាំងអស់ អង្គជំនុំជម្រះតុលាការកំពូល អាចកែប្រែបទចោទប្រកាន់ ដែលអង្គជំនុំជម្រះសាលាដំបូងបានកំណត់។ ប៉ុន្តែ

ន។ ទទ្បីករណ៍របស់សហមេធាវីថា "ចេតនាប្រយោលមិនស្ថិតក្នុងធាតុផ្សំនៃបទសម្លាប់រង្គាលនោះទេ ហើយក៏មិនមែនជាធាតុផ្សំពាក់ព័ន្ធនៃបទចោទពីដំបូងនោះដែរ"[336] លើកឡើងខុសទំនង ពីព្រោះអ្វីដែលពាក់ព័ន្ធនៅទីនេះមិនមែនការកំណត់បទចោទពីដំបូងនោះទេ តាមពិតគឺវាទាក់ទងនឹងសំអាងអង្គហេតុ ដែលបានធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូង ដោយផ្អែកលើអង្គហេតុនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ [337] ។ ក្នុងការផ្លាស់ប្តូរការកំណត់បទចោទនៃបទសម្លាប់រង្គាលទៅជាអំពើមនុស្សឃាត អង្គជំនុំជម្រះតុលាការកំពូល បានពន្យល់ថា ការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូង គឺគ្រប់គ្រាន់ដើម្បីបង្ហាញធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់នៃអំពើមនុស្សឃាត រួមបញ្ចូលទាំង ធាតុផ្សំអត្តនោម័តិនៃ *ចេតនាប្រយោល*ដែលបណ្តាលឱ្យមានមរណភាព ដោយសារតែលក្ខខណ្ឌនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២[338]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេស កត់សម្គាល់បន្ថែមទៀតថា ការចោទប្រកាន់អង្គហេតុនៃការសម្លាប់ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី២ ត្រូវបានបង្ហាញនៅក្នុងដីកាដំណោះស្រាយ [339] ។ ហេតុដូច្នេះ ក្រុមប្រឹក្សាជំនុំជម្រះពិសេសយល់ឃើញថា ការកំណត់បទចោទនៃការសម្លាប់រង្គាលទៅជាការធ្វើមនុស្សឃាត មិនគ្រប់គ្រាន់ក្នុងការបង្ហាញអំពីអាការៈនៃភាពលំអៀងនោះទេ។

អង្គជំនុំជម្រះតុលាការកំពូល មិនត្រូវបន្ថែមធាតុផ្សំថ្មីនៃបទល្មើសណាមួយ ដែលមិនបានដាក់ជូននៅអង្គជំនុំជម្រះសាលាដំបូងដើម្បីសម្រេចនោះទេ")។

[336] សំណើរបស់លោក ខៀវ សំផន សុំប្តឹងជំទាស់ចៅក្រម (១), កថាខណ្ឌ ៩៨។

[337] វិធាន ៩៨(២), ១១០(២) នៃវិធានផ្ទៃក្នុង។សំណើរបស់លោក ខៀវ សំផន សុំប្តឹងជំទាស់ចៅក្រម (១), កថាខណ្ឌ ៩៧-៩៩។ វិធាន ១១០(២) នៃវិធានផ្ទៃក្នុងចែងថា ("គ្រប់ករណីទាំងអស់ អង្គជំនុំជម្រះតុលាការកំពូល អាចកែប្រែបទចោទប្រកាន់ ដែលអង្គជំនុំជម្រះសាលាដំបូងបានកំណត់។ ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូល មិនត្រូវបន្ថែមធាតុផ្សំថ្មីនៃបទល្មើសណាមួយ ដែលមិនបានដាក់ជូននៅអង្គជំនុំជម្រះសាលាដំបូងដើម្បីសម្រេចនោះទេ")។

[338] សាលដីកាលើសំណុំរឿង ០០២/១ (F36), កថាខណ្ឌ ៥៥៨, ៥៦១ *ដែលក្នុងនោះក៏បានយោងទៅ* សាលក្រមលើសំណុំរឿង ០០២/១ (E313), កថាខណ្ឌ ៦៤៨ ("អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ថ្នាក់ដឹកនាំបក្សមិនបានគិតគូរអំពីមេរៀនផ្សេងៗ ដែលទទួលបានពី [ការផ្លាស់ទីលំនៅ] នៅក្នុងដំណាក់កាលទី១ទេ ហើយមិនបានចាត់វិធានការដើម្បីធានាថា ប្រជាជនបានទទួលជំនួយឧបត្ថម្ភ ឬ កន្លែងស្នាក់នៅគ្រប់គ្រាន់ នៅក្នុងកាផ្លាស់ទីលំនៅដំណាក់កាលទី២"។ ចំណុចនេះបញ្ជាក់ថា ជនល្មើសបានធ្វើសកម្មភាពដោយចេតនាប្រយោល (*dolus eventualis*)")។ (ជើងទំព័រយោងត្រូវបានលុបចោល)។

[339] សាលដីកាលើសំណុំរឿង ០០២/១ (F36), កថាខណ្ឌ ៥៦២ *ដែលយោងទៅលើ* ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (D427), កថាខណ្ឌ ១៣៧៣, ១៣៨១។ វិធាន ៩៨(២) នៃវិធានផ្ទៃក្នុង។

១១១. ចំណុចទី២ ទាក់ទងទៅនឹងការផ្តន្ទាទោសចំពោះបទមនុស្សឃាត និងអំពើអមនុស្សធម៌ផ្សេងៗទៀតនៃការបាត់ខ្លួនដោយបង្ខំ ក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី២ តាមរយៈ JCE[340] ក្រុមប្រឹក្សាជំនុំជម្រះពិសេសកត់សំគាល់ថា ការចោទប្រកាន់របស់សហមេធាវីនៅក្នុងករណីនេះមិនទំនង។ នៅក្នុងដីកាកំណត់កាលបរិច្ឆេទសវនាការលើបណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថា ដីកាដំណោះស្រាយ និងសាលក្រម ពុំបានពន្យល់អំពីមូលហេតុអ្វី ដែលការទទួលខុសត្រូវដោយផ្អែកលើ JCE មិនបានពង្រីកដល់ឧក្រិដ្ឋកម្មទាំងអស់ ដែល ខៀវ សំផន ត្រូវបានចោទប្រកាន់ និងផ្តន្ទាទោស[341]។ ទោះបីជាអញ្ជើញភាគីឲ្យដាក់សេចក្តីសង្កេតលើបញ្ហានេះក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលបានជូនដំណឹងថា ខ្លួនអាចពិចារណាកែប្រែការកំណត់ប្រភេទបទល្មើស រួមទាំងលទ្ធភាពនៃការកែប្រែបទចោទចំពោះការទទួលខុសត្រូវនៃ JCE លើឧក្រិដ្ឋកម្មទាំងអស់ ដែលអាចមានការតម្កល់ការផ្តន្ទាទោសចំពោះ ខៀវ សំផន[342]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញថា ខៀវ សំផន ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់នៃអំពើមនុស្សឃាត និងអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោម JCE[343]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេស រំលឹកថា ចំពោះបណ្តឹងជំទាស់ ភាគីត្រូវបង្ហាញថា "សេចក្តីសម្រេចទាំងនេះត្រូវបាន ឬ នឹងត្រូវបានយល់ឃើញយ៉ាងសមហេតុផលថា ជាលទ្ធផលនៃបុរេវិនិច្ឆ័យប្រឆាំងនឹងម្ចាស់បណ្តឹង ដែលមិនមែនជាការអនុវត្តច្បាប់ពិតប្រាកដ ផ្អែកលើលទ្ធផលនៃបកស្រាយច្បាប់ ឬ ការវាយតម្លៃរបស់ចៅក្រមលើនោះទៅលើអង្គហេតុនានា"។ ម្យ៉ាងវិញទៀត រាល់ការមិនយល់ស្របជាមួយអង្គសេចក្តីនៃសេចក្តីសម្រេចបើកផ្លូវឲ្យប្តឹងឧទ្ធរណ៍[344]។ ផ្អែកលើហេតុផលខាងលើ ក្រុមប្រឹក្សាជំនុំជម្រះពិសេសមិនជឿជាក់ទឡ្ហីករណ៍របស់សហមេធាវីថា ការកំណត់ប្រភេទបទល្មើសឡើងវិញនៃទម្រង់នៃការទទួលខុសត្រូវចំពោះ JCE ទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់នៃអំពើមនុស្សឃាត និងអំពើអមនុស្សធម៌ផ្សេងៗទៀត គឺជាមធ្យោបាយ "លាក់បំពួនវៀចវេរ និងភាន់ច្រឡំច្បាស់ក្រឡែត" ដែលត្រូវបានប្រើដោយអង្គជំនុំជម្រះតុលាការកំពូល ដើម្បីតម្កល់ការផ្តន្ទាទោស ដើម្បីធានាដល់ការផ្តន្ទាទោសចំពោះ

[340] សំណើរបស់លោក ខៀវ សំផន សុំប្តឹងជំទាស់ចៅក្រម (១), កថាខណ្ឌ ១០០-១០៥។

[341] ដីកាកំណត់កាលបរិច្ឆេទសវនាការបណ្តឹងសាទុក្ខ (F30), ទំព័រ ៤។

[342] ដីកាកំណត់កាលបរិច្ឆេទសវនាការបណ្តឹងសាទុក្ខ (F30), ទំព័រ ៤-៧។

[343] សាលដីកាលើសំណុំរឿង ០០២/១ (F36), កថាខណ្ឌ ១០៩៦-១០៩៩។

[344] សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំប្តឹងជំទាស់ចៅក្រម (ឯកសារលេខ ៧), កថាខណ្ឌ ៣៤-៣៥។ សេចក្តីសម្រេចលើបណ្តឹងជំទាស់ (E55/4), កថាខណ្ឌ ១៣។ សំអាងហេតុចំពោះសេចក្តីសម្រេចលើបណ្តឹងជំទាស់ ក្នុងសំណុំរឿង ០០២/២ (E314/12/1) កថាខណ្ឌ ៣៦។

ការសម្លាប់ ឬ ដើម្បីធានាដល់ការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត[345]។ ដូច្នេះ ក្រុមប្រឹក្សាជំនុំជម្រះពិសេសពិចារណាឃើញថា សហមេធាវីខកខានមិនបានបង្ហាញភ័ស្តុតាងគាំទ្រឡើយថា អ្នកសង្កេតការណ៍ដ៏សមហេតុផលនឹងអាចមើលឃើញភាពលំអៀងនៅក្នុងសំអាងហេតុស្តីពីការកំណត់ប្រភេទបទល្មើសឡើងវិញ។

១១២. ក្រុមប្រឹក្សាជំនុំជម្រះពិសេសយល់ឃើញថា សហមេធាវីខកខានមិនបានបំពេញបន្ទុកនៃភ័ស្តុតាងក្នុងការបង្ហាញអំពីភាពលំអៀង ឬ អាការៈសមហេតុផលនៃភាពលំអៀងនៅក្នុងសំអាងហេតុនៃសាលដីកាសំណុំរឿង ០០២/១ ហេតុដូច្នេះ សម្រេចបដិសេធមូលដ្ឋានទី ២។

## គ. មូលដ្ឋានទី៣៖ ការបញ្ជាក់ពីភាពយឺតយ៉ាវចាប់តាំងពីពេលប្រកាសសាលក្រមនៃសំណុំរឿង ០០២/២

### ១. សារណា

១១៣. សហមេធាវីបានលើកឡើងថា លក្ខណៈនៃការចេញដីកាសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលតាំងពីពេលប្រកាសសាលក្រមសំណុំរឿង០០២/២ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ដូចរៀបរាប់លម្អិតនៅខាងក្រោម បានធ្វើឱ្យកាន់តែមានមន្ទិលសង្ស័យថា ខៀវ សំផន មិនមានឱកាសក្នុងការប្តឹងសាទុក្ខឡើយ[346]។

១១៤. អង្គជំនុំជម្រះតុលាការកំពូលបានច្រានចោលបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ជំទាស់ទៅនឹងទម្រង់នៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ដោយថាមិនអាចទទួលយកបាន បានបកស្រាយខុសចំពោះគោលបំណងនៃបណ្តឹងសាទុក្ខនោះ ដោយថាសហមេធាវី "ប្តឹងសាទុក្ខលើសេចក្តីសង្ខេបនៃសាលក្រម"មិនមែនប្រឆាំងនឹង"ផ្នែកសម្រេចសេចក្តីនៃសាលក្រមឡើយ"[347]។

---

345 សំណើរបស់លោក ខៀវ សំផន សុំប្តឹងជំទាស់ចិត្តថៅក្រម (១), កថាខណ្ឌ ១០៥។

346 សំណើសុំប្តឹងជំទាស់ចិត្តរបស់ ខៀវ សំផន (១) កថាខណ្ឌ ១១០។

347 សំណើសុំប្តឹងជំទាស់ចិត្តរបស់ ខៀវ សំផន (១) កថាខណ្ឌ ១១១ យោងទៅ បណ្តឹងសាទុក្ខភ្លាមៗ ឯកសារ E463/1, សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ ឯកសារ E463/1/3, ការឆ្លើយតបរបស់លោក ខៀវ សំផន ទៅនឹងចម្លើយតបរបស់ សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងសាទុក្ខភ្លាមៗ ប្រឆាំងនឹងសាលក្រម ប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ឯកសារ E463/1/2/1 ("ការឆ្លើយតប E463/1/2/1")។

១១៥. ជាលទ្ធផល សហមេធាវីបានស្នើសុំឱ្យធ្វើមោឃភាពសេចក្តីសម្រេចនេះ ដោយផ្អែកលើមូលដ្ឋានថា ចៅក្រមបម្រុងមិនត្រូវបានតែងតាំងជាផ្លូវការជាចៅក្រមពេញសិទ្ធិ នៅពេលចេញសេចក្តីសម្រេចនោះ[348]។ អង្គជំនុំជម្រះតុលាការកំពូលមិនបានជូនដំណឹងអំពីសំណើនេះ រយៈពេលជាងបីខែ បើទោះបីជាមានសារណាជាបន្តបន្ទាប់របស់សហមេធាវីក្តី[349]។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា សំណើនេះមិនមានមូលដ្ឋានទេ ហើយមានទស្សនៈថា "មេធាវីការពារក្តីបំភ្លៃកាលប្បវត្តិ" បើទោះបីជាសហមេធាវីបានផ្តល់កាលប្បវត្តិដូចគ្នាបេះបិទ ហើយគាំទ្រដល់អង្គហេតុ ដែលការពិភាក្សាសម្រេចត្រូវបានធ្វើឡើងជាមួយចៅក្រមបម្រុង នៅមុនពេលមានការតែងតាំងរូបគាត់[350]។ សហមេធាវីចោទប្រកាន់ថា "កង្វះតម្លាភាពជាញឹកញាប់ និងគួរឱ្យសង្ស័យ" របស់តុលាការកំពូល ធ្វើឱ្យមានការយល់ឃើញពីភាពលម្អៀង[351]។

១១៦. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាបានលើកឡើងថា សហមេធាវីមិនបានបំពេញតាមបទដ្ឋានស្តីពីការបង្ហាញភស្តុតាងកម្រិតខ្ពស់ខ្លាំង អំពីភាពលម្អៀង និង/ឬការយល់ឃើញពីភាពលម្អៀង ទាក់ទងទៅនឹងសេចក្តីសម្រេចពីររបស់អង្គជំនុំជម្រះតុលាការកំពូល ដែលបានចេញចាប់តាំងពីមានការប្រកាសជាសាធារណៈពីសាលក្រមសំណុំរឿង ០០២/០២ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨[352]។

១១៧. ទីមួយ សហព្រះរាជអាជ្ញាបានជំទាស់ថា ផ្ទុយពីការអះអាងរបស់សហមេធាវី អង្គជំនុំជម្រះតុលាការកំពូលមិនបានបំពេញកិច្ចនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះចំពោះ បណ្តឹងសាទុក្ខភ្លាមៗរបស់សហមេធាវី ថាជាការប្តឹងសាទុក្ខទៅលើសេចក្តីសង្ខេប មិនមែនទៅលើផ្នែកសម្រេចសេចក្តីរបស់សាលក្រមអង្គជំនុំជម្រះសាលាដំបូង ដែលបានប្រកាសផ្ទាល់មាត់កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ឡើយ[353]។ សហព្រះរាជអាជ្ញាបានបញ្ជាក់ថា សំអាងហេតុរបស់អង្គជំនុំជម្រះតុលាការកំពូលសម្រាប់ការ

---

[348] សំណើសុំប្តឹងជំទាស់ចិត្តរបស់ ខៀវ សំផន (១) កថាខណ្ឌ ១១២ *យោងទៅ* សំណុំរឿង ០០២/២ សំណើសុំមោឃភាពរបស់ខៀវ សំផន ឯកសារ E463/1/4។

[349] សំណើសុំប្តឹងជំទាស់ចិត្តរបស់ ខៀវ សំផន (១) កថាខណ្ឌ ១១២។

[350] សំណើសុំប្តឹងជំទាស់ចិត្តរបស់ ខៀវ សំផន (១) កថាខណ្ឌ ១១៣ យោងទៅ សេចក្តីសម្រេចលើសំណើសុំមោឃភាព ឯកសារ E465/1/5។

[351] សំណើសុំប្តឹងជំទាស់ចិត្តរបស់ ខៀវ សំផន (១) កថាខណ្ឌ ១១៣។

[352] ចម្លើយតបរបស់ សហព្រះរាជអាជ្ញា (៥) កថាខណ្ឌ ៦៧-៧២។

[353] ចម្លើយតបរបស់ សហព្រះរាជអាជ្ញា (៥) កថាខណ្ឌ ៦៨។

ប្រកាសថា បណ្តឹងសាទុក្ខភ្លាមៗមិនអាចទទួលយកបាន បង្ហាញថា អនុវត្តចំពោះតែបណ្តឹងសាទុក្ខទៅលើផ្នែកសម្រេចសេចក្តីប៉ុណ្ណោះ[354]។

១១៨. ទីពីរ សហព្រះរាជអាជ្ញាបានជំទាស់ថា សហមេធាវីមិនបានបង្ហាញពីបុរេវិនិច្ឆ័យណាមួយដែល បណ្តាលមកពីការពន្យារពេលរយៈពេលបីខែ ក្នុងការជូនដំណឹងអំពីសំណើ ជាពិសេសនៅពេលដែលអង្គជំនុំជម្រះតុលាការកំពូលចេញសេចក្តីសម្រេចរបស់ខ្លួន លើសំណើសុំមោឃភាព នៅក្នុងរយៈពេលមួយខែបន្ទាប់ពីការជូនដំណឹង[355]។ ដោយរម្លឹកឡើងវិញថា សហមេធាវីយល់ច្រឡំ "អំពីការទទួលបាននូវសេចក្តីសម្រេចដែលរងការជំទាស់ពីមន្ត្រីគ្រប់គ្រងសំណុំរឿង ជាមួយនឹងសេចក្តីជូនដំណឹងនៃដីកាចាត់តាំងតាមប្រព័ន្ធអេឡិចត្រូនិក" សហព្រះរាជអាជ្ញាបានអះអាងថា សហមេធាវីយល់ខុសចំពោះការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ទាក់ទងនឹងពេលវេលានៃដីកាចាត់តាំង[356]។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ទោះជាក្នុងករណីណាក្តី ភាពមិនប្រក្រតីផ្នែកនីតិវិធីណាមួយ មិនមានអានុភាពទៅលើខ្លឹមសារនៃសេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ ហើយសេចក្តីសម្រេច ដែលមិនមានបង្កព្យសនកម្មចំពោះ ខៀវ សំផន មិនមែនជាភាពលម្អៀងណាមួយប្រឆាំងនឹងរូបគាត់ឡើយ[357]។

## ២. ការពិភាក្សា

១១៩. ជាដំបូង ក្រុមប្រឹក្សាជំនុំជម្រះពិសេស បានបញ្ជាក់ថា "ចំណុចចាប់ផ្តើមនៃការសម្រេចលើការជំទាស់អំពី [ភាពលម្អៀង] គឺថា "មានការសន្មតទុកជាមុនអំពីភាពមិនលម្អៀងដែលមានចំពោះចៅក្រម" ដែលជាលក្ខខណ្ឌតម្រូវខ្ពស់សម្រាប់ភាគីដែលធ្វើបណ្តឹង ក្នុងការដកចេញការសន្មតទុកជាមុននេះ[358]។ ក្រុម

---

[354] ចម្លើយតបរបស់ សហព្រះរាជអាជ្ញា (៥) កថាខណ្ឌ ៦៩ យោងទៅ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ (ឯកសារ E463/1/3) កថាខណ្ឌ ១៦-១៧។

[355] ចម្លើយតបរបស់ សហព្រះរាជអាជ្ញា (៥) កថាខណ្ឌ ៧០។

[356] ចម្លើយតបរបស់ សហព្រះរាជអាជ្ញា (៥) កថាខណ្ឌ ៧១។

[357] ចម្លើយតបរបស់ សហព្រះរាជអាជ្ញា (៥) កថាខណ្ឌ ៧២។

[358] សំណុំរឿង០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ០១) សេចក្តីសម្រេចជាសាធារណៈ ស្តីពីបណ្តឹងជំទាស់ជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល រង់ចាំបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ក្នុងសំណុំរឿង នួន ជា ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ ឯកសារ C11/29 ("សេចក្តីសម្រេចលើសំណើសុំប្តឹងជំទាស់ភ្លាមៗ (ឯកសារC11/29)") កថាខណ្ឌ ១៥ យោងទៅតុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង* Furundzija, IT-95-17/1-A, សាលដីកាអង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ កថាខណ្ឌ ១៩៦ តុលាការ SCSL *រដ្ឋអាជ្ញា តទល់នឹង* Norman, SCSL-

ប្រឹក្សាជំនុំជម្រះពិសេសបានសម្រេចដូចគ្នានឹងអង្គជំនុំជម្រះនានារបស់ អ.វ.ត.ក ថា នៅពេលចោទប្រកាន់អំពីភាពលម្អៀង ផ្អែកលើសេចក្ដីសម្រេចរបស់តុលាការ ភាគីមួយចាំបាច់ត្រូវបង្ហាញថា "សេចក្ដីសម្រេចទាំងនេះត្រូវបាន ឬនឹងត្រូវបានយល់ឃើញយ៉ាងសមហេតុផលថា ជាលទ្ធផលនៃបុរេវិនិច្ឆ័យ ប្រឆាំងនឹងម្ចាស់បណ្ដឹង ដែលមិនមែនជាការអនុវត្តច្បាប់ពិតប្រាកដ ផ្អែកលើលទ្ធផលនៃបកស្រាយច្បាប់ ឬការវាយតម្លៃរបស់ចៅក្រមនោះ ទៅលើអង្គហេតុនានា"[359]។ ត្រង់ចំណុចនេះ ការត្រួតពិនិត្យទៅលើសេចក្ដីសម្រេចរបស់តុលាការ ដែលត្រូវបានដកស្រង់ជាភស្តុតាងនៃភាពលម្អៀង ត្រូវបានធ្វើឡើង "មិនមែនដើម្បីរកកំហុសនោះទេ ប៉ុន្តែដើម្បីកំណត់ថាតើ កំហុសទាំងនោះ ប្រសិនបើរកឃើញ បង្ហាញថា ចៅក្រមរូបនោះ ពិតជាមានភាពលម្អៀងដែរឬទេ ហើយអ្នកសង្កេតការណ៍មិនលម្អៀង ដែលយល់ដឹងអំពីកាលៈទេសៈពាក់ព័ន្ធ នឹងយល់ឃើញអំពីភាពលម្អៀងនេះ ប្រកបដោយហេតុផលដែរឬទេ"[360]។

១២០. ក្រុមប្រឹក្សាជំនុំជម្រះពិសេស នាពេលនេះនឹងពិនិត្យទៅលើការចោទប្រកាន់ពីភាពលម្អៀង នៅក្នុងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលដែលបានចេញចាប់តាំងពីពេលប្រកាសសាលក្រមសំណុំរឿង០០២/២។ ចំពោះសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្ដឹងសាទុក្ខភ្លាមៗ ក្រុម

---

2004-14-PT សេចក្ដីសម្រេចលើញត្តិប្ដឹងជំទាស់ចៅក្រម Winter ចេញពីការពិភាក្សាសម្រេចលើ ញត្តិបឋមស្ដីពីការជ្រើសរើសកងទ័ពកុមារ, អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៤ កថាខណ្ឌ ២៥ តុលាការ ICTR *រដ្ឋអាជ្ញា តទល់នឹង Karema និងអ្នកដទៃទៀត* ICTR-98-44-T សេចក្ដីសម្រេចលើញត្តិរបស់ Karema ប្ដឹងជំទាស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០០៤ កថាខណ្ឌ ១០ សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងរបស់ អៀង ធីរិទ្ធ នួន ជា និង អៀង សារី ដែលប្ដឹងជំទាស់ចំពោះលោកចៅក្រម និល ណុន ចៅក្រម Silvia Cartwright ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc Lavergne និងចៅក្រម ធូ មណី ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១១ ឯកសារ E55/4 ("សេចក្ដីសម្រេចលើសំណើសុំប្ដឹងជំទាស់ (ឯកសារ E55/4)") កថាខណ្ឌ ១២។

[359] សំណុំរឿង ០០២/២ សំអាងហេតុចំពោះ សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ ឯកសារE314/12/1 ("សំណុំរឿង ០០២/២ សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ (ឯកសារ E314/12/1)") កថាខណ្ឌ ៣៦ សេចក្ដីសម្រេចលើសំណើសុំប្ដឹងជំទាស់ (ឯកសារ E55/4) កថាខណ្ឌ ១៣ 13 យោងទៅ សំណុំរឿង០០២/១៣-១០-២០០៩-អវតក/អបជ (០២) សេចក្ដីសម្រេចលើសំណើរបស់ ខៀវ សំផន ប្ដឹងជំទាស់សហចៅក្រមស៊ើបអង្កេត Marcel Lemonde ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ឯកសារលេខ ៧ កថាខណ្ឌ ៣៤ តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង Blagojević និងអ្នកដទៃទៀត* IT-02-60 សេចក្ដីសម្រេចលើសំណើរបស់ Blagojević អនុលោមតាមវិធាន ១៥(ខ) ការិយាល័យតុលាការ ICTY ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ កថាខណ្ឌ ១៤។

[360] សំណុំរឿង ០០២/២ សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ (ឯកសារ E314/12/1) កថាខណ្ឌ ៣៦ យោងទៅតុលាការ ICTR *រដ្ឋអាជ្ញា តទល់នឹង Seromba* ICTR-2001-66-T សេចក្ដីសម្រេចលើញត្តិប្ដឹងជំទាស់ចៅក្រម, ការិយាល័យតុលាការ ICTR ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៦ កថាខណ្ឌ ១២។

ប្រឹក្សាជំនុំជម្រះពិសេសកត់សម្គាល់ឃើញថា កំហុសឆ្គងដែលបានចោទប្រកាន់ កើតចេញពី "ការបំភ្លៃកម្មវត្ថុនៃបណ្តឹងសាទុក្ខ" ដោយអង្គជំនុំជម្រះតុលាការកំពូល ក្នុងការសម្រេចថា បណ្តឹងសាទុក្ខមិនអាចទទួលយកបាន[361]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសពិចារណាឃើញថា ផ្ទុយពីទឡ្ហីករណ៍របស់សហមេធាវី[362] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ យោងទៅ "ការប្រកាសនូវផ្នែកសម្រេច" នៃសាលក្រម មិនមែនជា "ការប្រកាសសេចក្តីសង្ខេប" ឡើយ[363]។ ដោយសារតែមិនមានភស្តុតាងគាំទ្រការចោទប្រកាន់ពី "ការបំភ្លៃ" ដោយអង្គជំនុំជម្រះតុលាការកំពូល ក្រុមប្រឹក្សាជំនុំជម្រះពិសេសមិនជឿថា សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់អង្គជំនុំជម្រះតុលាការកំពូល បង្ហាញពីភាពលម្អៀងរបស់ចៅក្រមដែលរងការចោទប្រកាន់ឡើយ។

១២១. ចំពោះការចោទប្រកាន់ពីភាពលម្អៀង ផ្អែកលើសេចក្តីសម្រេចលើសំណើសុំមោឃភាពវិញ ក្រុមប្រឹក្សាជំនុំជម្រះពិសេស កត់សម្គាល់ថា សំណើសុំមោឃភាព ត្រូវបានសហមេធាវីដាក់ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ ហើយត្រូវបានជូនដំណឹងនៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៩[364]។ អង្គជំនុំជម្រះតុលាការកំពូលបាន

---

361 សំណើសុំប្តឹងជំទាស់របស់ ខៀវ សំផន (១) កថាខណ្ឌ ១១១។

362 សំណើសុំប្តឹងជំទាស់របស់ ខៀវ សំផន (១) កថាខណ្ឌ ១១១។

363 សំណុំរឿង ០០២/២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងការប្រកាសសេចក្តីសង្ខេប នៃសាលក្រមដែលបានធ្វើឡើងនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨, ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ឯកសារ E463/1/3 ("សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ (ឯកសារ E463/1/3),") កថាខណ្ឌ ៦ ("ការប្រកាសសេចក្តីសង្ខេបនៃសាលក្រម និងការយល់ឃើញរបស់ អង្គជំនុំជម្រះសាលាដំបូង កាលពីថ្ងៃ១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ គឺជាការប្រកាសនូវ "ផ្នែកសម្រេចសេចក្តីរបស់ អង្គជំនុំជម្រះ") កថាខណ្ឌ ៩ ("ដែលខុសពី "ផ្នែកសម្រេចសេចក្តី" ដែលអង្គជំនុំជម្រះបានចេញកាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៦") កថាខណ្ឌ ១៤ ("អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ការប្រកាសផ្នែកសម្រេចសេចក្តីនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ តាមធម្មតាបញ្ចប់ដំណាក់កាលជំនុំជម្រះ")។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសកត់សម្គាល់ថា ជាច្រើនលើកច្រើនសារ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ បានយោងទៅ "ការប្រកាសសេចក្តីសង្ខេបសាលក្រម និងការយល់ឃើញ"។ សូមមើល សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ (ឯកសារ E463/1/3) កថាខណ្ឌ ៦, ១២, ១៨។ ទោះបីជាបែបនេះក្តី ការប្រើប្រាស់ក្នុងពេលជាមួយគ្នានូវពាក្យ "សេចក្តីសង្ខេប" និង "ផ្នែកសម្រេចសេចក្តី" ដោយអង្គជំនុំជម្រះតុលាការកំពូល មិនបានបង្ហាញអំពីបុរេវិនិច្ឆ័យ ចំពោះម្ចាស់បណ្តឹងឡើយ ដោយសារតែការប្រកាសសាលក្រម សំដៅលើការប្រកាសសេចក្តីសង្ខេបនៃការយល់ឃើញ និងផ្នែកសម្រេចសេចក្តីអនុលោមតាមវិធាន ១០២(១) នៃវិធានផ្ទៃក្នុង។ សូមមើល វិធាន ១០២(១) នៃវិធានផ្ទៃក្នុង សំណុំរឿង ០០២/២ ប្រតិចារឹកកិច្ចដំណើរការនីតិវិធីសវនាការ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ការប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២ ឯកសារ E1/529.1 ERN (ភាសាខ្មែរ) 01589681 ទំព័រ ៣៨៖ ១៥-១៦ (""បាទ សេចក្តីសង្ខេបនៃសំអាងហេតុ របស់អង្គជំនុំជម្រះចប់ត្រឹមនេះ ហើយជាបន្តយើងនឹងអានផ្នែកសម្រេចសេចក្តី)។

364 សំណុំរឿង ០០២/២ សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំធ្វើមោឃភាពសេចក្តីសម្រេចលេខ E463/1/3 លើ ប

ច្រានចោលសំណើសុំនេះដោយសម្រេចថា"យល់ច្រឡំការទទួលបានសេចក្តីសម្រេចដែលរងការជំទាស់ពីមន្ត្រីគ្រប់គ្រងសំណុំរឿង ជាមួយនឹងសេចក្តីជូនដំណឹងនៃដីកាចាត់តាំងតាមប្រព័ន្ធអេឡិចត្រូនិក" និងថា សហមេធាវី "លើកឡើងបែបស្មានៗ ... អំពីលក្ខណៈ ពេលវេលា និងខ្លឹមសារ នៃការពិភាក្សារបស់ចៅក្រម ជុំវិញសេចក្តីសម្រេចដែលរងការជំទាស់ ត្រូវទុកជាអាសាបង់"[365]។

១២២. ទឡ្ហីករណ៍របស់សហមេធាវីនៅក្នុងមូលដ្ឋាននេះ បង្ហាញពីការមិនយល់ស្របរបស់ខ្លួនទៅនឹងសំអាងហេតុ ដោយមិនបានបង្ហាញអំពីលទ្ធភាពនៃភាពលម្អៀងណាមួយរបស់ចៅក្រមដែលរងការចោទប្រកាន់ឡើយ។ លើសពីនេះទៀត ការចោទប្រកាន់ពីការពន្យារពេលក្នុងការជូនដំណឹងអំពីសំណើ ដែលជាភារកិច្ចរបស់ក្រឡាបញ្ជីអង្គជំនុំជម្រះ [366] មិនមានភាពគ្រប់គ្រាន់សម្រាប់ការដកចេញនូវការសន្និដ្ឋានអំពីភាពមិនលម្អៀងរបស់ចៅក្រមដែលរងការចោទប្រកាន់ឡើយ។

១២៣. ទឡ្ហីករណ៍របស់សហមេធាវីលើ "កង្វះតម្លាភាពជាញឹកញាប់ និងគួរឲ្យសង្ស័យ" របស់អង្គជំនុំជម្រះតុលាការកំពូល មិនមានមូលដ្ឋានឡើយ។ សូម្បីតែសន្មតថា មានភាពមិនប្រាកដប្រជាផ្នែកនីតិវិធី ទាក់ទងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចាប់តាំងពីពេលប្រកាសសាលក្រមសំណុំរឿង ០០២/២ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ក្តី តែត្រឹមតែការសង្ស័យលើតម្លាភាពនៃនីតិវិធី មិនមានភាពគ្រប់គ្រាន់សម្រាប់ការគាំទ្រដល់អត្ថិភាពនៃការចោទប្រកាន់អំពីភាពលម្អៀង ឬការយល់ឃើញអំពីភាពលម្អៀងរបស់ចៅក្រមដែលរងការចោទប្រកាន់ឡើយ។

១២៤. ហេតុដូច្នេះ ក្រុមប្រឹក្សាជំនុំជម្រះពិសេសសម្រេចបដិសេធមូលដ្ឋាននេះ។

## V. សម្រេចសេចក្តី

ផ្អែកលើហេតុផលដែលបានលើកឡើងខាងលើ ក្រុមប្រឹក្សាពិសេសសម្រេចជាឯកច្ឆ័ន្ទថា៖

---

ណ្តឹងសាទុក្ខភ្លាមៗរបស់ខ្លួន ប្រឆាំងនឹងសាលក្រមប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨, ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ ឯកសារ E463/1/5 ("សេចក្តីសម្រេចលើសំណើសុំមោឃភាព (ឯកសារ E463/1/5)") កថាខណ្ឌ ៣។

[365] សេចក្តីសម្រេចលើសំណើសុំមោឃភាព (ឯកសារ E463/1/5) កថាខណ្ឌ ៥-៦។

[366] សេចក្តីសម្រេចលើសំណើសុំមោឃភាព (ឯកសារ E463/1/5) កថាខណ្ឌ ៥។

- **បដិសេធ** សំណើរបស់សហមេធាវីសុំបើកសវនាការលើសំណើសុំ។[367]

- **បដិសេធ** សំណើសុំប្ដឹងជំទាស់ទាំងស្រុង។

ភ្នំពេញ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០

**ប្រធាន** **ក្រុមប្រឹក្សាជំនុំជម្រះពិសេស**

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **ន័យ ធុល** **Kang Jin BAIK** **ហួត វុទ្ធី**

**ស៊ិន រិទ្ធ** **Steven BWANA**

[367] អង្គជំនុំជម្រះពិសេសយល់ឃើញថាព័ត៌មានដែលក្រុមប្រឹក្សាមាននៅចំពោះមុខ គ្រប់គ្រាន់សម្រាប់ការចេញសេចក្ដីសម្រេចត្រឹមត្រូវមួយ ហើយដើម្បីជាប្រយោជន៍នៃយុត្តិធម៌ ក្រុមប្រឹក្សាត្រូវដំណើរការទៅមុខឱ្យបានលឿន។